anti-slavery

today's fight for tomorrow's freedom

ប្រឆាំងអំពើទាសករ

*ការតស៊ូប្រឆាំងថ្ងៃនេះដើម្បីសេរីភាពនៅថ្ងៃស្អែក*

# ខ្សែបណ្ដាញនៃអំពើជួញដូរអន្តោប្រវេសន៍

## បង្ក្រាបអំពើជួញដូរតាមរយៈការការពារសិទ្ធិសមនុស្សរបស់ជនអន្តោប្រវេសន៍



**ខ្សែបណ្តាញនៃអំពើជួញដូរអន្តោប្រវេសន៍: ការបង្រ្កាបអំពើជួញដូរតាមរយៈការការពារសិទ្ធិមនុស្សរបស់ជនអន្តោប្រវេសន៍**

**មាតិកា** **ទំព័រ**


១. សេចក្តីផ្តើម :ការប្រមើលមើលការជួញដូរជាផ្នែកមួយនៃរបៀបវារៈនៃសិទ្ធិជនអន្តោប្រវេសន៍។ ៣-៦

២. ដំណោះស្រាយសំរាប់អំពើជួញដូរក្នុងបណ្តាប្រទេសគោលដៅ ។ ៦-២៤

ស្ថានភាពរួមនៃអំពើជួញដូរនៅលើសកលលោក

ការប្រឈមមុខលើការងារផ្តន្ទាទោស

កង្វះខាតការការពារ

៣. ខ្សែបណ្តាញនៃអំពើជួញដូរអន្តោប្រវេសន៍ ២៤-៣៦

ស្ថានភាពរួមនៃអន្តោប្រវេសន៍កម្មអន្តរជាតិ

ការកើនឡើងនូវតម្រូវការអន្តោប្រវេសន៍កម្មករក្នុងប្រទេសអភិវឌ្ឍន៍

ថវិការផ្ញើ

៤. ការការពារសិទ្ធិជនអន្តោប្រវេសន៍ ៣៦-៥៦

យន្តការការពារអន្តរជាតិ

សារៈសំខាន់នៃអនុសញ្ញាអន្តោប្រវេសន៍ឆ្នាំ ១៩៩០ : ឧទាហរណ៍មកពីចក្រភពអង់គ្លេស និង ឥណ្ឌូនេស៊ី

៥. សន្និដ្ឋាន ៥៦-៥៩

ជីវប្រវត្តិដែលបានជ្រើសរើស

វែបសាយសំខាន់ៗមានប្រយោជន៍

ឧបសម្ពន្ធ័ ១: បទដ្ឋានអន្តរជាតិដែលទាក់ទងនឹងសិទ្ធិជនអន្តោប្រវេសន៍ ការងារបង្ខិតបង្ខំ និង អំពើចរាចរជួញដូរនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។

## ១. សេចក្តីផ្តើម : ការប្រមើលមើលការជួញដូរជាផ្នែកមួយនៃរបៀបវារៈនៃសិទ្ធិជនអន្តោប្រវេសន៍

ការបង្ខំពលករអន្តោប្រវេសន៍



អំពើចរាចរ រត់ពន្ធ និង ការធ្វើអន្តោប្រវេសន៍គឺមានលក្ខណៈផ្សេងៗពីគ្នា ក៏ប៉ុន្តែជាបញ្ហាដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ការធ្វើអន្តោប្រវេសអាចកើតមានឡើងតាមរយៈខ្សែបណ្តាញធម្មតា និង មិនធម្មតាហើយអាចជ្រើសរើសបានដោយសេរី ឬ ដោយបង្ខំដោយជនអន្តោប្រវេសន៍ដើម្បីធ្វើជាមធ្យោបាយរស់រានមានជីវិត (ឧ. ក្នុងអំឡុងពេលមានជម្លោះ បញ្ហាសេដ្ឋកិច្ច ឬ គ្រោះមហន្តរាយបរិដ្ឋាន) ។ ប្រសិនបើវិធីសាស្ត្រនៃការធ្វើអន្តោប្រវេសន៍មានលក្ខណៈមិនប្រក្រតីទេនោះ ជនអន្តោប្រវេសន៍អាចស្ថិតនៅក្រោមការជួយជ្រោមជ្រែងដោយអ្នករត់ពន្ធដែលនឹងសំរបសំរួលអោយចូលក្នុងប្រទេសណាមួយដោយយកកម្រៃ ។ អ្នករត់ពន្ធអាចទាមទារយកកម្រៃដ៏ច្រើន ហើយអាចបណ្តាលអោយជនអន្តោប្រវេសន៍ជួបប្រទះនឹងគ្រោះថ្នាក់នានាក្នុងពេលធ្វើដំណើរ ក៏ប៉ុន្តែនៅពេលទៅដល់គោលដៅ ជនអន្តោប្រវេសន៍មានសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯង ហើយជាធម្មតានឹងមិនជួបជាមួយនឹងអ្នករត់ពន្ធនោះជាលើកទីពីរនោះទេ ។

អំពើចរាចរមានលក្ខណៈខុសពីនេះច្រើនដោយសារថា វាពាក់ពន្ធ័នឹងការបំលាស់ទីមនុស្សក្នុងគោលបំណងធ្វើការកេងប្រវញ្ច័លើការងារ ឬ សេវាកម្មផ្សេងៗរបស់ពួកគេ[១] ។ មនុស្សភាគច្រើនដែលទទួលរងការជួញដូរគឺជនអន្តោប្រវេសន៍ជាកម្មករ[២] ។ អ្នកទាំងនេះគឺព្យាយាមរត់គេចចេញពីភាពអត់ឃ្លាន និង ការរើស

---

[1] អន្តរជាតិបានទទួលស្គាល់ និយមន័យអពើជួញដូរមនុស្ស ដែលបានចែងក្នុងពិធីសារអង្គការសហប្រជាជាតិ ស្តីពីការបង្កា ការបង្ក្រាប និងការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ខែវិច្ឆិកា ឆ្នាំ ២000 (មើលលំអិត ចំនុច ១, ១) ។

[2] ការលើកលែងក្នុងផ្នែកនេះ គឺមនុស្សមួយភាគតូច ដែលត្រូវបានគេចាប់ រឹលក់ បង្ខំពលកម្ម ហើយគេមិនបានធ្វើការសំរេចចាកចេញ ។

អើង ធ្វើអោយជីវិតរបស់គេបានប្រសើរឡើងនិង ផ្ញើប្រាក់ទៅក្រុមគ្រួសាររបស់គេវិញ ។ ពួកគេបានឮអំពីការងារដែលបានទទួលកម្រៃច្រើននៅបរទេសតាមរយៈក្រុមគ្រួសារ ឬ មិត្តភក្រ័ ឬ តាមរយៈ " ភ្នាក់ងាររកការងារ " ឬ បុគ្គលផ្សេងៗទៀតដែលសន្យាជួយរកការងារអោយពួកគេ និង រៀបចំការធ្វើដំណើរ ។ សំរាប់មនុស្សដែលគេចរាចរភាគច្រើន គឺបញ្ហាកើតមានតែនៅពេលដែលពួកគេទៅដល់ប្រទេសគោលដៅដែលការងារដែលគេបានសន្យាថាទទួលបានមិនមាននៅទីនោះ ហើយផ្ទុយទៅវិញពួកគេត្រូវបានទទួលការបង្ខិតបង្ខំអោយធ្វើការងារ ឬ ក្នុងលក្ខខណ្ឌដែលពួកគេមិនបានឯកភាព ។

វាមិនមែនជាការជួនគ្នានោះទេ ចំពោះការកើនឡើងនៃអំពើជួញដូរបានកើតឡើងក្នុងអំឡុងពេលដែលមានតំរូវការកើនឡើងសំរាប់ជនអន្តោប្រវេសន៍ជាកម្មករដែលមិនត្រូវបានទទួលស្គាល់ ឬ សម្របសំរួលអោយបានត្រឹមត្រូវ ។ ការខ្វះខាតឱកាសសំរាប់ការធ្វើអន្តោប្រវេសន៍ធម្មតាដើម្បីស្វែងរកការងារធ្វើនៅក្នុងបណ្តាប្រទេសផ្សេងៗទៀត និង ការពិតដែលថាជនអន្តោប្រវេសន៍ជាច្រើនកំពុងស្វែងរកការងារធ្វើនៅបរទេសដើម្បីរស់ ជាជាងឱកាសដើម្បីកត្តាជីវភាពរបស់ពួកគេ បានបន្សល់ទុកនូវជំរើសដ៏តូចបំផុតសំរាប់ជនអន្តោប្រវេសន៍ដែលត្រូវបង្ខំចិត្តពឹងលើអ្នករត់ពន្ធ ឬ អ្នកចរាចរដើម្បីទទួលបានការងារទាំងនេះ ។

ទោះបីជាបែបនេះក៏ដោយ រដ្ឋាភិបាលជាច្រើនបានឆ្លើយតបទៅនឹងបញ្ហានេះដោយស្នើសុំអោយមានការគ្រប់គ្រងកិច្ចការអន្តោប្រវេសន៍អោយបានកាត់តែតឹងរឹងថែមទៀត ដែលជាធម្មតាបង្កើនប្រាក់ចំណេញដល់ការរត់ពន្ធ និង ចរាចរ និង រឹតតែធ្វើអោយបញ្ហានេះកាន់តែពិបាកថែមទៀត ។

ដូច្នេះការបោះពុម្ពនេះមានបំណងពិនិត្យមើលលើបញ្ហាការជួញដូរក្នុងក្របខណ្ឌ័នៃការធ្វើអន្តោប្រវេសន៍ដែលមានលក្ខណៈទូលំទូលាយមួយ និង ដើម្បីស្នើឡើងនូវគោលនយោបាយដែលអាចមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយអំពើចរាចរ និង ក្នុងការបង្កាទប់ស្កាត់ការរំលោភលើសិទ្ធិមនុស្ស និង ការងារដែលតែងតែទទួលរងគ្រោះដោយជនអន្តោប្រវេសន៍ជាកម្មករនាបច្ចុប្បន្ននេះ ។

ផ្នែកទីមួយនៃការបោះពុម្ពផ្សាយនេះលើកឡើងអំពីទស្សនៈរួមនៃអំពើចរាចរមនុស្សជាអន្តរជាតិ ។ មានការពិចារណាលើយន្តការគំរាមគំហែងនានា ដែលអ្នកចរាចរប្រើប្រាស់ដើម្បីគ្រប់គ្រងលើជនអន្តោប្រវេសន៍ដែលទទួលរងការជួញដូរ និង មូលហេតុដែលលំបាកក្នុងការផ្តន្ទាទោស ។ អវត្តមាននៃវិធានការសមស្របដើម្បីការពារ និង ជួយជនអន្តោប្រវេសន៍ដែលទទួលរងការជួញដូរត្រូវបានគូសបញ្ជាក់ថាជាការបរាជ័យមួយដ៏ពិសេសក្នុងយុទ្ធសាស្រ្តនៃការប្រឆាំងអំពើចរាចរជួញដូរនៃបណ្តារដ្ឋជាច្រើន ។

ផ្នែកទីពីរលើកឡើងបញ្ជាក់ថាគោលនយោបាយដើម្បីជំរុញបង្កើនអោយមានការផ្តន្ទាទោស និង ផ្តល់ការគាំទ្រព្រមទាំងការការពារដល់ជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ ភាគច្រើននឹងទទួលបរាជ័យប្រសិនបើ

ទាំងអស់នេះមិនមែនជាផ្នែកមួយនៃយុទ្ធសាស្រ្តទូលំទូលាយជាងនេះដែលទទួលស្គាល់អំពីសេចក្តីត្រូវការ ឬ ការកើនឡើងនៃចំនួនជនអន្តោប្រវេសន៍ជាកម្មករ ហើយលើកឡើងនូវគោលនយោបាយដើម្បីគ្រប់គ្រង និង សំរបសំរួលការធ្វើអន្តោប្រវេសន៍នេះ ។ ជំពូកនេះលើកឡើងអំពីស្ថានភាពរួមនៃអំពើជួញដូរនាពេលបច្ចុប្បន្ន នេះរួមទាំងកត្តាជំរុញ និង កត្តាទាក់ទាញដែលលើកទឹកចិត្តអោយមានការធ្វើអន្តោប្រវេសន៍អន្តរជាតិ ។ ជំពូកនេះក៏លើកឡើងផងដែរនូវភស្តុតាងអំពីតំរូវការកើនឡើងលើជនអន្តោប្រវេសន៍ជាកម្មករ និង លើក សំណើរអំពីថាតើត្រូវសំរបសំរួលការធ្វើអន្តោប្រវេសន៍នេះបែបណាដើម្បីអាចផ្តល់ផលប្រយោជន៍អោយជន អន្តោប្រវេស ព្រមទាំងប្រទេសដែលបញ្ជូន និង ប្រទេសទទួលជនអន្តោប្រវេសន៍នោះ ។

ជំពូកទីបីផ្តោតសំខាន់លើសេចក្តីត្រូវការទទួលស្គាល់ និង គោរពសិទ្ធិការងារ និង សិទ្ធិមនុស្សនៃ ជនអន្តោប្រវេសន៍កម្មករទាំងអស់ដូចមានចែងក្នុង *អនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីការការពារសិទ្ធិរបស់ ជនអន្តោប្រវេសន៍កម្មករទាំងអស់ និង ក្រុមគ្រួសាររបស់ពួកគេ ឆ្នាំ ១៩៩០* (ក្រោយមកគេស្គាល់ថាជា អនុ សញ្ញាជនអន្តោប្រវេសន៍ឆ្នាំ ១៩៩០ ) ។ ជំពូកនេះវាយតំលៃលើចំនុចផ្សេងៗនៃអនុសញ្ញាអន្តរជាតិមួយចំនួន ដែលអាចប្រើប្រាស់ដើម្បីជួយ និង ការពារជនអន្តោប្រវេសន៍ជាកម្មករ និងផ្តល់ឧទាហរណ៍លើប្រទេសពីរ ដែលច្បាប់ដែលមានហើយបង្ហាញថាមិនទាន់គ្រប់គ្រាន់ ហើយមិនបានទប់ស្កាត់បង្កាការកេងប្រវញ្ច័ និង ការងារដោយបង្ខិតបង្ខំលើជនអន្តោប្រវេសន៍ជាកម្មករ ទោះបីជានៅពេលពួកគេធ្វើអន្តោប្រវេសន៍ដោយមធ្យោ បាយធម្មតាក៏ដោយ ។

## ១.១. និយមន័យនៃអំពើជួញដូរ

ពិធីសារអង្គការសហប្រជាជាតិដើម្បីបង្កាទប់ស្កាត់ បង្ក្រាប និង ផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារដោយបន្ថែមលើអនុសញ្ញាស្តីអំពីស្តីបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង (ដែលហៅថា ពិធីសារជួញដូរ) វិច្ឆិកា ២០០០ កំណត់និយមន័យអំពើជួញដូរដូចខាងក្រោមនេះ :

" ការជួល ការដឹកជញ្ជូន ការផ្ទេរ ការរក្សាទុក ឬ ការទទួលមនុស្ស ដោយមធ្យោបាយនៃការគំរាម គំហែង ឬ ប្រើប្រាស់ការបង្ខិតបង្ខំ ឬ ដោយរូបភាពបង្ខឹតបង្ខំណាផ្សេងទៀត ដោយការចាប់ពង្រត់ ឆបោក គៃបន្លំ ការបំពានអំណាច ឬ មុខងារលើជនរងគ្រោះ ឬ ដោយការអោយ ឬការទទួលប្រាក់ ឬ ផលប្រយោជន៍ផ្សេងៗដើម្បីទទួលបាននូវការយល់ព្រមពីមនុស្សម្នាក់ដែលមានអំណាចគ្រប់គ្រងលើជនម្នាក់ទៀត

ដើម្បីគោលបំណងកេងប្រវ័ញ្ច ។ ការកេងប្រវ័ញ្ចយ៉ាងហោចណាស់ត្រូវរួមបញ្ចូលទាំងការកេងប្រវ័ញ្ចលើអំពើពេស្យាចាលើអ្នកដ៏ទៃ ឬ រូបភាពផ្សេងៗទៀតនៃអំពើកេងប្រវ័ញ្ចផ្លូវភេទ ការងារ ឬ សេវាបង្ខិតបង្ខំ ទាសភាព ឬ ទង្វើប្រហាក់ប្រហែលទៅនឹងទាសភាព ឬ ការយកអង្គសរីរាង្គ" ។

និយមន័យបានបញ្ជាក់ច្បាស់ថា អំពើជួញដូរមិនកម្រិតត្រឹមការដឹកជញ្ជូនមនុស្សណាម្នាក់ពីកន្លែងមួយទៅកន្លែងមួយទៀតប៉ុណ្ណោះទេតែថែមទាំងការជួល និង ការទទួលពួកគេដែលជនណាម្នាក់មានការពាក់ពន្ធ័នឹងការបំលាស់ទីអ្នកផ្សេងម្នាក់ទៀតដើម្បីគោលបំណងកេងប្រវ័ញ្ចគឺជាជាផ្នែកមួយនៃដំណើរការជួញដូរហើយ។

និយមន័យក៏បញ្ជាក់ដែរថាអំពើជួញដូរមិនកម្រិតត្រឹមការកេងប្រវ័ញ្ចផ្លូវភេទនោះទេ តែក៏អាចកើតឡើងក្នុងការងារបង្ខិតបង្ខំ និង អំពើដែលដូចគ្នានឹងទាសភាព ។ នេះមានន័យថាមនុស្សដែលធ្វើអន្តោ-ប្រវេសន៏រកការងារធ្វើក្នុងវិស័យកសិកម្ម បដិសណ្ឋារកិច្ចម្ហូបអាហារ ការងារសាងសង់ ឬ ការងារជាបម្រើក្នុងផ្ទះក្រោមការឆបោក ឬ បង្ខិតបង្ខំអោយធ្វើការងារនោះក្នុងលក្ខខណ្ឌដែលពួកគេមិនឯកភាព ក៏ត្រូវចាត់ទុកថាជាមនុស្សដែលទទួលរងការជួញដូរដែរ ។

## ២. ការដោះស្រាយបញ្ហាអំពើជួញដូរក្នុងបណ្តាប្រទេសគោលដៅ

### ទស្សនៈរួមអំពីអំពើជួញដូរ



ក្មេងដែលត្រូវគេជួញដូរទៅក្នុងឧស្សាហកម្មនេសាទ ប្រទេសអាហ្វ្រិកខាងលិច ។ ក្មេងប្រុសៗ ទាញសំណាញ់ដែលឃ្លាំមើលដោយ "មេទាសករ" នៅតុងកា ច្រាំងសមុទ្រវ៉ុលតា ។

អំពើជួញដូរមនុស្សមានការកើតឡើងយ៉ាងខ្លាំងក្នុងអំឡុងឆ្នាំ ១៩៩០ ហើយរដ្ឋាភិបាលអាមេរិកប៉ាន់ប្រមាណថានៅបច្ចុប្បនេះមានមនុស្សប្រមាណ ៨០០-៩០០,០០០ នាក់ត្រូវទទួលរងការជួញដូរឆ្លងកាត់តាមព្រំដែនជារៀងរាល់ឆ្នាំ[៣] ។ ការស្រាវជ្រាវដែលបានធ្វើឡើងដោយ អង្គការការងារអន្តរជាតិ បានប៉ាន់ប្រមាណថាក្នុងឆ្នាំ ២០០០ មានកុមារចំនួន ១,២ លាននាក់ត្រូវបានជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និង ការងារជាអន្តរជាតិ[៤] ។

ការគណនាតួលេខដ៏ត្រឹមត្រូវមួយ លើចំនួនមនុស្សសរុបដែលរងការជួញដូរមានការលំបាកដោយសារធម្មជាតិនៃភាពលាក់កំបាំងនៃអំពើជួញដូរ និង បញ្ហាដែលពាក់ពន្ធ័នឹងការតាមដាន និង ការចងក្រងឯកសារអំពីករណីជួញដូរ ។ ការប៉ាន់ប្រមាណលើករណីដែលបានចងក្រងឯកសារជាធម្មតាតែងតែបានប្រើប្រាស់ដើម្បីកំណត់ចំនួនដែលមិនមានការចាប់អារម្មណ៍ពីសាធារណជន ហើយជានិច្ចកាលតែងតែមានកំហុសឆ្គងជាយថាហេតុ ។ ការវាយតំលៃនេះកាន់តែមានការលំបាកថែមទៀតនៅពេលដែលត្រូវធ្វើឡើងទូទាំងតំបន់ ឬជាអន្តរជាតិដោយសារថាទិន្នន័យអាចប្រមូលមកដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យផ្សេងៗគ្នា ឧទាហរណ៍ដូចជាមួយចំនួនពិនិត្យមើលតែទៅលើអ្នកដែលត្រូវជួញដូរឆ្លងកាត់ព្រំដែន ហើយអ្នកផ្សេងទៀតមើលទាំងឆ្លងកាត់ព្រំដែន ការជួញដូរនៅខាងក្នុងប្រទេស ។ អង្គការការងារអន្តរជាតិ បញ្ជាក់អំពីការជួបការលំបាករបស់ខ្លួនក្នុងការប្រមូលទិន្នន័យអំពីជនរងគ្រោះដោយអំពើជួញដូរជាកុមារ ជាពិសេសដូចជាស្ថិតិមួយចំនួនដែលបានប្រមូលមកគឺផ្អែកទៅតាមឆ្នាំ ហើយអ្នកផ្សេងទៀតបានពិនិត្យមើលតែលើចំនុចសំខាន់ដើម្បីវាស់ស្ទង់ចំនួនអ្នកដែលទទួលរងអំពើជួញដូរនៅពេលណាមួយតែប៉ុណ្ណោះ ។

ទោះបីមានការលំបាកបែបនេះក្តី ការប្រមូលពត៌មានពិស្តារអំពីការជួញដូរដែលរួមមានស្ថិតិដើម និង ការវិភាគលំអិតលើករណីនានា មានសារៈសំខាន់ណាស់ប្រសិនបើយើងចង់ស្វែងយល់អំពី "វិធីសាស្ត្រប្រតិបត្តិការ " របស់អ្នកជួញដូរ មូលហេតុអ្វីបានជាពួកគេទទួលរងនូវការជួញដូរ និង តើអ្នកចរាចរជួញដូរបន្តគ្រប់គ្រងពួកគេយ៉ាងដូម្តេចនោះ ។ ចំនុចទាំងអស់នេះអាចមានលក្ខណៈខុសៗគ្នាពីក្រុមជួញដូរមួយទៅក្រុមជួញដូរមួយផ្សេងទៀតក៏ដូចពីបណ្តាប្រទេសមួយទៅប្រទេសមួយទៀតផងដែរ *(មើល ២.១)* ។ មានតែក្រោយពេលដែលប្រមូលពត៌មានទាំងនេះបានទេ ទើបយើងអាចរៀបចំបង្កើនឡើងនូវយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធិភាពដែលរួមបញ្ចូលទាំងកាលៈទេសៈផ្សេងៗក្នុងបណ្តាប្រទេសបញ្ជូន និង ទទួល ។ គោលនយោបាយប្រឆាំងការជួញដូរសមាហរណកម្មគួរមានផ្អែកដែលធ្វើយ៉ាងណាធានាអោយបាននូវការផ្តន្ទាទោសអ្នកជួញដូរ ការការ

---

[3] US State Department, *Trafficking in Persons Report 2003, Washington 2003.*
[4] International Labour Office, *Every Child Counts-New Global Estimates on Child Labour, Geneva, 2002.*

ពារ និង គាំទ្រជនដែលទទួលរងអំពើជួញដូរ និង ការបង្ការទប់ស្កាត់អំពើជួញដូរតាមរយៈការអនុវត្តវិធានការដើម្បីដោះស្រាយលើឫសគល់នៃបញ្ហាតែម្តង ។

**២. ១ អំពើជួញដូររវាង Benin និង Gabon**

ក្នុងឆ្នាំ ១៩៩៩ អង្គការមួយនៅ បិនីញឈ្មោះ Enfants Solidairs D' Afrique et du Monde (ESAM) បានបញ្ចប់ការងារស្រាវជ្រាវស្តីអំពីអំពើជួញដូរកុមាររវាងសាធារណរដ្ឋ បិនីញ និង ហ្គាបុន ។ ការស្រាវជ្រាវនេះផ្អែកលើការសំភាសឪពុកម្តាយ កុមារ គ្រួសារទទួល អ្នកជួញដូរ និង មន្ត្រី ហើយលទ្ធផលដែលរកឃើញត្រូវបានសង្ខេបជូនដូចខាងក្រោមនេះ ។

ក្រុមគ្រួសារជាច្រើនដែលកូនរបស់ពួកគេត្រូវបានជួញដូរនិយាយថាពួកគេមានកូនចាប់ពីមួយនាក់ឡើងទៅដែលរស់នៅបរទេស ។ ដោយភាគច្រើន គឺ ៦៣ ក្នុងចំណោមឪពុកម្តាយចំនួន ១៧០ ដែលបានសំភាស (៣៧ ភាគរយ) បាននិយាយថាពួកគេមិនអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់របស់ក្រុមគ្រួសារពួកគេហេតុដូច្នេះហើយទើបត្រៀមខ្លួនក្នុងការអោយកូនទៅអ្នកជួញដូរ ។ ការសំភាសជាមួយនឹងកុមារនៅ បិនីញ បង្ហាញអោយឃើញថា ឪពុកម្តាយរបស់ពួកគេមានឥទ្ធិពលណាស់ក្នុងការបញ្ចុះបញ្ចូលអោយកូនៗសហការជាមួយនឹងអ្នកជួញដូរ ។ ក្មេងចំនួន ២៨១ នាក់ដែលបានសំភាសនៅ បិនីញ ២១២ (៧៥ ភាគរយ) បាននិយាយថា ពួកគេនឹងទៅប្រសិនបើឪពុកម្តាយរបស់ពួកគេប្រាប់អោយទៅ ។ កុមារភាគច្រើនដែលទទួលរងការជួញដូរ ៨៨ ភាគរយមកពីស្រុកចំនួន ០៣ នៅ បិនីញ គឺ Oueme, Mono និង Atlantique ។

តាមការពិនិត្យលើកុមារចំនួន ២៩៩ នាក់ដែលបានទទួលរងការជួញដូរ សរុបចំនួន ១៩៨ នាក់ (៨៦ ភាគរយ) គឺជាក្មេងស្រី ។ ចំនុចនេះឆ្លុះបញ្ចាំងថាក្មេងស្រីគឺមានតំរូវការច្រើនជាងសំរាប់ការងារនៅក្នុងផ្ទះ និង នៅទីផ្សារជាអ្នកលក់ ។ ការសំភាសក៏បានបង្ហាញផងដែរថាគេមានការចាប់អារម្មណ៍លើក្មេងស្រីច្រើនជាងក្មេងប្រុសដោយសារថាពួកគេអាចនឹងមិនធ្វើការតវ៉ាប្រឆាំងអ្វីច្រើនទេ នៅពេលដែលពួកគេធំឡើងប្រៀបធៀបទៅនឹងក្មេងប្រុស ។ ការចំណាយលើការរៀបអាពាហ៍ពិពាហ៍របស់កូនស្រីក៏អាចជាចំនុនសំខាន់មួយដែលជាមូលហេតុនៃការបញ្ជូនក្មេងស្រីអោយអ្នកជួញដូរច្រើនជាងក្មេងប្រុស ។ ចំពោះក្មេងប្រុសដែលត្រូវបានគេជួញដូរ តាមរយៈការសំភាសឃើញថាស្ទើរតែ ២/៣ នៃពួកគេធ្វើការនៅផ្នែកកសិកម្ម និង នេសាទ។

ពត៌មានសំខាន់ៗផ្សេងទៀតដែលចេញមកពីការស្រាវជ្រាវនេះគឺថា ក្មេងជាច្រើនដែលព្យាយាមឆ្លងព្រំដែន ឬ ត្រូវបញ្ជូនត្រឡប់មកវិញពីប្រទេសដែលអ្នកជួញដូរបញ្ជូនពួកគេទៅមិនវិលត្រឡប់មកផ្ទះរបស់គេវិញនោះទេ ។ កុមារចំនួន ៩១ នាក់នៅ ប៉ិនីញត្រូវបានប្រមូលចេញពីតារាងចំនួន ១៥០ នាក់ដែលត្រូវបានចងក្រងជាឯកសារដោយនាយកដ្ឋាននគរបាលពិសេសដើម្បីការពារអនិតិជន ។ ទោះជាបែបណាក៏ដោយអ្នកស្រាវជ្រាវអាចស្វែងរកតែចំនួន ៩១ នាក់ (៦១ ភាគរយ) ក្នុងចំណោមក្មេងចំនួន ១៥០ នាក់នោះតែប៉ុណ្ណោះដែលបង្ហាញថាកុមារជាច្រើនដែលបញ្ជូនត្រឡប់មកវិញត្រូវទទួលរងការជួញដូរសារជាថ្មីនាពេលក្រោយមក ។

កុមារសរុបចំនួន ៩១ នាក់ត្រូវគេសំភាសនៅ ប៉ិនីញអំពីលក្ខខណ្ឌនៅកន្លែងការងារដែលពួកគេធ្វើនៅពេលពួកគេនៅ ហ្កាបូន ។ ចំពោះលក្ខខណ្ឌនៃការរស់នៅ ជាង ២/៣ នៃកុមារទាំងនេះនិយាយថា "អាក្រក់ " ។ ពួកគេលើកឡើងថាទទួលរងការស្រែកគំរាមដាក់ ខ្វះចំណីអាហារ និង ទទួលរងការវាយដំដោយនិយោជិកដែលជាឧទាហរណ៍អំពីលក្ខខណ្ឌមិនល្អដែលពួកគេទទួលរង ។

ចំពោះលក្ខខណ្ឌកន្លែងធ្វើការងារ កុមារជាងពាក់កណ្តាលនិយាយថាមិនល្អ ។ កុមារទាំងនេះជាទូទៅធ្វើការអោយអ្នកលក់ដូរ ហើយត្រូវធ្វើការពី ១៤ ទៅ ១៨ ម៉ោងក្នុងមួយថ្ងៃ-នេះរួមទាំងការងារនៅផ្ទះ និងការងារតាមទីផ្សារ ។ ពួកគេត្រូវលីសែងអ៊ីវ៉ាន់ធ្ងន់ៗ និង ដើរចម្ងាយឆ្ងាយដើម្បីលក់ទំនិញ ។ អ្នកជួលពួកគេភាគច្រើន (៩៥ ភាគរយ) គឺជាស្ត្រី ។

ប្រភេទនៃពត៌មានដែលផ្តល់ដោយការស្រាវជ្រាវនេះ រដ្ឋាភិបាលអាចយកមកប្រើប្រាស់បានដើម្បីជូនពត៌មានដល់គោលនយោបាយប្រឆាំងការជួញដូរសំដៅរកដំណោះស្រាយដល់ឬសគល់នៃបញ្ហា ហើយសំដៅសំខាន់ចំពោះតំបន់ និង បុគ្គលភាគច្រើនដែលកំពុងប្រឈមមុខនឹងសភាពគ្រោះថ្នាក់ ។



ក្មេងលក់ទឹក ដែលទូល ចំនុះច្រើនជាង ៧លីត្រ ។

បងស្រី ពីរែត នឹងក្មេងស្រី នៅមជ្ឈមណ្ឌល អាកូអែល លីបប្រេវីល ហ្គាបូន ។ ក្មេងស្រីទាំងនេះ ត្រូវបានគេជួញដូរទៅ ហ្គាបូន ។





Pelagy អាយុ៨ឆ្នាំ ហើយ Jocelyn អាយុ៦ឆ្នាំ ជាបងប្អូន ។ Pelagy ត្រូវបានគេជួញដូរ ពីបេនីន ដោយឡានដឹកទំនិញ កាត់តាម នីស្សេរីយ៉ា និង កាំម៉ារូន ទៅហ្គាបូន ។ Jocelyn ត្រូវបានគេដឹកតាមទូក ។ ក្មេងទាំងពីរត្រូវបានគេយកទៅធ្វើការក្នុងផ្ទះ ដោយ គ្មានប្រាក់កំរៃ ។

ស្ត្រីនេះធ្វើការជាអ្នកជួញដូរមនុស្ស ២៦ឆ្នាំ មកហើយ ដោយយកក្មេងពីបិនីន ទៅ នីស្សេរីយ៉ា ។ នាងនិយាយថា ក្មេងស្រី ដែលគាត់ ជួញដូរ គ្មានអនាគតទេរស់នៅ ជាមួយគ្រួសារ ហើយត្រូវរស់នៅក្នុងជីវិត ដ៏លំបាក ។



## ការប្រឈមមុខក្នុងការងារផ្តន្ទាទោស

ផ្នែកមួយនៃហេតុផលដែលថាអំពើជួញដូរមានការកើនឡើងក្នុងប៉ុន្មានឆ្នាំកន្លងមកនេះគឺដោយសារផលចំណេញខ្ពស់ និង ជាសហគ្រាសម្យ៉ាងដែលប្រឈមមុខនឹងគ្រោះថ្នាក់តិចតួច ។ អំពើចរាចរជួញដូរមនុស្សត្រូវបានគេប៉ាន់ប្រមាណថាទទួលបានផលចំណេញពី ៧ ទៅ ១០ កោដដុល្លារក្នុងមួយឆ្នាំនៅទូទាំងពិភពលោកដល់អ្នកដែលពាក់ព័ន្ធ[5] ។ គ្រោះថ្នាក់ដោយការចាប់បានមានកម្រិតទាបដោយសារអ្នកជួញដូរប្រើប្រាស់ទាំងការយន្តការបង្ខិតបង្ខំដើម្បីគ្រប់គ្រងលើជនអន្តោប្រវេសន៍ ហើយដើម្បីធានាអោយបានថាពួកគេមិនអាច ឬ មិនមានឆន្ទះក្នុងការទំនាក់ទំនង ឬ សហការជាមួយសមត្ថកិច្ច ។ យន្តការទាំងនេះរួមមានទាំង :

### ការគំរាមគំហែង ឬ ប្រើអំពើហឹង្សា

ការប្រើប្រាស់អំពើហឹង្សាដោយលាក់កំបាំង ឬ ដោយចំហររួមទាំងការធ្វើទារុណកម្ម និង រំលោភត្រូវបានយកមកប្រើប្រាស់ជាទូទៅ ដោយពួកចរាចរជួញដូរដើម្បីធ្វើជាមធ្យោបាយមួយអោយជនអន្តោប្រវេសន៍ទាំងនោះគោរពតាមពួកគេ ។ សំរាប់រយៈពេលវែង គឺការគំរាមកំហែងហឹង្សាប្រឆាំងនឹងក្រុមគ្រួសា ឬ មិត្តភក្រ័នៅក្នុងប្រទេសកំណើតដែលបង្ហាញអំពីការធ្វើអោយរាងចាលប្រកបដោយប្រសិទ្ធិភាពបំផុតចំពោះអ្នកទាំងឡាយណាដែលមានបំណងព្យាយាមរត់គេច ឬ រាយការណ៍អំពីអ្នកជួញដូរទៅអោយសមត្ថកិច្ច ។ ជនអន្តោប្រវេសន៍ជាច្រើននឹងទ្រាំទទួលរងក្នុងស្ថានភាពរបស់ពួកគេ ជាជាងការបញ្ចេញប្រាប់ដល់ក្រុមគ្រួសាររបស់ដែលអាចនាំដល់ការប្រើអំពើហឹង្សាសងសឹកមកវិញ ។

### ស្ថានភាពអន្តោប្រវេសន៍មិនប្រក្រតី និង ការគ្រប់គ្រងលើការធ្វើដំណើរ

អ្នកជួញដូរមិនជូនដំណើរជនអន្តោប្រវេសន៍ ទៅ និង មកពីកន្លែងធ្វើការងារ និង ចាក់សោរពួកគេក្នុងបន្ទប់ ឬ ផ្ទះដើម្បីរារាំងអ្នកនោះមិនអោយរត់គេចនោះទេ ។ តែមានយន្តការអាទិ៍កំបាំងផ្សេងទៀតសំរាប់គ្រប់គ្រងលើការធ្វើដំណើររបស់មនុស្សដូចជាការដកយកឯកសារធ្វើដំណើរ ឬ ចាប់បង្ខំអ្នកនោះអោយកាន់ទូរសព្ទ័ដៃនៅគ្រប់ពេលវេលាទាំងអស់ អាចមានប្រសិទ្ធិភាពដូចគ្នា ។

---

[5] UNICEF UK. *Eng Child Exploitation: Stop the Traffic, London, 2003, P.11.*
តាមទូរលេខជួញដូរមនុស្សជាអន្តរជាតិ មានភាពខុសគ្នារវាងការប៉ាន់ប្រមាណពីផលចំណេញដោយការជួញដូរមនុស្ស

ជនដែលត្រូវគេជួញដូរភាគច្រើនចូលមកប្រទេសគោលដៅដោយប្រើឯកសារក្លែងក្លាយ ឬ ដោយលួចលាក់ ។ ទោះបីជាជនអន្តោប្រវេសន៍នោះចូលដោយស្របច្បាប់ អ្នកជួញដូរធម្មតាដកយកលិខិតឆ្លងដែន និង ឯកសារធ្វើដំណើរផ្សេងៗទៀតដើម្បីកុំអោយជនអន្តោប្រវេសន៍អាចបង្ហាញថាពួកគេមានសិទ្ធិនៅក្នុងប្រទេសនោះ ។

ជនអន្តោប្រវេសន៍ជឿថាប្រសិនបើពួកគេទៅជួបជាមួយនឹងសមត្ថកិច្ច នោះពួកគេនឹងត្រូវគេបញ្ជូនត្រឡប់ទៅវិញ ឬ ទទួលរងការផ្តន្ទាទោស ហើយក្នុងករណីជាច្រើនដែលការភ័យខ្លាចទាំងនេះត្រូវបានគេរកឃើញថាពិតប្រាកដ ។ អ្នកជួញដូរក៏អះអាងដែរថាពួកគេគ្រប់គ្រងលើនគរបាល ដែលហាក់ដូចជាសមហេតុផលសំរាប់ជនអន្តោប្រវេសន៍មួយចំនួន ជាពិសេសប្រសិនបើមន្ត្រីរបស់រដ្ឋនោះឃុបឃិតក្នុងអំពើជួញដូរពួកគេចេញពីប្រទេសកំណើត ។

**ចំណងបំណុល**

ដើម្បីបង់ថ្លៃសំបុត្រសំរាប់ទទួលបានការងារល្អនៅបរទេសតាមការសន្យា ជនអន្តោប្រវេសន៍ភាគច្រើននឹងត្រូវការខ្ចីប្រាក់ ។ ប្រាក់នេះអាចបានមកពីក្រុមគ្រួសារ ឬ មិត្តភក្រ័ អ្នករកស៊ីចងការ ឬ មកពីអ្នកជួញដូរផ្ទាល់តែម្តង ។ នៅពេលពួកគេទៅដល់គោលដៅ និង ដឹងថាការងារដែលគេបានសន្យានោះមិនមាន ពួកគេត្រូវតែសងប្រាក់គេមកវិញដែលអាចមានតំលៃពី ១០០០ ទៅ ៣៥ ០០០ ដុល្លារ[៦] ។

ជនអន្តោប្រវេសន៍ដែលជាប់បំណុលចំពោះសមាជិកក្រុមគ្រួសារនៅស្រុកកំណើត នឹងមានអារម្មណ៍ថាពួកគេគ្មានជំរើសអ្វីផ្សេងនោះទេ ដោយសារថាពួកគេមិនអាចត្រឡប់ទៅស្រុកកំណើតវិញបានទេប្រសិនបើមិនមានប្រាក់ដែលជំពាក់គេនោះ ។ ជនអន្តោប្រវេសន៍ដែលជំពាក់ប្រាក់អ្នកចរាចរជួញដូរនឹងមានការខឹងមានកំហឹងចំពោះការចាញ់ល្បិចបោកប្រាស់ និង ទទួលរងការកេងប្រវញ្ច័ តែក៏អាចនៅមានអារម្មណ៍ថាពួកគេនៅមានកាតព្វកិច្ចក្នុងការបង់ប្រាក់សងទៅអ្នកជួញដូរវិញ និង ជឿថាពេលក្រោយពួកគេនឹងអាចរកប្រាក់បានដោយខ្លួនគេ ។ ការសង្ឃឹមបែបនេះអាចខុសដោយសារថាបំណុលរបស់គេអាចកើនឡើងយ៉ាងច្រើនតាមរយៈការចំណាយលើការស្នាក់នៅ ម្ហូបអាហារ និង ការប្រាក់ ។

---

[6] Salt, J. *Current Trends in International Migration in Europe,* Council of Europe, Strasbourg*, 2001.* Quoted in International Organization for Migration, World Migration 2003, Geneva, P.315.

**ចំណងផ្លូវមនោសញ្ចេតនា**

អ្នកជួញដូរមួយចំនួនប្រើប្រាស់ចំណងមនោសញ្ចេតនាដែលមានចំពោះពួកគេជាយន្តការសំរាប់ការគ្រប់គ្រងពួកគេ និង ចាប់បង្ខំពួកគេអោយធ្វើការប្រឆាំងនឹងឆន្ទ: ដែលជាញឹកញាប់ឃើញមានក្នុងអំពើពេស្យាចា ។ អ្នកជួញដូរប្រាប់ដល់ "មិតស្រី " របស់គេថា ពួកគេធ្វើដំណើរទៅប្រទេសមួយផ្សេងទៀតដើម្បីជីវិតប្រសើឡើង ហើយក្រោយមកក៏បំពាននឹងទំនុកចិត្តដែលបានបង្កើតហើយនោះ ។ ក្នុងស្ថានភាពបែបនេះ ស្ត្រីនោះមិនទាន់កំណត់បានភ្លាមថា " មិត្តប្រុស " របស់នាងគឺជាអ្នកជួញដូរនោះទេ ហើយដូចជាមួយនឹងជនរងគ្រោះនៃអំពើហិង្សក្នុងគ្រួសារដែរ វាអាចប្រើប្រាស់ពេលវេលាមួយរយ:មុនពេលដែលពួកគេអាចរៀបចំចាកចេញពីមនុស្សដែលកំពុងកេងប្រវញ្ច ឬ បំពានលើពួកគេ ។

**ការខ្វះជំរើស**

យន្តការគំរាមគំហែង រួមបញ្ចូលនឹងបញ្ហាជាក់ស្តែងដែលជនអន្តោប្រវេសន៍មិនមានប្រាក់ដើម្បីរស់ និង ខ្វះថវិការសំរាប់ការធ្វើដំណើរត្រឡប់មកវិញ បានកាត់បន្ថយជំរើសរបស់ពួកគេយ៉ាងខ្លាំងក្លាបំផុត ។ ស្របពេលដែលជនអន្តោប្រវេសន៍មិនស្គាល់ស្ថានភាពទឹកដីនៃប្រទេស ឬ ទីក្រុងដែលពួកគេទើបមករស់នៅផង មិនចេះភាសា និង មិនដឹងជាទៅពឹងពាក់អ្នកណាបានផងនោះ ជាធម្មតាពួកគេមានអារម្មណ៍ថាគ្មានជំរើសអ្វីក្រៅពីស្តាប់បង្គាប់អ្នកជួញដូរនោះទេ ។

កត្តាទាំងអស់នេះពន្យល់អំពីវិធីសាស្ត្រដែលអ្នកជួញដូររក្សាការគ្រប់គ្រងលើជនអន្តោប្រវេសន៍ និង ហេតុអ្វីបានជាជនអន្តោប្រវេសន៍ដែលភាគច្រើននឹងមិនទៅឬសហាការរជាមួយនឹងសមត្ថកិច្ចដើម្បីប្រឆាំងនឹងអ្នកជួញដូរ ។ អ្វីដែលជាបញ្ហាផងដែរនោះគឺថាសូម្បីតែរហូតមកដល់បច្ចុប្បន្ននេះហើយក៏ដោយ ភ្នាក់ងារអនុវត្តច្បាប់ ឬ មន្ត្រីអនុវត្តច្បាប់តិចតួចណាស់ដែលយល់ដឹងអំពីអ្វីទៅជាអំពើជួញដូរ និង វិធីសាស្ត្រប្រតិបត្តិការរបស់វា ។ នេះមានន័យថាជាញឹកញាប់ពួកគេមិនអាចកំណត់អត្តសញ្ញាណមនុស្សដែលពួកគេទំនាក់ទំនងជាមួយហើយដែលកំពុងត្រូវគេជួញដូរ ហើយជាលទ្ធផលពួកគេបាត់ឱកាសក្នុងការសង្គ្រោះពួកគេចេញពីវដ្តនៃការជួញដូរ និង កសាងសំណុំរឿងដើម្បីប្រឆាំងនឹងអ្នកជួញដូរ ។

ដោយសារមូលហេតុទាំងអស់នេះហើយទើបករណីដែលអ្នកជួញដូរម្នាក់ត្រូវបានគេស្គាល់អត្តសញ្ញាណហើយ និង មានភស្តុតាងគ្រប់គ្រាន់ដើម្បីឈានដល់ការចោទប្រកាន់ប្រឆាំងនឹងពួកគេនៅតែជាការលើកលែងជាជាងជាក្រិតក្រមទូទៅ ។ ទោះបីជាមានការចោទប្រកាន់ កង្វះខាតផ្លូវច្បាប់គ្រប់គ្រាន់ ភាគច្រើនមានន័យថា

អ្នកជួញដូរត្រូវបានចោទដោយអំពើល្មើសមិនសមស្រប ហើយប្រសិនបើរកឃើញថាមានទោសនឹងទទួលដោយកំរិតស្រាលបំផុត (មើល ២.២) ។

ស្ត្រីជនជាតិអាល់បានី បង្ហាញស្នាមដែលជាលទ្ធផលពីការវាយដំនាងដោយពួកជួញដូរមនុស្ស



### ២.២ ស្ថានភាពនៅក្នុងប្រទេសចក្រភពអង់គ្លេសរវាងឆ្នាំ ១៩៩៩ និង ២០០២

ក្នុងឆ្នាំ ១៩៩៩ អង្គភាពប្រឆាំងអបាយមុខ និង រង្គសាលនគរបាលក្រុងឡុងដុនបានចាប់ផ្តើមរៀបចំកសាងករណីដែលស្ត្រីត្រូវបានគេជួញដូរចូលប្រទេសចក្រភពអង់គ្លេសដើម្បីការកេងប្រវ័ញ្ចផ្លូវភេទ ។ ទោះបីជាអង្គភាពប្រឆាំងអបាយមុខ និង រង្គសាលនេះបានកំណត់យកករណីជួញដូរជាអាទិ៍ភាព អង្គភាពនេះជួបប្រទះនូវបញ្ហាដ៏ធ្ងន់ធ្ងរពីរ ។ ទីមួយគឺមិនមានភ្នាក់ងារណាមួយដែលអង្គភាពនេះអាចបញ្ជូនមនុស្សដែលត្រូវគេចរាចរជួញដូរដើម្បីគាំទ្រ ជួយ និង ការពារ ។ ទីពីរ មិនមានច្បាប់ដែលលើកឡើងអោយបានជាក់លាក់អំពីអំពើជួញដូរដែលមានន័យថានគរបាលត្រូវតែធ្វើការចោទប្រកាន់នូវបទល្មើសមិនសមស្របដូចមានចែងក្នុងច្បាប់ស្តីពីបទល្មើសផ្លូវភេទឆ្នាំ ១៩៥៦ ។

ផលវិបាកនៃបញ្ហានេះបានឆ្លុះបញ្ចាំងនៅក្នុងតួលេខអំពីការចោទប្រកាន់ដូចតទៅ ។ រវាងឆ្នាំ ១៩៩៩ និង ២០០២ អង្គភាពនគរបាលប្រឆាំងនឹង ឧបាយមុខ និង រង្គសាលបានស៊ើបអង្កេតករណីជួញដូរចំនួន ១៨ ដែលក្នុងនោះអ្នកជួញដូរចំនួន ៤៤ រូបត្រូវបានទទួលការចោទប្រកាន់ដោយបទល្មើសចែងក្នុងច្បាប់ស្តីពីបទល្មើសផ្លូវភេទឆ្នាំ ១៩៥៦ ដែលជាសំខាន់ផ្តោតលើការរស់នៅដោយផ្អែកលើប្រាក់ដែលបានមកពីពេស្យាចា និង

ការគ្រប់គ្រងលើពេស្យាចា ។ ក្នុងចំណោមនោះមានតែមនុស្សចំនួន ២០ នាក់ដែលជាប់ទោសពន្ធនាគារ និង មានតែចំនួនប្រាំនាក់ប៉ុណ្ណោះដែលកំរិតទោសលើសពីរយៈពេលពីរឆ្នាំ[7] ។

ជាការពិតណាស់ ការកាត់ទោសប្រភេទនេះនឹងមិនអាចជាការធ្វើអោយរាងចាលចំពោះអ្នកជួញដូរទេ ប្រៀបធៀបនឹងប្រាក់កាសដ៏ច្រើនដែលអាចរកបានពីអំពើនេះ ។ សញ្ញានៃទំហំផលចំណូលដែលអ្នកជួញដូរអាចរកបាននៅចក្រភពអង់គ្លេសគឺបានឆ្លុះបញ្ចាំងនៅក្នុងការរឹបអូសបាននូវទ្រព្យសម្បត្តិ ដោយអង្គភាពប្រឆាំងនឹងឧបាយមុខ និង វង្គសាលដោយមានទឹកប្រាក់ជាង ១ លានប៉ោននៅក្នុងតែចំនួនប្រាំបីករណីខាងលើ ។ គួរបញ្ជាក់ផងដែរថាចំនួននេះមិនតំណាងអោយផលចំណេញរួមដែលអ្នកជួញដូររកបាននោះទេ ព្រោះថាចំនួននេះមិនបានបូកបញ្ចូលនូវលុយដែលបានចំណាយរួចហើយ ឬ លុយដែលមិនទាន់បានតាមដាននៅឡើយ ។

ចក្រភពអង់គ្លេស និង បណ្តារដ្ឋនៅសហគមន៍អឺរ៉ុបបានទទួលស្គាល់នូវសេចក្តីត្រូវការចេញដែលហាមប្រាមដល់អំពើចរាចរទាំងសំរាប់ការកេងប្រវ័ញ្ចលើការងារ និង ផ្លូវភេទ និង កំរិតទោសទណ្ឌសមស្រប ។ តាមការពិតតាមក្របខណ្ឌសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសហគមន៍អឺរ៉ុបលើការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (២០០២) បណ្តារដ្ឋនៅសហគមន៍អឺរ៉ុបទាំងអស់ត្រូវធ្វើវិសោធនកម្មចាំបាច់លើច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនអោយបានមុនបំណាច់ឆ្នាំ ២០០៤ ។

ជាការពិតណាស់គឺមានសេចក្តីត្រូវការអោយមានច្បាប់ដែលហាមប្រាមលើអំពើជួញដូរ លើគ្រប់រូបភាពនៃការកេងប្រវ័ញ្ច និង កំណត់ការដាក់ទោសអោយបានសមស្របទៅតាមបទល្មើសនោះ ។ ទោះជាយ៉ាងនេះក៏ដោយ វាជាការសំខាន់ណាស់ដែលវិធានការច្បាប់ជាតិ និង តំបន់ត្រូវតែមានភាពស៊ីសង្វាក់គ្នាជាមួយនឹងនិយមន័យអំពីការជួញដូរនៅក្នុងពិធីសារស្តីអំពីការជួញដូរ បើពុំនោះទេអ្នកជួញដូរនឹងអាចគេចផុតពីការចោទប្រកាន់ហើយក្រុមជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរនឹងមិនទទួលបាននូវការទទួលស្គាល់នោះទេ ។

អនុសញ្ញាស្តីពីការទប់ស្កាត់ និង បង្ក្រាបអំពើជួញដូរស្ត្រី និង កុមារដើម្បីពេស្យាចា ដែលបានឯកភាពគ្នាដោយសហគមន៍អាស៊ីខាងត្បូងដើម្បីកិច្ចសហប្រតិបត្តិការតំបន់ (SAARC)[8] ក្នុងខែ មករា ឆ្នាំ ២០០២ គឺជាឧទាហរណ៍នៃគំនិតផ្តួចផ្តើមដែលមិនស៊ីសង្វាក់គ្នាជាមួយនឹងពិធីសារ ។ អនុសញ្ញា SAARC

---

[7] Vice Unit Statistics 1999-2002. ក្នុង ២៨រឿងក្តី មាន ៩រឿងក្តីកំពុងតែរងចាំសវនាការ ៦រឿងត្រូវបានគេនិរទេស ៣ត្រូវបានគេបញ្ជូនទៅធ្វើការនៅសហគម ២ត្រូវបានគេបោះចោលការចោទប្រកាន់ ២ទៀតកាត់ទោសព្យួ ១ត្រូវបានគេពិន័យ និង១ទៀតត្រូវបានគេព្រមាន។

[8] សមាជិក SAARC រួមទាំង ប្រទេសបង់ក្លាដែស បូតាន ឥណ្ឌា ម៉ាដាវ នេប៉ាល់ ប៉ាគីស្ថាន និងស្រីលង្កា

អនុវត្តបានតែចំពោះស្ត្រី និង កុមារ ហើយកម្រិតការសង្កត់ធ្ងន់លើពេស្យាចា ការកេងប្រវញ្ច័ផ្លូវភេទ និង អាពាហ៍ពិពាហ៍កុមារ ឬ ក្លែងក្លាយ ។ ជាលទ្ធផលអនុសញ្ញា SAARC មិនដូចជាពិធីសារចរាចរជួញដូរទេ គឺនឹងមិនលើកឡើងអំពីការជួញដូរដើម្បីគោលបំណងការងារ ដូចជាការងារក្នុងផ្ទះ ឬ អ្នកប្រណាំងសត្វអូដ ដែលជាបញ្ហាធ្ងន់ធ្ងរសំរាប់រដ្ឋសមាជិក SAARC មួយចំនួន ។



ក្មេងអាយុទើបតែ៤ឆ្នាំ ត្រូវបានគេជួញដូរទៅ United Arab Emirates ដើម្បីប្រើប្រាស់ជាអ្នកជិះសត្វអូដប្រណាំង ។

២.៣ **អំពើជួញដូរអ្នកប្រណាំងអូដទៅ the UAE** កុមារបន្តទទួលរងការចរាចរពីបណ្តាប្រទេសដូចជា បង់ក្លាដេស និង ប៉ាគីស្ថានដើម្បីប្រើប្រាស់ជាអ្នក ប្រណាំងសត្វអូដនៅ UAE ។ ការប្រើប្រាស់កុមារជាអ្នកជិះអូដប្រណាំងគឺមានលក្ខណៈគ្រោះថ្នាក់ស្រេចទៅ ហើយអាចបណ្តាលអោយមានរបួសស្នាមធ្ងន់ធ្ងរ និង ស្លាប់ផងក៏មាន ។ កុមារមួយចំនួនក៏ត្រូវរំលោភបំពាន ដោយអ្នកជួញដូរ និង និយោជក (ឧ. ការបង្អត់ម្ហូបអាហារ និង ការវាយដំពួកគេ ) ។ ការបំបែកកុមារ ចេញពីក្រុមគ្រួសាររបស់ពួកគេ និង ការបញ្ជូនពួកគេទៅប្រទេសផ្សេងទៀតដែលមនុស្ស វប្បធម៌ និង ភាសា ជាធម្មតាមិនអាចយល់គ្នាបាន ធ្វើអោយពួកគេពឹងផ្អែកតែលើនិយោជក និង បង្ខំអោយពួកគេក្លាយទៅជា កម្មករដោយបង្ខិតបង្ខំតែម្តង ។

UAE បានហាមដល់ការប្រើប្រាស់កុមារក្រោមអាយុ ១៥ ឆ្នាំ ឬមានទម្ងន់តិចជាង ៤៥ គីឡូក្រាម មិនអាចចូលរួមក្នុងការប្រណាំងសត្វអូដអស់រយៈពេលជាច្រើនឆ្នាំ ហើយបំរាមថ្មីដែលមានកំរិតទោសតឹងរឹងជាង បានចូលជាធរមាននៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០២ ។

ទោះជាយ៉ាងណា ក៏ដោយភស្តុតាងដែលការហាមប្រាមនេះមិនត្រូវបានអនុវត្តអោយបានត្រឹមត្រូវគឺបាន ឃើញច្បាស់នៅក្នុងការផ្សាយឯកសារដោយសាជីវកម្មផ្សព្វផ្សាយរបស់អូស្ត្រាលីនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣[៩] ។ អ្នកផលិតកុនត្រូវបានអញ្ជើញអោយចូលរួមក្នុងការប្រណាំងសត្វអូដ តែមន្ត្រីដែលនៅទីលាន ប្រណាំងហាក់ដូចជាមានការភ្ញាក់ផ្អើលនៅពេលឃើញវត្តមានរបស់គេ ។ គេឃើញមាននគរបាលអមដំណើរ អ្នកជិះអូដប្រណាំងដែលមានវ័យក្មេងមួយក្រុមឡើងលើឡានក្រុង ហើយមន្ត្រីផ្សេងៗទៀតព្យាយាមឃាត់ការ ផលិតកុន ។

វីដេអូនេះក៏បានសរសេរនៅខាងក្រោមអំពីអ្នកជិះអូដពីររូបមកពីប៉ាគីស្ថានដែលមានអាយុប្រាំ និងប្រាំពីរ ឆ្នាំហើយបាននៅក្នុងប្រទេស UAE អស់រយៈពេលពីរឆ្នាំមកហើយ និង ប្រណាំងចំនួន ៤ ដងក្នុងមួយ សប្តាហ៍ ។ កុមារមកពីប្រទេសបង់ក្លាដេសដែលជាអ្នកជិះអូដប្រណាំងនៅ UAE អស់រយៈពេលជិតប្រាំមួយ ឆ្នាំទៅហើយនោះក៏ត្រូវបានសំភាសហើយក៏បានបញ្ជាក់ដែរថាជា" ការងារដ៏អាក្រក់បំផុតនៅលើលោក" ។

ស្ថានទូតប៉ាគីស្ថានបានចេញសេចក្តីប្រកាសពត៌មាននៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣ ដែល ក្នុងនោះបានលើកឡើងថាបានរៀបចំការធ្វើមាតុភូមិនិវត្តន៍កុមារចំនួន ២១ រូបដែលត្រូវគេជួញដូរនៅក្នុង សប្តាហ៍មុននោះ ហើយថាកុមារប៉ាគីស្ថានដែលត្រូវគេជួញដូរចំនួន ៨៦ នាក់ត្រូវបានធ្វើមាតុភូមិវិវត្តន៍កាលពី ឆ្នាំមុន ។

អនុសញ្ញា SAARC នឹងមិនមានឥទ្ធិពលលើការបញ្ចប់ការជួញដូរកុមារពី និង ឆ្លងកាត់រដ្ឋសមាជិក SAARC ដើម្បីធ្វើការងារជាអ្នកជិះអូដប្រណាំងក្នុងប្រទេស UAE ទេ ។ UAE មិនទាន់បានចុះ ហត្ថលេខា ឬ ផ្តល់សច្ចាប័នលើពិធីសារជួញដូរនោះទេ ។

ច្បាប់ដែលមានគុណភាពល្អគឺជាជំហានដ៏សំខាន់ដំបូង តែក៏ត្រូវការអោយមានឆន្ទៈនយោបាយដើម្បី ធានាអោយបានថាច្បាប់ប្រឆាំងការជួញដូរត្រូវបានអនុវត្តដោយត្រឹមត្រូវ ។ ចំនុចនេះគឺនឹងត្រូវការនូវវិធានការ មួយចំនួនដែលអាចរួមបញ្ចូលទាំង : ការបណ្តុះបណ្តាលដល់ភ្នាក់ងារទាំងអស់ដែលពាក់ពន្ធ័ដែលអាចធ្វើការ ងារពាក់ពន្ធ័នឹងជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ (នគរបាល ផ្នែកអន្តោប្រវេសន៍ តុលាការ សេវាសង្គម

[9] Thompson, G. & Grey, K., *Foreign Correspondent,* Australian Broadcasting Corporation, 25 February 2003. Footage was shot between 13 and 25 October 2002.

។ ល។) កំណត់យកការជួញដូរជាកង្វល់អាទិភាពមួយសំរាប់ភ្នាក់ងារដែលពាក់ពន្ធ័ បែងចែងធនធានបន្ថែមដល់បណ្តាភ្នាក់ងារទាំងនេះ វិធានការប្រឆាំងអំពើពុករលួយ និង លើសពីអ្វីៗទាំងអស់នោះគឺការផ្តល់សេវាដើម្បីការពារ និង គាំទ្រដល់ជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ ។

**បរាជ័យនៃការការពារ**

គោលបំណងសំខាន់ក្នុងការជួយដល់មនុស្សដែលទទួលរងការជួញដូរគឺត្រូវជួយពួកគេអោយបានរួចផុតពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ (ឧ. អំពើហឹង្សា ការធ្វើទារុណកម្ម អំរំលោភសេពសន្ថវៈ អំពើរារាំងសេរីភាព ការងារដោយបង្ខិតបង្ខំ ។ល។) និង ធានាអោយបានថាពួកគេនឹងមិនប្រឈមមុខនឹងគ្រោះថ្នាក់បែបនេះតទៅទៀត ។ ពិធីសារអំពីការជួញដូរលើកឡើងក្នុងមាត្រា ៦, ៧ និង ៨ ថាការការពារ និង សេវាកម្មជំនួយចម្បងដែលគួរផ្តល់ជូនដល់ជនរងគ្រោះដោយអំពើជួញដូរ ។ សេវាទាំងនេះរួមមាន :

- សិទ្ធិអនុសញ្ញាតិស្នាក់នៅបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍
- ទីជម្រកសមស្រប
- ពត៌មាន និង ការប្រឹក្សាអប់រំផ្លូវចិត្ត ជាពិសេសអំពីសិទ្ធិផ្លូវច្បាប់
- ជំនួយផ្នែកសុខាភិបាល ផ្លូវចិត្ត និង សំភារៈ
- ឱកាសការងារ ការអប់រំ និង ការបណ្តុះបណ្តាល
- ឱកាសសំរាប់ដំណើរការច្បាប់ និង សំណង
- ផ្តល់នូវសុវត្ថិភាពដល់ជននោះនៅពេលបញ្ជូនគេត្រឡប់មកវិញដែលជាការល្អប្រសិនបើធ្វើឡើងដោយលក្ខខណ្ឌស្ម័គ្រចិត្ត ។

តែគួរអោយសោកស្តាយដោយសារថាចំនុចដែលបានគូសបញ្ជាក់ខាងលើមិនចាប់បង្ខំអោយរដ្ឋធ្វើសច្ចាប័នលើពិធីសារ និង រដ្ឋាភិបាលគ្រាន់តែមានកាតព្វកិច្ច " ពិចារណាអនុវត្ត " ចំនុចទាំងនោះ " ក្នុងករណីសមស្រប " ។ ផលវិបាកបញ្ហានេះគឺថានៅពេលរដ្ឋដាក់បញ្ចូលពិធីសារទៅក្នុងច្បាប់ជាតិ ពួកគេអាចបំបែកដោយសេរី ឬ ធ្វើមិនដឹងមិនឮអំពីការការពារ និង ការគាំទ្រ ឬ ការអាចទទួលបានទាំងអស់នេះដោយមានលក្ខខណ្ឌលើការសហប្រតិបត្តិការជាមួយនឹងនគរបាល ។ នៅពេលដែលមានករណីបែបនេះកើតឡើងគឺវាធ្វើអោយចុះខ្សោយនូវប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រប្រឆាំងការជួញដូររួចទៅហើយ ។

## លក្ខណៈសម្បត្តិនៃតំណាក់កាលឆ្លុះបញ្ចាំង

ជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ គឺកម្រនឹងបញ្ចេញនូវអ្វីដែលបានកើតឡើងចំពោះពួកគេណាស់ នៅពេលដែលជួបជាលើកដំបូងជាមួយនឹងសមត្ថកិច្ច ឬ អង្គការមិនមែនរដ្ឋាភិបាល ។ នេះគឺដោយសារមូលហេតុជាច្រើនរួមទាំង : ការភ័យខ្លាចការសងសឹកពីអ្នកជួញដូរចំពោះរូបគេ ឬ ក្រុមគ្រួសារ ការគ្មានឆន្ទៈដើម្បីពិភាក្សាអំពីអ្វីដែលបានកើតឡើងចំពោះពួកគេដោយសារថាភាពតក់ស្លុត ឬ ភាពអាម៉ាស ការគ្មានទំនុកចិត្តលើសមត្ថកិច្ច ឬ ការភ័យខ្លាចថានឹងត្រូវទទួលរងការចោទប្រកាន់ ឬ បញ្ជូនត្រឡប់ទៅវិញ ។ ដូច្នេះជនដែលត្រូវគេជួញដូរនឹងត្រូវការរយៈពេលសំរាប់ធ្វើការឆ្លុះបញ្ចាំងឡើងវិញ ។ នេះចង់មានន័យថារយៈពេលមួយដែលស្ថានភាពអន្តោប្រវេសន៍របស់គេត្រូវបានគ្រប់គ្រងជាលក្ខណៈបណ្ដោះអាសន្ន[១០] ដើម្បីអាចបញ្ជូនពួកគេទៅទទួលយកប្រឹក្សាយោបល់ និងជំនួយ ជាសះស្បើយពីបទពិសោធន៍របស់គេ និង ធ្វើការសំរេចចិត្តប្រកបដោយពត៏មានគ្រប់គ្រាន់អំពីអ្វីដែលត្រូវធ្វើបន្ទាប់ពីនោះ ។

ផ្អែកលើមូលដ្ឋាននៃការស្រាវជ្រាវរបស់យើងនេះ[១១] អង្គការប្រឆាំងទាសភាពអន្តរជាតិលើកឡើងថា ដំណាក់កាលនៃការឆ្លុះបញ្ចាំងនេះគួរមានរយៈពេលបីខែក្នុងករណីមនុស្សពេញវ័យដូចជាករណីថ្មីៗនេះ នៅក្នុងប្រទេសហូឡង់ និង ប្រាំមួយខែសំរាប់កុមារ ។ តំណាក់កាលឆ្លុះបញ្ចាំងនេះមានផលប្រយោជន៍មួយចំនួនទាំងការការពារជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ និង ការជួយដល់ការចោទប្រកាន់លើអ្នកជួញដូរ :

- វាផ្ដល់ជនរងគ្រោះនូវឱកាសដើម្បីជៀសវាងបាននូវការចាប់បញ្ជូនភ្លាមៗទៅវិញ ចូលក្នុងដៃរបស់អ្នកជួញដូរដោយមិនបញ្ចេញប្រាប់ដល់នគរបាល ឬ មន្ត្រីអន្តោប្រវេសន៍ និង ដាក់ខ្លួនគេ ឬ ក្រុមគ្រួសាររបស់ពួកគេនៅក្នុងស្ថានភាពគ្រោះថ្នាក់ ។

---

10 មនុស្សភាគច្រើនដែលត្រូវគេជួញដូរ មានស្ថានភាពអន្តោប្រវេសន៍មិនធម្មតា ( ដូចជា គ្មានលិខិតឆ្លងដែន ឯកសារក្លែងក្លាយ ទិដ្ឋាការ ហួសកំណត់ ។ល។ ) ហើយអ្នកជួញដូរមនុស្ស ប្រើប្រាស់ ចំនុចទាំងនេះ ជាមធ្យោបាយគ្រប់គ្រងពួកគេ ។

11 Anti-Slavery International, *Human Traffic, Human Rights: Redefining Victim Protection,* London, 2002. របាយការណ៍ពិនិត្យឡើងវិញ ពីច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស និងគោលនយោបាយ នៅ បែលស៊ិក កូឡុំប៊ី អ៊ីតាលី នីជីរីយ៉ា... នីដឺឡែន នីស្សេរីយ៉ា ប៉ូឡូញ ថៃ អុយក្រែន ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក ។ របាយការណ៍មានអនុសាសន៍គោលនយោបាយ ៤៥ និងអាចរកបានពី http://www.antislavery.org/homepage/resources/humantraffichumanrights.htm

- តំណាក់កាលឆ្លុះបញ្ចាំងផ្តល់ពេលវេលាដោយជនរងគ្រោះដោយអំពើជួញដូរដើម្បីវាយតំលៃលើជីវិតរបស់គេ និង ធ្វើការវាយតំលៃសមស្របអំពីគ្រោះថ្នាក់លើពួកគេប្រសិនបើពួកគេសហការជាមួយនឹងនគរបាល ឬ ត្រឡប់ទៅស្រុកកំណើតវិញរួមទាំងថាតើពួកគេអាចត្រូវទទួលរងការជួញដូរឡើងវិញ ឬ ទទួលខុសត្រូវនូវទោសផ្សេងៗពីអ្នកជួញដូរ ។ ទោសទណ្ឌអាចកើតមានឡើងដោយសារអ្នកជួញដូរគិតថាអន្តោប្រវេសន៍ដែលត្រូវគេជួញដូរ អាចសហការជាមួយនឹងសមត្ថកិច្ចអាចជាការព្រមានដល់អ្នកផ្សេងកុំអោយគេចាប់បាន ឬ ស្វែងរកអ្នកជួយ ឬ មិនបានសងប្រាក់ដែលពួកគេជំពាក់អ្នកជួញដូរ ។
- ក្នុងអំឡុងពេលឆ្លុះបញ្ចាំងឡើងវិញ អ្នកជួញដូរមិនរកប្រាក់បាននោះទេពីជននោះហើយទង្វើនេះបន្ថុចបង្អាក់ជំនួញរបស់គេ និង កាត់បន្ថយអំពើចរាចរជួញដូរមនុស្ស ។
- ដំណាក់កាលឆ្លុះបញ្ចាំងមិនជៀតជ្រែកជាមួយនឹងការស៊ើបអង្កេតរបស់នគរបាលទេដោយសារថានគរបាលនៅតែអាចសាកសួរដល់ជន ដែលរងគ្រោះដោយអំពើជួញដូរដែលមានឆន្ទៈចង់សហការជាមួយពួកគេ និង បន្តការស៊ើបអង្កេត ។ ទោះជាបែបនេះក៏ដោយនៅពេលដែលមន្ត្រីជួបជាមួយអ្នកណាម្នាក់ដែលពួកគេគិតថាអាចជាជនរងគ្រោះនៃអំពើចរាចជួញដូរ តែជននោះនឹងមិននិយាយជាមួយពួកគេ អាចមានឱកាសដើម្បីបញ្ជូនពួកគេទៅភ្នាក់ងារដើម្បីទទួលជំនួយ និង ការគាំទ្រ និង លទ្ធភាពដែលពួកគេនឹងសហការជាមួយនឹងនគរបាលនៅពេលក្រោយ ។
- ការគាំទ្រដែលផ្តល់ជូនទាំងនោះចំពោះជនដែលទទួលរងការជួញដូរនឹងមានឱកាសដើម្បីទទួលបាននូវទំនុកចិត្ត និង អាចទទួលបាននូវពត៏មានអំពីវិធីសាស្ត្រដែលអ្នកជួញដូរប្រើប្រាស់ ហើយថាតើមានជនរងគ្រោះផ្សេងទៀតឬទេដែលកំពុងជាប់នៅក្នុងស្ថានភាពនេះ ។ ប្រសិនបើពិធីសារអាចបង្កើតឡើងបានរវាងនគរបាល និង ភ្នាក់ងារដែលជួយដល់ជនអន្តោប្រវេសន៍ដែលទទួលរងការជួញដូរ ពត៏មាននេះអាចចែករំលែក និង អាចជួយដល់នគរបាលក្នុងការប្រមូលភស្តុតាងអំពីអ្នកជួញដូរ ដោះលែងជនអន្តោប្រវេសន៍ដែលផ្សេងៗទៀត កសាងឯកសារចំពោះអ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការជួញដូរ និង បន្ថុចបង្អាក់រចនាសម្ពន្ធ័របស់អ្នកជួញដូរ ។
- បន្ទាប់ពីរយៈពេលនៃការឆ្លុះបញ្ចាំង មនុស្សដែលទទួលរងការជួញដូរនឹងឯកភាពអោយនគរបាលសំភាសដែលអាចផ្តល់អោយពួកគេនូវពត៏មានសំខាន់ៗ ។ ក្នុងករណីខ្លះជនអន្តោប្រវេសន៍ដែល

ត្រូវគេជួញដូរអាចសំរេចចិត្តថាពួកគេមានបំណងនឹងផ្តល់ចំលើយប្រឆាំងនឹងអ្នកជួញដូរដែលទង្វើនេះជួយដល់ការចោទប្រកាន់ផ្តន្ទាទោសប្រកបដោយជោគជ័យ ។

- ប្រសិនបើបន្ទាប់ពីរយៈពេលនៃការឆ្លុះបញ្ចាំងនេះមក ជនដែលគេជួញដូរមានបំណងត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ការរៀបចំនានាអាចធ្វើឡើងលើការវិលត្រឡប់នោះ និង កាត់បន្ថយនូវសភាពគ្រោះថ្នាក់របស់ពួកគេក្នុងការធ្លាក់ចូលក្នុងអំពើជួញដូរសារជាថ្មី ឧទាហរណ៍ដូចជារៀបចំទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលដើម្បីជួបជាមួយនឹងពួកគេ នៅព្រលានយន្តហោះ និង ជួយដល់ពួកគេក្នុងការធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ ។
- ដោយសារថាជនរងគ្រោះដោយអំពើជួញដូរបញ្ចេញរឿងទាំងមូលរបស់ពួកគេ ដោយប្រើពេលវេលាច្រើន ដំណាក់កាលឆ្លុះបញ្ចាំងនឹងជួយអោយអាចជៀសវាងបាននូវស្ថានភាពដែលមិនសមស្រប ឬ ការកត់ត្រាទុកពត៏មានដែលពេញលេញ និង អនុវត្តភ្លាមៗ ។ ភាពមិនស៊ីសង្វាក់ណាមួយដែលអាចរកឃើញប៉ុន្មានសប្តាហ៍ក្រោយមកគឺពិតជាអាចធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ជោគជ័យក្នុងការចោទប្រកាន់ផ្តន្ទាទោសប្រឆាំងនឹងអ្នកជួញដូរ ឬ ពាក្យសុំសិទ្ធិស្នាក់នៅ ។

ទាំងអស់ខាងលើនេះបញ្ជាក់អំពីតថភាពដែលថាគ្មានអ្វីផ្ទុយគ្នានោះទេរវាងការការពារ និង ការគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរ និង ការព្យាយាមផ្តន្ទាទោសអ្នកជួញដូរ ។ ផ្ទុយទៅវិញប្រទេសដែលរៀបចំនូវប្រពន្ធ័ដែលធ្វើឡើងដើម្បីផ្តល់សន្តិសុខអោយជនរងគ្រោះ និង ការជួយជ្រោមជ្រែង ជាពិសេសតាមរយៈតំណាក់កាលនៃការឆ្លុះបញ្ចាំង និង សិទ្ធិស្នាក់នៅដែលមិនក៏រិតលើលក្ខខណ្ឌនៃការផ្តល់កិច្ចសហការក្នុងការចោទប្រកាន់ផ្តន្ទាទោស ឃើញថាជាមធ្យោបាយមួយធ្វើអោយការចោទប្រកាន់ផ្តន្ទាទោសអ្នកជួញដូរមានប្រសិទ្ធិភាព (មើល ២.៤) ។

ទោះបីជាបែបនេះក៏ដោយ រដ្ឋភាគច្រើននៅតែមានការស្ទាក់ស្ទើក្នុងការដាក់បញ្ចូលមាត្រា ៦, ៧ និង ៨ នៃពិធីសារជួញដូរចូលក្នុងច្បាប់ជាតិដែលជាមូលហេតុនៃការបន្តរក្សានូវការធានាលើការផ្តល់ជំនួយ និង ការការពារដល់ជនអន្តោប្រវេសន៍ដែលទទួលរងការជួញដូរនៅមានក៏រិតនៅឡើយ ។



មនុស្សដែលត្រូវគេជួញដូរជាច្រើន ត្រូវបានគេឃុំខ្លួន និងនីរទេស ជាសជាងជួយពួកគេ

**២. ៤ ឧទាហរណ៍ពីប្រទេស អ៊ីតាលី និង ហូឡង់**

នៅក្នុងប្រទេស ហូឡង់ មានរយៈពេលឆ្លុះបញ្ចាំងរយៈពេលបីខែ និង សិទ្ធិអនុញ្ញាតិអោយស្នាក់នៅសំរាប់ជនរងគ្រោះដែលសហការក្នុងដំណើរការតុលាការប្រឆាំងនឹងអ្នកជួញដូរ ។ រវាងឆ្នាំ ១៩៩៥ និង ខែ មិថុនា ឆ្នាំ ២០០០ នគរបាលរៀបចំរបាយការណ៍សំនុំរឿងចំនួន ៧៥៦ ទាក់ទងនឹងករណីជួញដូរដាក់ជូនការិយាល័យអយ្យកា ដែលក្នុងនោះករណីចំនួន ៧១ ភាគរយបន្តទៅសវនាការ ។ ក្នុងចំនួននេះ ៨៨ ភាគរយ (៤៧២ ករណី) បានទទួលការកាត់ទោស ហើយទោសពន្ធនាគារមានចំនួន ៨៥ ភាគរយ ។

នៅក្នុងប្រទេសអ៊ីតាលីឃើញមានការកើនឡើងចំពោះករណីផ្តន្ទាទោសអ្នកជួញដូរក្រោយពីចេញអនុវត្តមាត្រា ៨ នៃច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៩៨ ។ យោងតាមមាត្រា ១៨ គឺអាចផ្តល់សិទ្ធិអនុញ្ញាតិអោយស្នាក់នៅចំនួន ១៨ ខែលើមូលដ្ឋានថាប្រសិនបើជនរងគ្រោះនៃអំពើកេងប្រវ័ញ្ចស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយសារលទ្ធផលនៃការរត់គេចចេញពីស្ថានភាពរបស់គេ ឬ ដោយសារជននេះសហការក្នុងដំណើរការតុលាការ ។

ប្រទេសអ៊ីតាលីកាត់ទោសករណីជួញដូរតាមមាត្រា ៦០០ នៃច្បាប់ព្រហ្មទណ្ឌសំរាប់ការកាត់បន្ថយទាសភាព ។ រវាងឆ្នាំ ១៩៩៧ និង ១៩៩៩ មាត្រា ៦០០ ត្រូវបានអនុវត្តប្រកបដោយជោគជ័យក្នុងករណីចំនួនប្រាំពីរនៅទូទាំងប្រទេស ។ ទោះបីជាមិនទាន់មានស្ថិតិជាតិនៅឡើយសំរាប់មាត្រា ៦០០ ករណីក្រោយពីការចេញមាត្រា ១៨ យើងជឿជាក់ថាការកាត់ទោសនឹងមានការកើនឡើង ។ គ្រាន់តែនៅ មីឡាន មាត្រា ៦០០ ត្រូវបានអនុវត្តនៅក្នុងសវនាការជំនួន ១៤ ក្នុងឆ្នាំ ២០០០ និង ២០០១ ។ នៅ ប៊ូស្ត អាស៊ីស្ស

មាត្រា ៦០០ ត្រូវបានអនុវត្តដើម្បីកាត់ទោសអ្នកជួញដូរចំនួន ៤០ រូបក្នុងសវនាការចំនួន ៧ រួមទាំងក្នុងឆ្នាំ ២០០០ ។ ចៅក្រមព្រហ្មទណ្ឌមួយរូបអះអាងនៅក្នុងកិច្ចសំភាសក្នុងឆ្នាំ ២០០២ ថាគាត់មានជំនឿថាការមាន មាត្រា ១៨ ស្តីអំពីសិទ្ធិស្នាក់នៅបានធ្វើអោយការចោទប្រកាន់មានការកើនឡើង ហើយភាគច្រើនបានសំរេចលទ្ធផលដោយការរកឃើញថាមានទោស[១២] ។

ការឆ្លើយតបរបស់សហគមន៍អឺរ៉ុបចំពោះអំពើជួញដូរបញ្ជាក់ច្បាស់លើចំនុចនេះ ។ ទោះបីជាសហគមន៍អឺរ៉ុប តាមរយៈក្របខណ្ឌនៃសេចក្តីសំរេចរបស់ខ្លួនទទួលស្គាល់ថាកំរិតទោស និង និយមន័យស៊ីសង្វាក់មានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ខ្លួនមិនទាន់ទទួលថាការគាំទ្រ និង ការពារកម្រិតខ្ពស់ដល់ជនរងគ្រោះដោយអំពើជួញដូរមានសារៈសំខាន់ស្មើគ្នានោះទេ ។

សំណើរច្បាប់តែមួយគត់របស់សហគមន៍អឺរ៉ុបរហូតមកដល់ពេលនេះដែលទាក់ទងនឹងការការពារ និង ជួយជនរងគ្រោះគឺសេចក្តីណែនាំរបស់ក្រុមប្រឹក្សាលើការអនុសញ្ញាតិសិទ្ធិស្នាក់នៅរយៈពេលខ្លី ដែលស្នើថា សិទ្ធិស្នាក់នៅនឹងត្រូវចេញអោយតែក្នុងករណីដែលថា " វត្តមានរបស់ជនរងគ្រោះមានសារៈប្រយោជន៍ " ហើយថាពួកគេ" បង្ហាញអំពីចេតនាច្បាស់លាស់ក្នុងការសហការ " ។ សេចក្តីណែនាំនេះក៏បានលើកឡើងដែរថាវា" មិនពាក់ពន្ធ័នឹងការការពារសាក្សី ឬ ជនរងគ្រោះនោះទេ"[១៣] ។

សេចក្តីប្រកាសប្រ៊ូសែល ដែលបានឯកភាពរួមគ្នានៅក្នុងសន្និសីទមួយដែលរៀបចំឡើងដោយសហគមន៍អឺរ៉ុប និង អង្គការអន្តោប្រវេសន៍អន្តរជាតិនៅក្នុងខែ កញ្ញា ឆ្នាំ ២០០២ ពិតជាលើកឡើងអំពីបញ្ហាការការពារ និង ការជួយនេះហើយត្រូវបានអនុម័តថាជាឯកសារផ្លូវការរបស់សហគមន៍អឺរ៉ុបក្នុងឆ្នាំ ២០០៣ ។ សេចក្តីថ្លែងការនេះលើកឡើងថាៈ គួរតែមានមូលនិធិគ្រប់គ្រាន់សំរាប់ទីជម្រកស្នាក់នៅ និង ការជួយដល់ជនរងគ្រោះនៃអំពើជួញដូរ ជនរងគ្រោះដោយអំពើជួញដូរមិនត្រូវទទួលទោសព្រហ្មទណ្ឌ ឬ ឃុំខ្លួនចំពោះបទល្មើសដែលបណ្តាលមកពីខ្លួនត្រូវគេជួញដូរនោះទេ ការបណ្តេញជនរងគ្រោះដោយអំពើជួញដូរភ្លាមជាទូទៅត្រូវតែជៀសវាងអោយបាន ហើយក្រោមលក្ខខណ្ឌមួយចំនួនត្រូវមានការចេញសិទ្ធិអនុញ្ញាតស្នាក់នៅរយៈពេលខ្លី និង ពេលវេលាសំរាប់ឆ្លុះបញ្ចាំងឡើងវិញ ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីថ្លែងប្រកាសនេះមិនមានសុពលភាពផ្លូវច្បាប់ទេហើយការប្តេជ្ញាចិត្តនេះមិនចាប់បង្ខំអោយរដ្ឋសមាជិកអនុវត្តនោះទេ ។

[12] Anti-Slavery International, op.cit.,p.68.
[13] Anti-Slavery International, op.cit.,pp.141-142.

វិធានការដើម្បីចោទប្រកាន់អ្នកជួញដូរ និង ការពារជនរងគ្រោះដោយអំពើជួញដូរជាធាតុផ្សំសំខាន់ក្នុងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ។ ទោះជាបែបណាក៏ដោយយើងត្រូវទទួលស្គាល់ថាគោលនយោបាយទាំងនេះគឺគ្រាន់តែព្យាបាលរោគសញ្ញាតែប៉ុណ្ណោះ តែមិនបានដោះស្រាយបញ្ហានោះទេ ។ ប្រសិនបើរដ្ឋពិតជាចង់ដោះប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សសំរាប់រយៈពេលយូរអង្វែង ពួកគេត្រូវព្យាយាមធ្វើយ៉ាងណាបង្កានូវកាលៈទេសៈដែលកើតមានឡើង ហើយបណ្តាលអោយជនទាំងនោះក្លាយទៅជាជនរងគ្រោះដោយអំពើជួញដូរ ។

ទោះជាយ៉ាងណាក៏ដោយ ផ្នែកនៃការងារបង្កានៃកម្មវិធីប្រឆាំងការជួញដូរជានិច្ចកាលសង្កត់ធ្ងន់លើព្យាយាមធ្វើយ៉ាងណាបំបាក់ទឹកចិត្តជនអន្តោប្រវេសន៍ពីការធ្វើដំណើរទៅបរទេសដើម្បីស្វែងរកការងារធ្វើ ដោយគូសបញ្ជាក់សំខាន់លើគ្រោះថ្នាក់ដែលអាចកើតមានចំពោះពួកគេ ។ ការឃោសនាបែបនេះហាក់ដូចជាមិនមានលទ្ធផលនោះទេនៅពេលដែលតម្រូវការជនអន្តោប្រវេសន៍ជាកម្មករនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍កំពុងមានការកើនឡើង និង ការផ្គត់ផ្គង់ដ៏ខ្លាំងនៃជនអន្តោប្រវេសន៍កម្មករទាំងនោះដែលភាគច្រើនព្រមប្រថុយនឹងគ្រោះថ្នាក់នោះដើម្បីទទួលបានការងារដែលគេយល់ថាជាមធ្យោបាយមួយដើម្បីរស់សំរាប់រូបគេ និង ក្រុមគ្រួសារ[១៤] ។ ប្រសិនបើរដ្ឋាភិបាលមានបំណងចង់បង្កាទប់ស្កាត់អំពើជួញដូរ នោះគឺត្រូវពិនិត្យនិន្នាការអន្តោប្រវេសន៍អន្តរជាតិនាពេលសព្វថ្ងៃនេះឡើងវិញ និង ធ្វើការកែតម្រូវលើគោលនយោបាយដែលមានរួចហើយដែលដើរតួនាទីសំខាន់ក្នុងការបង្កើននូវសេចក្តីត្រូវការរបស់អ្នកជួញដូរ និង អ្នករត់ពន្ធមនុស្ស ។

ជនអន្តោប្រវេសន៍ដែលទើបមកដល់ថ្មី នៅក្នុងមណ្ឌលឃុំឃាំង ប្រទេសអេស្ប៉ាញ



## ៣. ទំនាក់ទំនងនៃការធ្វើអន្តោប្រវេសន៍ – អំពើជួញដូរ

### ទស្សនៈរួមនៃការធ្វើអន្តោប្រវេសន៍អន្តរជាតិ

បើតាមអង្គការការងារអន្តរជាតិ ប៉ាន់ប្រមាណថាមានជនអន្តោប្រវេសន៍ជាកម្មករចំនួន ១២០ លាននាក់ និងសមាជិកក្រុមគ្រួសារនៅក្នុងពិភពលោកយើងនាបច្ចុប្បន្ននេះ ។

រូបភាពនៃការធ្វើអន្តោប្រវេសន៍ចំនួនបីត្រូវបានចាត់ទុកថា ជាចំនុចដែលត្រូវគូសបញ្ជាក់អោយបានច្បាស់ :

១- ការធ្វើអន្តោប្រវេសន៍ដើម្បីហេតុផលការងារមិនត្រឹមតែកើតឡើងពីប្រទេសកំពុងអភិវឌ្ឍន៍ទៅប្រទេសអភិ-វឌ្ឍន៍នោះទេ ។ ជនអន្តោប្រវេសន៍ប្រមាណ៦០ ភាគរយរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍[១៥] ។

២- កម្មករជាស្ត្រីមានចំនួន ៥០ ភាគរយឬលើសពីនេះនៃចំនួនជនអន្តោប្រវេសន៍នៅអាស៊ី និងអាមេរិកឡាទីន ។ ឧទាហរណ៍ស្ត្រីហ្វីលីពីនមានចំនួន ៧០ ភាគរយនៃកម្មករអន្តោប្រវេសន៍នៅបរទេសនៅក្នុងឆ្នាំ ២០០០[១៦] ។

៣- ចំនួនកម្មករជនអន្តោប្រវេសន៍បានកើនឡើងយ៉ាងច្រើនក្នុងប៉ុន្មានកន្លងទៅនេះ ។ បើតាមអង្គការអន្តោប្រវេសន៍អន្តរជាតិ ចំនួនមនុស្សដែលរស់នៅខាងក្រៅប្រទេសរបស់ខ្លួនបានកើនឡើងយ៉ាងខ្លាំងចាប់ពីឆ្នាំ ១៩៨៥ និង ២០០០ ពី ១០៥ លាននាក់ដល់ ១៧៥ លាននាក់[១៧] ។ នេះគឺតំណាងអោយការកើនឡើងចំនួន ៧៥ ភាគរយនៅពេលដែលប្រជាជនពិភពលោកកើនឡើងតែចំនួន ២៦ ភាគរយ ។




វិចិត្រករ អេទីអូភៀន Yitagesu Mergia បានគូររូបអស់រយៈពេលជាង ១០ឆ្នាំ ហើយធ្វើការជាមួយអង្គការមនុស្សធម៌ ។ ការពន្យល់នេះ ជាផ្នែកមួយនៃយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស របស់ អង្គការ IOM

---

[15] International Labour Organization, *Facts on Migration Labour, 2003.*

[16] International Organization for Migration, *World Migration 2003,* Geneva, p. 7.

[17] ទូរលេខនេះ រួមបញ្ចូលទាំងកម្មករ អន្តោប្រវេសន៍អចិន្ត្រៃ ជនភាសខ្លួន និងជនគ្មានទីលំនៅ ប៉ុន្តែមិនបានរួមបញ្ចូលអន្តោប្រវេសន៍ ខុសច្បាប់នោះទេ ។ International Organization for Migration, *World Migration 2003, op.cit.,p.5*

មានហេតុផលមួយចំនួនចំពោះការកើនឡើងនូវចំនួនជនអន្តោប្រវេសន៍កម្មករក្នុងឆ្នាំកន្លងទៅនេះ ដែលយើងអាចសង្ខេបបានដូចតទៅ :

**កត្តាជំរុញ**

- មិនមានឱកាសការងារគ្រប់គ្រាន់រួមបញ្ចូលទាំងលក្ខខណ្ឌរស់នៅជួបការលំបាក កង្វះខាតការអប់រំជាមូលដ្ឋាន និង សុខាភិបាល ។
- ការបែកបាក់នយោបាយ និង បំលាស់ទីសេដ្ឋកិច្ចដែលអាចបណ្តាលមកពីជម្លោះ ការបំផ្លិចបំផ្លាញបរិដ្ឋាន គោលនយោបាយកំណែទម្រង់រចនាសម្ពន្ធ័ ការចាត់ចែងគ្រប់គ្រងសេដ្ឋកិច្ចមិនបានល្អ ។ល។ ទាំងអស់នោះអាចគំរាមគំហែងដល់សមត្ថភាពបុគ្គលក្នុងការមើលថែទាំខ្លួនឯង និង ក្រុមគ្រួសារដោយផ្ទាល់ ឬ ដោយប្រយោលហើយស្ថានភាពបែបនេះឈានដល់កំរិតនៃការមិនមានការធ្វើខ្ពស់ ការចំណាយច្រើនក្នុងជីវភាពប្រចាំថ្ងៃ និង សេវាកម្មសាធារណៈតិចតួច ។
- ការរើសអើង (ភេទ ពូជសាសន៍ ឬ វណ្ណៈ) បក្សពួកនិយម និង អំពើពុករលួយដែលរារាំងដល់ការរីកចំរើនលើការងារ ឬ វិជ្ជាជីវៈ ។
- ការបែកបាក់ក្រុមគ្រួសារ (ជាពិសេសករណីមានជំងឺ ឬ ការស្លាប់ម្តាយ ឬ ឪពុក)ដែលជាធម្មតាជំរុញសមាជិកក្រុមគ្រួសារដែលនៅរស់អោយកូនរបស់គេចេញទៅធ្វើការងារ ឬ រកឱកាសផ្សេងៗទៀត ។

**កត្តាទាក់ទាញ**

- មានឧបសគ្គតិចតួចក្នុងការធ្វើដំណើរ (ឧ. មានការកំរិតតិចជាងមុនលើសេរីភាពផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ការចំណាយតិចតួច និង អាចធ្វើដំណើរបានដោយប្រើរយៈពេលខ្លី និង ងាយស្រួលក្នុងការទទួលបានលិខិតឆ្លងដែន ។ល។)
- មានប្រាក់ខែ និង ជីវភាពរស់នៅខ្ពស់នៅបរទេស មានការងារធ្វើគ្រប់ទីកន្លែង និង ឱកាសក្នុងការពង្រីកវិជ្ជាជីវៈ និង ជំរើសផ្សេងៗទៀតក្នុងការទទួលបានជំនាញបន្ថែម និង ការអប់រំ ។

- មានសហគមន៍ និង ផ្លូវសំរាប់ការធ្វើអន្តោប្រវេសន៍រួចហើយនៅក្នុងបណ្តាប្រទេសផ្សេងៗទៀត និង មានតម្រូវការជនអន្តោប្រវេសន៍កម្មករ ជាមួយនឹងវត្តមានដ៏សកម្មរបស់ភ្នាក់ងារជួល ឬ ទំនាក់ទំនង ដែលចង់ជួយសំរបសំរួលការងារ និង ការធ្វើដំណើរ ។
- មានសេចក្តីសង្ឃឹមច្រើនលើឱកាសនៅក្នុងបណ្តាប្រទេសទាំងនេះដែលត្រូវបានលើកជំរុញបន្ថែមដោយ ប្រពន្ធ័ឃោសនា និង អិនធឺណែត ។



អន្តោប្រវេសន៍ខុសច្បាប់ បានឆ្លងកាត់ រីយ៉ោក្រាន ទៅសហរដ្ឋអាមេរិក តាម ក្បូន ។

**៣. ១ កត្តាជំរុញ និង កត្តាទាក់ទាញក្នុងប្រតិបត្តិការនៃការធ្វើអន្តោប្រវេសន៍ ម៉ិចស៊ិកកូ-សហរដ្ឋអាមេរិក**

ការធ្វើអន្តោប្រវេសន៍របស់ជនជាតិម៉ិចស៊ិកកូចូល សហរ មានសារៈសំខាន់ខ្លាំងណាស់ចំពោះសេដ្ឋកិច្ច នៃប្រទេសទាំងពីរ ។ សហគមន៍ម៉ិចស៊ិកកូ ផ្តល់នូវទឹកប្រាក់ប្រមាណ ៨២.១ កោដដុល្លារ សហរ ក្នុងមួយឆ្នាំដល់ការរីកចំរើននៃផលិតផលក្នុងស្រុក និង ប្រមាណ ៩ កោដដុល្លារត្រូវផ្ញើទៅប្រទេសម៉ិចស៊ិកកូ ដោយជនជាតិម៉ិចស៊ិកកូ ឬ អ្នកដែលមានដើមកំណើតដើមជាម៉ិចស៊ិកកូ ក្នុងឆ្នាំ ២០០១[១៨] ។

តួលេខនេះមិនរាប់បញ្ចូលការធ្វើអន្តោប្រវេសន៍មិនប្រក្រតីរបស់ជនជាតិម៉ិចស៊ិកកូចូលសហរដ្ឋអាមេរិក នោះទេ ។ ប្រមាណជាង ៩០ ភាគរយនៃទិដ្ឋភាពការងារ "អចិន្ត្រៃយ៍ " ដែលផ្អែកលើការធ្វើអន្តោប្រវេសន៍ នេះត្រូវបានផ្តោតសំខាន់លើជនអន្តោប្រវេសន៍ដែលមានជំនាញ និង ការអប់រំល្អ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ។ នេះមានន័យថាមិនមានមធ្យោបាយគ្រប់គ្រាន់សំរាប់ការធ្វើអន្តោប្រវេសន៍ធម្មតាដើម្បីចាប់យកការងារដែលត្រូវការជំនាញតិចតួចនោះទេ ទោះបីជាមានតំរូវការខ្លាំងយ៉ាងណាក៏ដោយនៅសហរដ្ឋអាមេរិក ។ ជាលទ្ធផល ជនអន្តោប្រវេន្តជាច្រើនព្យាយាមឆ្លងព្រំដែនដោយខុសច្បាប់ដើម្បីស្វែងរកការងារធ្វើ ហើយមាន

[18] International Organization for Migration, *World Migration 2003, op. cit.p.148.*

ការប៉ាន់ប្រមាណថាមានជនអន្តោប្រវេសន៍មិនប្រក្រតីទាំងនេះប្រហែល ៤០០០ នាក់បានចូលក្នុងប្រទេស សហរ ដោយជោគជ័យរៀងរាល់ថ្ងៃ[១៩] ។

គ្រោះថ្នាក់ក្នុងការធ្វើអន្តោប្រវេសន៍មិនប្រក្រតីនេះមានសភាពធ្ងន់ធ្ងរណាស់ ។ រវាងឆ្នាំ ១៩៩៨ និង ២០០១ មានជនអន្តោប្រវេសន៍ប្រមាណ ១ ៥០០ នាក់បានស្លាប់នៅពេលកំពុងព្យាយាមឆ្លងព្រំដែន ។ ជារៀងរាល់ឆ្នាំ ជនអន្តោប្រវេសន៍ប្រមាណ ១.៥ លាននាក់ត្រូវបានចាប់ខ្លួននៅព្រំដែន សហរ-ម៉ិចស៊ិកកូ និង ត្រូវចាប់បង្ខំអោយត្រឡប់ទៅផ្ទះវិញ[២០] ។ អ្នកផ្សេងទៀតអាចទៅដល់ សហរ តែត្រូវបង្ខំចិត្តធ្វើការងារដោយការបង្ខិតបង្ខំ ឬ ក្នុងស្ថានភាពប្រកបដោយការកេងប្រវ័ញ្ច ។

ទោះបីជាសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរបែបណាក៏ដោយ ក៏នៅតែមានជនអន្តោប្រវេសន៍ជាច្រើនមានះនូវគ្រោះថ្នាក់នេះនឹងអាយុជីវិតរបស់ពួកគេដើម្បីស្វែងរកការងារធ្វើនៅ សហរ ។ ការពន្យល់អំពីរឿងនេះអាចពិនិត្យឃើញមាននៅត្រង់ថា ជាមធ្យមអន្តោប្រវេសន៍ម៉ិចស៊ិកកូជាកម្មករមួយរូបអាចស្វែងរកការងារបានធ្វើក្នុង សហរ ក្នុងរយៈពេល ០២ សប្តាហ៍ក្រោយការមកដល់របស់គេ[២១] ។ លើពីនេះទៅទៀត ជនអន្តោប្រវេសន៍ម៉ិចស៊ិកកូ រកប្រាក់បានចំនួនប្រាំបួនដងច្រើនជាងអ្វីដែលគេអាចរកបាននៅក្នុងប្រទេសដើមរបស់គេ[២២] ។ជាការពិតណាស់រាល់គោលនយោបាយនៃការធ្វើអន្តោប្រវេសន៍ដែលធ្វើមិនដឹងមិនឮអំពីសេចក្តីត្រូវរបស់ប្រទេសខ្លួននូវកម្មករជនអន្តោប្រវេសន៍ ទោះក្នុងផ្នែកណាក៏ដោយនៃសេដ្ឋកិច្ច គឺជាការលើកទឹកចិត្តជំរុញអោយមានការធ្វើអន្តោប្រវេសន៍មិនប្រក្រតី និង ធ្វើអោយជនអន្តោប្រវេសន៍កម្មករកាន់តែងាយរងគ្រោះថែមទៀតនឹងអំពើកេងប្រវ័ញ្ចដោយនិយោជកដែលមិនល្អ អ្នករត់ពន្ធ និង អ្នកជួញដូរ ។

កំរិតកើនឡើងនៃភាពខុសគ្នាលើទ្រព្យសម្បត្តិនៅក្នុង និង រវាងបណ្តាប្រទេសកំពុងមានការកើនឡើងទំនងក្នុងប្រទេសដែលមានកត្តាជំរុញ និង ប្រទេសដែលមានកត្តាទាក់ទាញហើយនាំអោយមនុស្សជាច្រើនធ្វើការសំរេចចិត្តដើម្បីធ្វើអន្តោប្រវេសន៍ ។ តែរដ្ឋាភិបាលនៃប្រទេសដែលមានការអភិវឌ្ឍន៍ជាទូទៅមានការរារែកក្នុងការទទួលស្គាល់ជាសាធារណៈនូវសេចក្តីត្រូវការរបស់ពួកគេលើពលករអន្តោប្រវេសន៍ដែលមានជំនាញ ឬ មិនមានជំនាញ ។ មិនត្រឹមតែមិនដោះស្រាយនូវប្រតិកម្មនានាដែលបង្កការស្អប់ខ្ពើមចំពោះជនបរទេសប៉ុណ្ណោះ

---

[19] International Migration for Migration, *World Migration 2003, op.cit.,p.150.*
[20] *Ibid,* p.31 and p. 60.
[21] P. Taran and G. Moreno-Fontes Chammartin, *Getting at the Roots: stopping Exploitation of Migrant Workers by Organized Crime,* Perspectives on Labour Migration Vol. 1E, ILO Geneva, 2003, P.5. Quoted in ILO, *Trafficking in Human Beings,* New Approaches to the Problem, Geneva 2003, P.5.
[22] International Organization for Migration, *World Migration 2003, op.cit., p.66.*

ទេ តែថែមទាំងបានទាញយកផលប្រយោជន៍នយោបាយតាមរយៈការជំរុញរៀបចំយ៉ាងណាអោយគោលនយោបាយអន្តោប្រវេសន៍កាន់តែមានលក្ខណៈតានតឹងថែមទៀត ។ គោលនយោបាយបែបនេះគឺបានត្រឹមតែកាត់បន្ថយឱកាសការធ្វើអន្តោប្រវេសន៍ធម្មតា និង ផ្តល់ឱកាសបន្ថែមទៀតដល់អ្នកជួញដូរដើម្បីប្រតិបត្តិការការងាររបស់ពួកគេ ។

ការបង្ខំពលកម្មជនអន្តោប្រវេសន៍ និងគ្រួសាររបស់គេក្នុងប្រទេសប្រេស៊ីល កំពុងធ្វើការជាច្រើនខែដោយគ្មានប្រាក់កំរៃមុនពេល ដែលត្រូវនគបាលចាប់ដោយវាយឆ្មក់ ។ បន្ទាប់ពីនោះ ទើបពួកគេទទួលបានប្រាក់ខែ ។



**តំរូវការកើនឡើងលើកម្មករជាជនអន្តោប្រវេសន៍នៅក្នុងប្រទេសអភិវឌ្ឍន៍**

អត្រាកំណើតទាប និង អត្រាជីវិតវែងមានន័យថាប្រទេសអភិវឌ្ឍន៍ភាគច្រើនមានប្រជាជនចាស់ជរា។ ចំនុចនេះនឹងនាំដល់ការខ្វះការងារ ជំនាញ និង បន្ទុកក្នុងការបង់ពន្ធរបស់ប្រជាជនដែលកំពុងធ្វើការដើម្បីគាំទ្រ និង ផ្តល់ផលប្រយោជន៍សង្គមនានាអោយប្រជាជនផ្សេងៗទៀត ។ អត្រាមនុស្សចាស់ជរាដែលត្រូវការពឹងពាក់ឈានដល់ចំនុចកំពូលហើយនៅក្នុងបណ្តាប្រទេស OECD ជាច្រើនពីអត្រាប្រាំលើម្នាក់ មកបីលើមួយនាក់នៅក្នុងរយៈពេល ១៥ ឆ្នាំទៅមុខទៀតនេះ[២៣] ។ សមាមាត្រនៃមនុស្សពេញវ័យជាង ៦០ នៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ត្រូវគេពិនិត្យឃើញថានឹងមានការកើនឡើងពី ៨ ភាគរយទៅ ១៩ ភាគរយនៅក្នុងឆ្នាំ ២០៥០ ចំណែកចំនួនកុមារនឹងធ្លាក់ចុះមកត្រឹម ១/៣[២៤] ។

ក្នុងន័យនេះប្រសិនបើមិនមានការធ្វើអន្តោប្រវេសន៍ដ៏ច្រើននោះទេប្រជាជនដែលមានអាយុកំពុងធ្វើការងារ (ពី ១៥ ដល់ ៦៥ ឆ្នាំ) នៅក្នុងអឺរ៉ុបខាងលិចត្រូវបានគេប៉ាន់ប្រមាណថានឹងធ្លាក់ប្រមាណ ៨.៥ ភាគរយ (២២.១ លាននាក់) រវាងឆ្នាំ ២០០០ និង ២០២៥ និង ៣៧.២ ភាគរយ (៩៦.៦ លាននាក់) នៅ

---

[23] មានប្រទេសអភិវឌ្ឍន៍ចំនួន៣២ ក្នុងអង្គការសហប្រត្តិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD),International Organization for Migration, *World Migration 2003, op. cit.,p.68.*

[24] United Nation Population Division 2002, *World Population Aging 1950-2050, New York.* Quoted in Bruson Mckinley, Directore General of the MIO, *International Migration and Development-*

ឆ្នាំ ២០៥០ ។ ស្ថានភាពដូចគ្នានេះកើតមានឡើងនៅអឺរ៉ុបកណ្តាល និង ខាងកើត ដែលប្រជាជនមានអាយុធ្វើការងារត្រូវបានគេប៉ាន់ប្រមាណថាធ្លាក់ចុះចំនួន ៩.២ ភាគរយ (ប្រាំបីលាន) រវាងឆ្នាំ ២០០០ និង ២០២៥ និង ៣០.៩ ភាគរយ (២៧ លាននាក់) មុនឆ្នាំ ២០៥០[២៥] ។

បើទោះបីជារដ្ឋាភិបាលអឺរ៉ុបខិតខំជំរុញគោលនយោបាយដើម្បីអោយមនុស្សចូលក្នុងទីផ្សាការងារយ៉ាងក៏ដោយ (ឧ. មិនលើកទឹកចិត្តអោយចូលនិវត្តន៍ឆាប់ពេក ឬ បង្កើនរចនាសម្ព័ន្ធថែរក្សាកុមារ) ក៏នឹងមិនធ្វើអោយមានការផ្លាស់ប្តូរត្រង់ចំនុចជាក់ស្តែងថា សេដ្ឋកិច្ចរបស់គេនឹងកាន់តែមានការពឹងផ្អែកលើកម្មករអន្តោ-ប្រវេសន៍ថែមទៀតនៅពេលអនាគត ។ ដើម្បីធានាបាននូវស្ថេរភាពនៃចំនួនប្រជាជនដែលធ្វើការងារនៅក្នុងប្រទេសសមាជិកសហគមន៍អឺរ៉ុបទាំង ១៥ គឺត្រូវការអោយមានការហូរចូលកម្មករបរទេស និង អ្នកមានជំនាញវិជ្ជាជីវៈប្រមាណ ៦៨ លាន នាក់រវាងឆ្នាំ ២០០៣ និង ២០៥០[២៦] ។

សេចក្តីត្រូវការលើកម្មករជនអន្តោប្រវេសន៍នឹងឆ្លើយតបដោយការធ្វើអន្តោប្រវេសន៍មិនប្រក្រតី វាលែងតែអ្នកធ្វើគោលនយោបាយទទួលស្គាល់ថា វាបំរើផលប្រយោជន៍អោយជាតិរបស់គេក្នុងការសំរបសំរួល និង គ្រប់គ្រងលើដំណើរការនេះ ។ ប្រទេសគោលដៅទទួលផលប្រយោជន៍ពីជនអន្តោប្រវេសន៍ទាំងនេះក្នុងការកសាងសេដ្ឋកិច្ចតាមរយៈការងាររបស់ពួកគេ គំនិតថ្មីៗ និង ការបង់ពន្ធ ។ ប្រសិនបើរចនាសម្ព័ន្ធនៃការធ្វើអន្តោប្រវេសន៍ធម្មតាត្រូវបានប្រើប្រាស់ ជនអន្តោប្រវេសន៍មិនបាច់បាច់ប្រថុយខ្លួនអោយធ្លាក់ទៅក្នុងដៃអ្នករត់ពន្ធ និង អ្នកជួញដូរនោះទេ ហើយនឹងអាចស្ថិតនៅក្នុងស្ថានភាពមួយល្អសំរាប់ការពារសិទ្ធិការងាររបស់ពួកគេនៅក្នុងប្រទេសដែលទទួលពួកគេ ។ រដ្ឋាភិបាលនៅក្នុងប្រទេសកំណើតទាំងនោះក៏អាចគ្រប់គ្រងលើដំណើរការនៃការធ្វើអន្តោប្រវេសន៍ដើម្បីអាចធានាបានថា ការធ្វើអន្តោប្រវេសន៍បែបនេះជួយដល់ការងារកសាងសេដ្ឋកិច្ច និង សង្គមរបស់ប្រទេសកំណើតខ្លួន ។

## សក្តានុពលនៃការបង្កើតឳកាសសំរាប់ការធ្វើអន្តោប្រវេសន៍

ការធ្វើអន្តោប្រវេសន៍ដោយគ្មានការគ្រប់គ្រងអាចមានឥទ្ធិពលអវិជ្ជមានលើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសចំពោះប្រទេសទាំងឡាយណាដែលកំពុងជួបប្រទះបញ្ហាជាច្រើនរួចហើយដូចក្នុងវិស័យ អប់រំ អប់រំមនុស្សចាស់ ចំណីអាហារ និង ការស្លាប់របស់កុមារ ។ ប្រទេសទាំងអស់នេះនឹងប្រឈមមុខក្នុងការបាត់បង់

[25] ការលើកលែងតែមួយគត់ក្នុងប្រទេសអ៊ឺរ៉ុប គឺ ប្រទេសអៀកឡែន និងអាល់បានី. UN population Division. Quoted in International Organization for Migration, *World Migration 2003, op.cit.,p.244.*
[26] International Organization for Migration, *World Migration 2003, op. cit., p. 245.*

អ្នកដែលមានវិជ្ជាជីវៈប្រកបដោយជំនាញភាគច្រើនដោយសារពួកគេនឹងបំពេញបន្ថែមនូវសេចក្តីត្រូវការ ដែលកំពុងមានកង្វះខាតនៅក្នុងប្រទេសអភិវឌ្ឍន៍ និង ត្រូវព្យាយាមកំណត់អោយបានថា ការធ្វើអន្តោប្រវេសន៍ធ្វើឡើងតាមផែនការច្បាស់លាស់ និង ជួយដល់ការអភិវឌ្ឍយូរអង្វែង ។

កម្មវិធីការធ្វើអន្តោប្រវេសន៍ដែលរៀបចំឡើងរួមគ្នារវាងប្រទេសប្រភព និង ប្រទេសគោលដៅអាចធានាបាននូវផលជាវិជ្ជមានអតិបរិមាក្នុងការធ្វើអន្តោប្រវេសន៍ដោយជាមួយគ្នានេះដាក់កំរិតលើការហូរចេញអស់នៃពលករដែលមានជំនាញពីបណ្តាប្រទេសប្រភព (អស់អ្នកចេះដឹង) ។ កម្មវិធីទាំងនេះនឹងលើកទឹកចិត្តអោយការធ្វើអន្តោប្រវេសន៍សំរាប់រយៈពេលខ្លី ហើយក្រោយមកជនអន្តោប្រវេសន៍នោះត្រូវវិលត្រឡប់មកប្រទេសដើមកំណើតវិញ ។ កម្មវិធីអាចរួមបញ្ចូលទាំងការបណ្តុះបណ្តាលដើម្បីលើកកំពស់ជំនាញជនអន្តោប្រវេសន៍ពេលនៅបរទេស និង សំរបសំរួលការចែករំលែកពត៌មាន ទំនាក់ទំនាក់ទំនង និង ជំនាញជាមួយនឹងបុគ្គលិកក្នុងស្រុកនៅពេលពួកគេត្រឡប់មកវិញ ។ កម្មវិធីទាំងនេះក៏ត្រូវមានកិច្ចព្រមព្រៀងអំពីវិធីសាស្ត្រក្នុងការទទួលបានផលមកវិញជាអតិបរិមា ដើម្បីជំរុញអោយមានការអភិវឌ្ឍន៍សំរាប់រយៈពេលយូរអង្វែងនៅក្នុងប្រទេសកំណើតរបស់ខ្លួន ។

## ប្រាក់សន្សំ

ប្រាក់សន្សំគឺជាផ្នែកមួយនៃប្រាក់ដែលជនអន្តោប្រវេសន៍អន្តរជាតិរកបាន ហើយផ្ញើមកប្រទេសកំណើតរបស់គេ ។ ស្ថិតិលើប្រាក់សន្សំនេះជាទូទៅសំដៅលើការផ្ញើដោយផ្លូវការ មានន័យថាចំនួនប្រាក់ដែលផ្ញើតាមរយៈធនាគារ និង ចុះបញ្ជីនៅក្នុងស្ថិតិជាតិ ។

ចំនួនសរុបនៃប្រាក់សន្សំមានការកើនឡើងពីដងរវាងឆ្នាំ ១៩៨៨ និង ១៩៩៩ ។ យោងតាមធនាគារពិភពលោក ប្រាក់ផ្ញើជាផ្លូវការមានការកើនឡើងថែមទៀតពី ៦០ កោដដុល្លារ ទៅ ៨០ កោដដុល្លារ រវាងឆ្នាំ ១៩៩៨ និង ២០០២[២៧] ។ ប្រាក់ផ្ញើក្រៅផ្លូវការ ដែលគេផ្ញើតាមរយៈអ្នកកាន់ប្រពន្ធ័ឯកជន មិត្តភក្រ័ ឬបងប្អូន គឺអាចច្រើនជាងតួលេខផ្លូវការពីពីរទៅបីដង ។[២៨]

ប្រាក់សន្សំនេះបានជួយដល់ការបង្កើនប្រាក់ចំនូលយ៉ាងច្រើនរបស់រដ្ឋ ហើយនឹងអាចមានផលប៉ះពាល់ជាសំខាន់លើសេដ្ឋកិច្ចជាតិ ។ នៅ ប៊ីនីញ ប្រាក់សន្សំនេះជាមធ្យមមានប្រមាណ ៤.៥ ភាគរយនៃផលិតផល

---

[27] World Bank, *Global Development Finance,* April 2003. Quoted in Human Rights Watch, Letter to World Bank President James Woldfensohn, 18 September 2003.

[28] Brunson McKinley, Director General of the IOM, *International Migration and Development-The Potential for a Win-Win-Situation,* presentation at G 77 Panel for Migration and Development. New York, 20 June 2003, p.9.

ក្នុងស្រុក (GDP) រវាងឆ្នាំ ១៩៨០ និង ១៩៩៩[២៩] និង នៅសាធារណៈរដ្ឋ ដូមីនីកែន និង ហុងឌូរ៉ា និង យេមែន ប្រាក់សន្សំនេះមានចំនួន ១៦ ភាគរយនៃ GDP និង នៅ លីសូថូ តួលេខនេះកើនឡើងរហូតដល់ ២៦.៥ ភាគរយ[៣០] ។

ប្រាក់សន្សំនេះអាចធ្វើអោយភាពខុសគ្នាផ្នែកពាណិជ្ជកម្មមានការថយចុះ ជំរុញការរក្សាបាននូវរូបិយបណ្ណ័បរទេស សំរបសំរួលសេវាបំណុល កាត់បន្ថយភាពក្រីក្រ និង អសមភាពលើទ្រព្យសម្បត្តិ និង គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចយូរអង្វែង ។ ក្នុងបណ្ដាប្រទេសដែលមានប្រាក់ចំណូលទាប ជាមធ្យម ប្រាក់សន្សំនេះមានទំហំធំជាងជំនួយអភិវឌ្ឍបរទេស ។ ជាង ២០ ឆ្នាំមកហើយប្រាក់សន្សំផ្លូវការប្រចាំឆ្នាំរបស់ប្រទេសអាហ្វ្រិកមួយចំនួនរួមទាំងប្រទេស ម៉ូរ៉ុកកូ អេហ្ស៊ីប នីហ្សេរីយ៉ា និង ទុយនេស៊ី មានតំលៃច្រើនជាងជំនួយអភិវឌ្ឍន៍បរទេសដែលប្រទេសទាំងអស់នេះទទួលបាន[៣១] ។ នៅ អែលសាវ៉ាដ័រ ប្រាក់សន្សំនេះមានចំនួនច្រើនជាង ៨០ ភាគរយនៃថវិការហូរចូលក្នុងឆ្នាំ ២០០០ ដែលជំនួយអភិវឌ្ឍបរទេស និង ការវិនិយោគផ្ទាល់ពីបរទេសរួមគ្នាមានតិចជាង ២០ ភាគរយ[៣២] ។

ក្រុមគ្រួសារក៏ទទួលបាននូវផលប្រយោជន៍ជាច្រើនផងដែរពីប្រាក់សន្សំនេះដែលជាធម្មតា មានប្រមាណ ៥០ ភាគរយនៃប្រាក់ចំនូលគ្រួសារ ។ នៅក្នុងប្រទេសអាមេរិកឡាទីនជាច្រើន ប្រាក់សន្សំនេះបានបង្កើនដល់ដល់ថវិការបស់ជាប្រជាជនជាមធ្យមចំនួនរវាងពី ប្រាំពីរ ទៅ ១៤ ភាគរយ[៣៣] ។ ប្រាក់នេះអាចប្រើប្រាស់សំរាប់ការចំណាយលើម្ហូបអាហារ ឬ អ្វីៗផ្សេងៗទៀតដូចជាថ្នាំពេទ្យ ។ ឬ ម្យ៉ាងទៀតប្រាក់នេះអាចចំណាយលើផលិតផលដែលផលិតនៅក្នុងស្រុក និង សេវាកម្មនានាដែលជាការទាមទារអោយមានការជំរុញលើតម្រូវការ និង អាចជះឥទ្ធិពលល្អលើសហគមន៍ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល ។

ប្រាក់ចំនូលបន្ថែមដែលបានមកពីប្រាក់សន្សំនេះអាចអោយក្រុមគ្រួសារបញ្ជូនកូនទៅសាលារៀនជាជាងការបញ្ជូនអោយទៅធ្វើការងារ ឬ អាចយកទៅប្រើប្រាស់បម្រើអោយការអប់រំ និង បណ្ដុះបណ្ដាល ។ ប្រាក់សន្សំនេះក៏អាចយកទៅវិនិយោគចាប់ផ្ដើមមុខរបររកស៊ី ឬ ជំនួញ ឬ ដាក់ក្នុងធនាគារដើម្បីទទួលកម្រៃការប្រាក់ ។ ជាការពិតណាស់ ប្រាក់សន្សំគឺជាប្រភពសំខាន់មួយនៃប្រាក់ចំណូលបរទេសសំរាប់សេដ្ឋកិច្ចនៃប្រទេសជាច្រើន ។ ទោះជាយ៉ាងណាក៏ដោយក្នុងន័យថាមានតំរូវការកម្មករអន្តោប្រវេសន៍កើនឡើង វាជាការសំខាន់

---

29 International Organization for Migration, *World Migration 2003, op. cit., p.227.*

30 Bruson McKinley, Director General of the IOM, *International Migration and Development-The Potential for a Win-Win-Situation, op. cit., p.9.*

31 IOM, *Migration Policy Issue, Facts and Figures on International Migration,* No. 2 March 2003, P.2.

32 Bruson McKinley, Director General of the IOM, *Migrants' Remittances in the Americas,* paper delivered during the VIII Regional Conference on Migration in Cancon, Mexico, 29-30 May 2003, p.5.

33 *Ibid.*

ណាស់ដែលត្រូវព្យាយាម និង ធានាអោយបានថាមានប្រាក់សន្សំច្រើនទៀតហូរចូលទៅប្រទេស និង ប្រជាជនដែលត្រូវការប្រាក់នោះ ហើយថាសក្តានុពលក្នុងការអភិវឌ្ឍរយៈពេលយូរអង្វែងអាចសំរេចបាន ។ ការលើកឡើងនូវចំនុចដូចខាងក្រោមនេះនឹងអាចជួយសំរបសំរួលលើការងារនេះ :

- ជនអន្តោប្រវេសន៍ត្រូវការស្ថានភាពជាអ្នកអន្តោប្រវេសន៍ធម្មតានៅក្នុងប្រទេសដែលពួកគេកំពុងធ្វើការងារ បើពុំនោះទេ ពួកគេនឹងទទួលរងនូវការកេងប្រវញ្ច័ដែលជាកត្តាកាត់បន្ថយដល់ឱកាសនៃការសន្សំប្រាក់កាស និង ទីបញ្ចប់មិនមានលទ្ធភាពក្នុងការផ្ញើប្រាក់មកប្រទេសកំណើតរបស់ខ្លួន ។ ជនអន្តោប្រវេសន៍ដែលមានស្ថានភាពធម្មតាក៏ទទួលរងនូវការកេងប្រវញ្ច័ផងដែរ ដូច្នេះត្រូវការចាត់វិធានាការយ៉ាងណាដើម្បីធានាអោយបានថាសិទ្ធិរបស់ពួកគេត្រូវបានការពារដោយច្បាប់ និង ការអនុវត្តជាក់ស្តែង (ឧ. តាមរយៈវិធានការច្បាប់ ពត៌មានមុនការធ្វើអន្តោប្រវេសន៍អំពីសិទ្ធិរបស់គេ និង ការចងធ្វើជាសហជីព ។ល។)
- ជនអន្តោប្រវេសន៍ត្រូវមានលទ្ធភាពប្រើប្រាស់ធនាគារនៅក្នុងប្រទេសដែលខ្លួនរស់នៅដែលនឹងជួយដល់ពួកគេក្នុងការផ្ញើប្រាក់មកប្រទេសរបស់ខ្លួនវិញតាមរយៈមធ្យោបាយណាដែលចំណាយតិច ។ ការធ្វើបែបនេះបាននឹងបញ្ចៀសបាននូវការប្រើប្រាស់សេវាផ្ញើប្រាក់ឯកជនដែលជាធម្មតា យកថ្លៃសេវាច្រើនហួសហេតុពេក ។ នៅអាមេរិកកណ្តាល និង អាមេរិកខាងត្បូងកំរៃសេវានេះជាធម្មតាគឺប្រមាណ ១៣ ភាគរយ និង ជាញឹកញាប់គឺលើពី ២០ ភាគរយ[៣៤] ។ (មើល ៣.២)
- ជំរុញលើកទឹកចិត្តអោយជនអន្តោប្រវេសន៍ទុកប្រាក់សន្សំខ្លះ ឬ ទាំងអស់នៅក្នុងប្រទេសដើមរបស់ខ្លួនជាជាងការដាក់ក្នុងគណនេយ្យនៅបរទេស ។ ដើម្បីអោយអាចដំណើរការនេះបាន ជនអន្តោប្រវេសន៍ត្រូវមានជំនឿជឿជាក់ក្នុងចិត្តថា ផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេសរបស់ខ្លួនមានប្រសិទ្ធិភាពត្រឹមត្រូវ និង អាចជឿទុកចិត្តបានហើយថាប្រាក់សន្សំរបស់គេនឹងមិនប្រឈមមុខនឹងគ្រោះថ្នាក់នោះទេ ។ ប្រសិនបើលលក្ខខណ្ឌនេះអាចធានាបាន ជនអន្តោប្រវេសន៍អាចទទួលយកអត្រាការប្រាក់ទាបបានលើប្រាក់សន្សំរបស់គេដោយសារភាពអាណិតស្រលាញ់ប្រទេសកំណើតខ្លួន ។

[34] De la Grarza and Lowell, *Sending Money Home: Hispanic Remittances and Community Development, Rowman and Littlefield, Oxford, 2002.* Quoted in Brunson McKinley, Migrants' Remittances in the Americas, op. cit., p6. តំលៃនៃប្រាក់ដែលផ្ញើរមកប្រទេសនីការាហ្គ័រ ឡើងដល់ ២៥ភាគរយនៃចំនួនលុយដែលបានផ្ញើរ ។

- រដ្ឋាភិបាលត្រូវការបង្កើតឡើងនូវកម្មវិធីដែលលើកទឹកចិត្តអោយប្រើប្រាស់ប្រាក់សន្សំក្នុងការធ្វើវិនិយោគ និង គម្រោងអភិវឌ្ឍន៍ ។ ឧទាហរណ៍ ការកាត់បន្ថយសេវាផ្ទេរប្រាក់អាចផ្ដល់ជូនដល់ជនអន្តោប្រវេសន៍ប្រសិនបើពួកគេប្រើគណនេយ្យនៅក្នុងធនាគាររបស់ប្រទេសកំណើត ។ រដ្ឋាភិបាលនៃប្រទេសទាំងពីរ-ប្រទេសប្រភព និង ប្រទេសគោលដៅ ក៏អាចជួយដល់គម្រោងអភិវឌ្ឍន៍នេះនូវថវិកាសំរាប់ជាផ្នែកមួយនៃប្រាក់សន្សំជាផ្លូវការ (មើល ៣.២)។
- រដ្ឋាភិបាលត្រូវទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងជនអន្តោប្រវេសន៍ និង សហគមន៍របស់គេដើម្បីស្តាប់អំពីការកង្វល់នានារបស់គេ ជួយដោះស្រាយបញ្ហារបស់គេ និង ធ្វើអោយគេក្លាយទៅជាដៃគូរក្នុងដំណើរការនៃការបង្កើតឡើងនូវគោលនយោបាយជុំវិញបញ្ហាការធ្វើអន្តោប្រវេសន៍ ។ ជនអន្តោប្រវេសន៍មិនត្រូវទទួលការបង្ខិតបង្ខំអោយទទួលយករាល់វិធានការដូចបានលើកឡើងទាំងអស់ខាងលើទេ ។



ក្រុមនេសាទកម្ពុជា ៧៦នាក់ ដែលត្រូវបានគេជួញដូរ នៅមាត់ច្រាំកាប៉ាល់នេសាទថៃ ឃុំឃាំងដោយនាវាជើងទឹកឥណ្ឌូនេស៊ី រងចាំនៅឯមូលដ្ឋានទ័ពនាវាសួរាបាយ៉ា ដើម្បីត្រឡប់មកផ្ទះវិញ ។

កិច្ចព្រមព្រៀងដែលកំណត់អំពីក្របខណ្ឌ័សំរាប់ការធ្វើអន្តោប្រវេសន៍ដោយមានផែនការមានផលប្រយោជន៍ច្បាស់លាស់សំរាប់ប្រទេសបញ្ជូន និង ប្រទេសទទួលជនអន្តោប្រវេសន៍ ។ ប្រទេសទទួលនឹងអាចបំពេញបន្ថែមនូវការខ្វះខាតកម្មករ និង ដោះស្រាយលើបញ្ហាសំពាធប្រជាពលរដ្ឋ ហើយប្រទេសប្រភពអាចបង្កានូវការហូរចេញអស់ប្រជាជន ដែលមានជំនាញតាមរយៈការជំរុញអោយមានការធ្វើអន្តោប្រវេសន៍ដោយមានការគ្រប់គ្រង និង មានលក្ខណៈបណ្តោះអាសន្នសំដៅធ្វើយ៉ាងណាអោយជនអន្តោប្រវេសន៍នាំយកមកវិញនូវជំនាញថ្មី ទំនាក់ទំនង និង ប្រភពធនធានហិរញ្ញវត្ថុដែលអាចជួយជំរុញដល់ការរីកចំរើនសេដ្ឋកិច្ចក្នុងស្រុក ។ គោល

នយោបាយដែលសំរួលដល់ការហូរចូលប្រាក់សន្សំទៅប្រទេសប្រភព និង ការធ្វើអោយទទួលបានផលជាអតិបរិ—មាអាចជួយជំរុញអោយមានការអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចសំរាប់រយៈពេលយូរអង្វែង ។

ទោះបីជាមើលឃើញថា មានឱកាសជាច្រើននៅក្នុងដំណើរការធ្វើអន្តោប្រវេសន៍សំរាប់រាល់បណ្តារដ្ឋចូលរួមពាក់ពន្ធ័ បណ្តាប្រទេសជាច្រើននៅតែបដិសេធន៍មិនទទួលស្គាល់វិសាលភាពដែលថាពួកគេពឹងផ្អែកលើកម្មករអន្តោប្រវេសន៍ ឬ ធានានូវសិទ្ធិរបស់ជនទាំងនេះដូចមានចែងក្នុងច្បាប់ការងារអន្តរជាតិ និង ឯកសារសិទ្ធិមនុស្ស ។

**៣.២ គោលនយោបាយរៀបចំឡើងដើម្បីជំរុញអោយប្រាក់សន្សំទទួលបានផលជាវិជ្ជមានអតិបរិមា**

***ម៉ិចស៊ិចកូ***

រដ្ឋាភិបាលម៉ិចស៊ិចកូបានចេញកម្មវិធីមួយហៅថា " ៣ បក ១ " ដែលស្ថិតនៅក្រោមសហពន្ធ័ រដ្ឋ និង រចនាសម្ពន្ធ័ដឹកនាំក្រុងដើម្បីម្នាក់ៗផ្តល់ប្រាក់ ០១ ដុល្លារសំរាប់បន្ថែមលើប្រាក់សន្សំ ០១ ដុល្លារ ដែលជនអន្តោប្រវេសន៍វិនិយោគនៅក្នុងសហគមន៍ក្នុងប្រទេសដើមរបស់គេ ។ កម្មវិធីប្រភេទនេះលើកទឹកចិត្តអោយជនអន្តោប្រវេសន៍ផ្ញើប្រាក់មកស្រុកដោយសារថាប្រាក់ដែលដាក់បន្ថែមដោយភ្នាក់ងាររដ្ឋាភិបាលនៅគ្រប់កំរិតគឺជាផ្នែកមួយសំខាន់ដែលហូរចូលក្នុងសហគមន៍របស់គេ ។[៣៥]

***សេនេហ្គាល***

ដោយការផ្តល់នូវប្រពន្ធ័ផ្ទេរពិសេសដល់ សេនេហ្គាល តាមរយៈ Banque De L'Habitat du Senegal នៅប៉ារីស ការបញ្ជូនប្រាក់សន្សំតាមផ្លូវការពីប្រទេសបារាំងមានការកើនឡើងយ៉ាងច្រើន ។ នៅក្នុងឆ្នាំ ១៩៩៩ លុយប្រមាណ ២៤ លានដុល្លារត្រូវបានផ្ទេរតាមផ្លូវការទៅប្រទេស សេនេហ្គាលតាមរយៈប្រពន្ធ័នេះ តួលេខនេះតំណាងអោយ ២៦ ភាគរយនៃថវិការសន្សំសរុបចូលប្រទេសនៅក្នុងឆ្នាំនោះ ។[៣៦]

[35] Bruson McKinley, *Migrants' Remittances in the Americas, op. cit., p7.*
[36] International Organization for Migration, *World Migration 2003, op. cit. p. 230.*

ការសហការណ៍យុទ្ធនាការ "សិទ្ធិ "អន្តោប្រវេសន៍ប្រឆាំងនឹងការហូតពន្ធកម្មករក្នុងផ្ទះនៅហុងកុង




## ៤. ការការពារសិទ្ធិជនអន្តោប្រវេសន៍ យន្តការការពារសិទ្ធិអន្តរជាតិ

ជនអន្តោរប្រវេសន៍មិនប្រក្រតីភាគច្រើនងាយនឹងទទួលរងគ្រោះក្នុងការងារ ដែលទទួលការបង្ខិតបង្ខំ និង ការកេងប្រវញ្ច័ តែជនអន្តោប្រវេសន៍ធម្មតាក៏ប្រឈមមុខនឹងការបំពារបំពានសិទ្ធិមនុស្ស និង ការងារផងដែរ ។

សេចក្តីត្រូវការក្នុងការការពារសិទ្ធិរបស់ជនអន្តោប្រវេសន៍ទាំងពីរប្រភេទត្រូវបានទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិដូចជាអនុសញ្ញារបស់អង្គការការងារអន្តរជាតិលេខ ១៤៣ ស្តីអំពីកម្មករអន្តោប្រវេសន៍ ១៩៧៥ និង *អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីអំពីការការពារសិទ្ធិមនុស្សរបស់កម្មករអន្តោប្រវេសន៍ទាំងអស់ និង ក្រុមគ្រួសាររបស់ពួកគេ ១៩៩០ ។* លិខិតតុបករណ៍អន្តរជាតិផ្សេងៗទៀត ទោះបីជាមិនលើកឡើងសង្កត់ធ្ងន់លើជនអន្តោប្រវេសន៍យ៉ាងណាក៏ដោយ ក៏មានបញ្ញត្តិដែលអាចជួយក្នុងការការពារសិទ្ធិកម្មករអន្តោប្រវេសន៍ ។

អនុសញ្ញាពាក់ពន្ធ័មួយចំនួន ត្រូវបានសង្ខេបជូនដូចខាងក្រោមដោយលើកឡើងអំពីនិទស្សន៍សំរាប់ភាពខ្លាំង និង ខ្សោយរបស់គេ ។ ជាការសំខាន់ដែលយើងពិនិត្យមើលលើបទដ្ឋានផ្សេងៗ ដោយសារថាភាគច្រើននឹងមិនទទួលបានសច្ចាប័នពីប្រទេសមួយ ឬ ប្រទេសផ្សេងទៀតនឹងអាចអនុវត្តបានតែលើកម្មករអន្តោប្រវេសន៍មួយចំនួន ឬ អ្នកដែលស្ថិតនៅក្នុងស្ថានភាពពិសេសណាមួយ ។[៣៧]

**អនុសញ្ញាអង្គការការងារអន្តរជាតិលេខ ៩៧ ស្តីអំពីការងារ (បានពិនិត្យឡើងវិញ) ១៩៤៩-សច្ចាប័នមានចំនួន ៤២**[៣៨]

[38] The number of ratifications listed for conventions in this section was correct as of 1 November 2003.

ទោះបីជាអនុសញ្ញានេះមានអាយុប្រមាណជាង ៥០ ឆ្នាំហើយក៏ដោយ ក៏មាត្រាមួយចំនួននៅតែលើកឡើងអំពីបញ្ហាដែលជនអន្តោប្រវេសន៍នៅតែប្រឈមមុខនាពេលបច្ចុប្បន្ននេះ រួមទាំង :

មាត្រា ២: តម្រូវអោយរដ្ឋផ្តល់នូវ " សេវាកម្មគ្រប់គ្រាន់ និង ដោយមិនគិតកម្រៃដើម្បីជួយជនអន្តោប្រវេសន៍ក្នុងការរកការងារធ្វើ" និង" ជាពិសេសត្រូវផ្តល់ជូនពួកគេនូវពត៌មានដែលត្រឹមត្រូវ" ។

មាត្រា ៣: តម្រូវអោយរដ្ឋចាត់ " រាល់វិធានការសមស្របប្រឆាំងនឹងការឃោសនាភូតកុហក់អំពីការធ្វើអន្តោប្រវេសន៍ចេញ និងចូលប្រទេស" ។

មាត្រា ៦: តម្រូវអោយរដ្ឋធានាអោយបានថាជនអន្តោប្រវេសន៍ទាំងអស់ទទួលបាននូវការមើលថែទាំមិនអោយតិចជាងអ្វីដែលជនជាតិរបស់ខ្លួនទទួលបានលើវិស័យមួយចំនួនរួមទាំងកម្រៃទទួលបានពីការងារ លក្ខខណ្ឌការងារ ការស្នាក់នៅ និង សមាជិកភាពក្នុងសហជីព ។

មាត្រា ១០: ក្នុងករណីដែលការធ្វើអន្តោប្រវេសន៍រវាងប្រទេសនោះមានចំនួនច្រើន អាជ្ញាធរមានសមត្ថកិច្ច" នៅពេលចាំបាច់ ឬ តាមការដែលចង់បាន" ត្រូវចុះចូលក្នុងកិច្ចព្រមព្រៀងសំរាប់ការគ្រប់គ្រងលើការងារដែលជាការព្រួយបារម្ភរួមគ្នាទាក់ទងនឹងការអនុវត្តអនុសញ្ញា ។

**លក្ខខណ្ឌកម្រិត :** វិសាលភាពនៃអនុសញ្ញានេះគឺមានការកំរិតក្រោមមាត្រា ១១ ថា " ជនទាំងឡាយណាដែលត្រូវបានទទួលជាប្រក្រតីថាជាជនអន្តោប្រវេសន៍ការងារ " ដូច្នេះគឺនឹងមិនជួយដល់ជនអន្តោ-ប្រវេសន៍មិនប្រក្រតីនោះទេ ។ ដោយសារចំណាស់ និង វិសាលភាពមានកំរិត អនុសញ្ញានេះបានទទួលនូវការផ្តល់សច្ចាប័នតិច គឺមានតែរដ្ឋចំនួន ៤២ តែប៉ុណ្ណោះនៅថ្ងៃទី ១ ខែ វិច្ឆិការ ឆ្នាំ ២០០៣ ។

**អនុសញ្ញាអង្គការការងារអន្តរជាតិលេខ ១៤៣ ស្តីអំពីកម្មករអន្តោរប្រវេសន៍ (បញ្ញាតិបន្ថែម) ១៩៧៥-ទទួលការផ្តល់សច្ចាប័នចំនួន ១៨)**

អនុសញ្ញានេះចែកជាពីរផ្នែក ។ ផ្នែកទីមួយលើកឡើងអំពីការធ្វើអន្តោប្រវេសន៍នៅក្នុងលក្ខខណ្ឌដែលមានការគំរាមគំហែង និង ព្យាយាមកាត់បន្ថយការធ្វើអន្តោប្រវេសន៍មិនប្រក្រតី ព្រមទាំងពង្រីកនូវការការពារមួយចំនួនទៀតដល់ជនអន្តោប្រវេសន៍មិនប្រក្រតី ។ ផ្នែកទីពីរគឺព្យាយាមជំរុញអោយមានឱកាសសម-ភាព និង ការថែទាំដល់កម្មករអន្តោប្រវេសន៍នៅក្នុងស្ថានភាពធម្មតា ។ មាត្រាដែលគួរអោយចាប់អារម្មណ៍មាន :

មាត្រា ១ : តំរូវអោយរដ្ឋ" គោរពសិទ្ធិមនុស្សជាមូលដ្ឋានរបស់កម្មករអន្តោប្រវេសន៍ទាំងអស់" ។

មាត្រា ៣: អោយរដ្ឋទាំងអស់ចាត់វាល់វិធានការចាំបាច់ និង សមស្របដើម្បីបង្ក្រាបចលនាលួចលាក់សំងាត់របស់ជនអន្តោប្រវេសន៍ក្នុងការស្វែងរកការងារ និង ការងារខុសច្បាប់របស់ពួកគេ រួមទាំងវិធានការប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំការធ្វើអន្តោប្រវេសន៍ខុសច្បាប់ ឬ រកការងារធ្វើ ។

មាត្រា ៨: ក្នុងករណីដែលជនអន្តោប្រវេសន៍បានរស់នៅដោយស្របច្បាប់លើដែនដីមួយដើម្បីរកការងារធ្វើ មិនត្រូវចាត់ទុកថាកម្មករអន្តោប្រវេសន៍នោះជាជនខុសច្បាប់ដោយការបាត់បង់ការងាររបស់គាត់នោះទេ ។ កម្មករអន្តោប្រវេសន៍ត្រូវទទួលបាននូវសមភាពជាមួយនឹងជនជាតិខ្លួនលើ "ការធានានូវសន្តិសុខការងារ ការផ្តល់ការងារផ្សេងៗទៀត កម្រៃឧបត្ថម្ភពេលគ្មានការងារ និង ការបណ្តុះបណ្តាលឡើងវិញ ។"

មាត្រា ៩: បើទោះបីជាជនអន្តោប្រវេសន៍មានស្ថានភាពមិនប្រក្រតី ពួកគេត្រូវ " ទទួលបាននូវការថែទាំប្រកបដោយសមភាពសំរាប់រូបគេ និង ក្រុមគ្រួសារលើសិទ្ធិផ្សេងៗដែលទទួលបានពីការងារកន្លងមកដូចជាកម្រៃពីការងារ សន្តិសុខសង្គម និង ផលប្រយោជន៍ផ្សេងៗទៀត " ។ នៅពេលមានជម្លោះកើតចេញពីបញ្ហានេះ កម្មករ ឬ តំណាងណាម្នាក់ត្រូវមានសិទ្ធិលើកឡើងអំពីករណីនេះជូនទៅអាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា ១០: តំរូវអោយរដ្ឋជំរុញ និង ធានា "ឱកាស និង ការថែទាំស្មើគ្នាក្នុងការងារ និង វិជ្ជាជីវៈ សន្តិសុខសង្គម សហជីពពាណិជ្ជកម្ម និង សិទ្ធិផ្នែកវប្បធម៌ ព្រមទាំងសេរីភាពបុគ្គល និង សមូហភាព" ចំពោះជនអន្តោប្រវេសន៍ និង ក្រុមគ្រួសារគេដែលស្របច្បាប់នៅក្នុងដែនដីនោះ ។

មាត្រា ១២: តំរូវអោយរដ្ឋផ្តល់ការអប់រំដល់ជនអន្តោប្រវេសន៍អំពីសិទ្ធិ និង " ផ្តល់នូវជំនួយប្រកបដោយប្រសិទ្ធិភាពដល់កម្មករអន្តោប្រវេសន៍ក្នុងការអនុវត្តសិទ្ធិ និង ការការពាររបស់គេ" ។

**លក្ខខណ្ឌកម្រិត :** អនុសញ្ញានេះបានទទួលការផ្តល់សច្ចាប័នតែ ១៨ ហើយចំនួននេះមិនឃើញមាននៅប្រមាណ ១០ ឆ្នាំចុងក្រោយនេះទេ ។ ហើយម្យ៉ាងទៀត មានតែប្រទេសបីក្នុងចំណោមប្រទេសទាំងនេះទេដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តោប្រវេសន៍ឆ្នាំ ១៩៩០ ។

## អនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីការការពារសិទ្ធិកម្មករអន្តោរប្រវេសន៍ទាំងអស់ និង ក្រុមគ្រួសារ (១៩៩០)-ទទួលបានសច្ចាប័នចំនួន ២៣

អនុសញ្ញាអង្គការសហប្រជាជាតិនេះមានបទដ្ឋានអន្តរជាតិទូលំទូលាយណាស់ ដើម្បីដោះស្រាយបញ្ហាកម្មករអន្តោប្រវេសន៍ ។ អនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៣ ហើយនឹងមានតំណាងឃ្លាំមើលសន្និសញ្ញាដើម្បីពិនិត្យឡើងវិញលើរដ្ឋ ដែលបានផ្តល់សច្ចាប័នហើយបានអនុវត្តបានពេញលេញឬទេ ។ អនុសញ្ញាឆ្នាំ ១៩៩០ ធ្វើឡើងដោយផ្អែកលើគោលការណ៍នៃអនុសញ្ញាអង្គការការងារអន្តរជាតិលេខ

៩៧ និង ១៤៣ និង សេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្សដើម្បីពង្រីកច្បាប់សិទ្ធិមនុស្សដល់កម្មករអន្តោប្រវេសន៍ទាំងអស់ និង ក្រុមគ្រួសាររបស់ពួកគេនៅទូទាំងដំណើរការធ្វើអន្តោប្រវេសន៍ទាំងមូល ។ ហើយក៏មានបំណងផងដែរក្នុងការបង្កា និងលុបបំបាត់ " ការដឹកនាំដោយលួចលាក់ និង ការចរាចរជួញដូរកម្មករអន្តោប្រវេសន៍ " និង ការជួលជនអន្តោប្រវេសន៍អោយធ្វើការងារក្នុងស្ថានភាពមិនប្រក្រតី ។ អនុសញ្ញានេះចែកចេញជាប្រាំបួនផ្នែក ហើយផ្នែកខ្លះត្រូវបានលើកមកបញ្ជាក់ដូចខាងក្រោមនេះ :

**ផ្នែក ១ និង ២:**

ផ្នែកទាំងនេះរួមមាននិយមន័យអំពីកម្មករអន្តោប្រវេសន៍ជា " ជាមនុស្សដែលត្រូវចូលរួម ចូលរួម ឬ បានកំពុងចូលរួមធ្វើសកម្មភាពការងារដោយយកកម្រៃក្នុងរដ្ឋមួយដែលខ្លួនមិនមែនជាប្រជាជននៃរដ្ឋនោះ " (មាត្រា ២) ។ សមាជិកក្រុមគ្រួសារត្រូវបានកំណត់និយមន័យក្នុង (មាត្រា ៤) និង មាត្រាអំពីភាពមិនរើសអើងមានបញ្ចូលក្នុង (មាត្រា ៧) ។



អនុសញ្ញាពលកម្មអន្តរជាតិ លេខ ២៩ (១៩៣០) ការពារ កម្មករអន្តោប្រវេសន៍ជាតិ ពីការបង្ខំពលកម្ម គ្រួសារមួយ ដែលត្រូវបានរួចបំណុល នៅឥណ្ឌា

**ផ្នែក ៣:**

អនុសញ្ញានេះផ្តល់នូវសិទ្ធិមនុស្សជាមូលដ្ឋានទៅរាល់កម្មករអន្តោប្រវេសន៍ទាំងអស់ និង ក្រុមគ្រួសាររបស់ពួកគេដោយមិនគិតអំពីស្ថានភាពប្រក្រតី ឬ មិនប្រក្រតីរបស់ជនអន្តោប្រវេសន៍នៅក្នុងប្រទេសគោលដៅនោះទេ ។ សិទ្ធិនេះរួមទាំង : ការការពារមិនអោយមានការធ្វើទារុណកម្ម (មាត្រា ១០) ការពារមិនអោយមានអំពើទាសភាព ឬ ការងារដោយបង្ខិតបង្ខំ (មាត្រា ១១) សេរីភាពក្នុងការគិត សម្បជញ្ញ និង សាសនា (មាត្រា ១២) សិទ្ធិមិនរំខាន (មាត្រា ១៤) សិទ្ធិទទួលបានសេរីភាព និង សន្តិសុខក្នុងភាពជាមនុស្ស

(មាត្រា ១៦ និង ១៧) ភាពស្មើគ្នាចំពោះមុខច្បាប់ (មាត្រា ១៦ និង ២០) ការការពារប្រឆាំងនឹងការដកហូត ឬ ការបំផ្លាញឯកសារអត្តសញ្ញាណ (មាត្រា ២១) សមភាពក្នុងការទទួលបានការថែទាំដូចជនជាតិខ្លួន លើប្រាក់កម្រៃពីការងារ និង លក្ខខណ្ឌការងារ (មាត្រា ២៥) សិទ្ធិចូលរួមនៅក្នុងសកម្មភាពសហជីពជំនួញ (មាត្រា ២៦) ពត៌មានអំពីសិទ្ធិដែលមានក្នុងអនុសញ្ញា និង សិទ្ធិព្រមទាំងកាតព្វកិច្ចនៅក្នុងប្រទេសដែលពាក់ពន្ធ័ (មាត្រា ៣៣) ។

**ផ្នែកទី ៤:**

អនុសញ្ញាចែងអំពីសិទ្ធិបន្ថែមសំរាប់ជនអន្តោប្រវេសន៍ដែលបានចុះឈ្មោះរួមទាំង : ពត៌មានមុនពេលចូលក្នុងប្រទេសគោលដៅ លក្ខខណ្ឌនៃការទទួលអោយចូល ការស្នាក់នៅ និង ការងារ (មាត្រា ៣៧) សិទ្ធិក្នុងការអវត្តមានពីការងារបណ្តោះអាសន្ន (មាត្រា ៣៨) សិទ្ធិស្មើគ្នានិងជនជាតិនៃប្រទេសនោះក្នុងការទទួលបានការអប់រំ បណ្តុះបណ្តាលជំនាញ និង សេវាសង្គម (មាត្រា ៤៣ និង ៤៥) ការជួបជុំជាមួយនឹងដៃគូ ឬ កូនក្នុងបន្ទុក (មាត្រា ៤៤) ការទទួលបានសិទ្ធិស្មើគ្នានឹងជនជាតិនៃប្រទេសនោះលើការការពារនឹងការបណ្តេញចោល ផលប្រយោជន៍ពេលគ្មានការងារធ្វើ និង ជំរើសលើការងារផ្សេងទៀតប្រសិនបើការងារបច្ចុប្បន្នត្រូវបានបញ្ចប់ (មាត្រា ៥៤) ។

**ផ្នែក ៦:**

អនុសញ្ញាក៏ស្នើឡើងនូវគោលនយោបាយដើម្បីជំរុញការធ្វើអន្តោប្រវេសន៍អន្តរជាតិស្របច្បាប់និងមានសមភាពរួមទាំង: អង្គការគ្រប់គ្រងលើការជួលកម្មករអោយធ្វើការងារនៅបរទេស (មាត្រា ៦៦) កិច្ចសហការរវាងរដ្ឋដើម្បីបង្កាការផ្សព្វផ្សាយពត៌មានភូតកុហក់អំពីការធ្វើអន្តោប្រវេសន៍ និង វិធានការហាមប្រាម និងផ្តន្ទាទោសអ្នកទទួលខុសត្រូវក្នុងការដឹកនាំជនអន្តោប្រវេសន៍ ឬ សំរាប់ការងារណាអោយជនអន្តោប្រវេសន៍ដែលមិនមាននៅក្នុងឯកសារ (មាត្រា ៦៨) និង ធានាអោយបានថាកម្មករអន្តោប្រវេសន៍ និង ក្រុមគ្រួសាររបស់គេនៅក្នុងស្ថានភាពធម្មតាទទួលបាននូវលក្ខខណ្ឌរស់នៅដូចគ្នានឹងអ្វីដែលជនជាតិនៃប្រទេសនោះ ទទួលបានលើ " បទដ្ឋានរស់នៅទូទៅ សុវត្ថិភាព សុខភាព និង គោលការនៃភាពថ្លៃថ្នូរជាមនុស្ស " (មាត្រា ៧០) ។

**លក្ខខណ្ឌកម្រិត :** រហូតមកដល់ពេលនេះអនុសញ្ញាបានទទួលសច្ចាប័នតែពីប្រទេសចំនួន ២៣ ប៉ុណ្ណោះ ហើយប្រទេសទាំងអស់នេះគឺសុទ្ធតែជាប្រទេសបញ្ជូន (អាហ្សង់បៃយ៉ាន់ បីលលីស បូលីវៀ បូស្នៀ និង ហេហ្សេហ្គូវីណា ខេប វើត កូឡុំបី អេក្វាដ័រ អេហ្ស៊ីប អែលសាវ៉ាដ័រ ហ្គាណា កាត់តាម៉ាឡា ហ្គីនៀ ហ្គីហ្ស៊ីស្ថាន ម៉ាលី ម៉ិចស៊ិកកូ ម៉ូរ៉ុកកូ ហ្វីលីពីន សេនេហ្គាល សៃឆែល ស្រីឡាំងកា តាស៊ីកហ្គីស្ថាន យូហ្គង់ដា និង យូរ៉ាហ្គាយ ) ។

## អនុសញ្ញាអង្គការការងារអន្តរជាតិលេខ ២៩ ស្តីអំពីការបង្ខិតបង្ខំអោយធ្វើការងារ ១៩៣០- មានសច្ចាប័នពី ១៦៣ ប្រទេស

អនុសញ្ញាអង្គការការងារអន្តរជាតិលេខ ២៩ ទទួលបាននូវការផ្តល់សច្ចាប័នច្រើន ហើយជាអនុសញ្ញាសិទ្ធិមនុស្សមូលដ្ឋានរបស់អង្គការការងារអន្តរជាតិមួយ ដែលតម្រូវអោយរដ្ឋសមាជិកអង្គការនេះអនុវត្តតាមបើទោះបីជាមិនទាន់បានផ្តល់សច្ចាប័នក៏ដោយ ។ អនុសញ្ញានេះអាចជួយដល់កម្មករអន្តោប្រវេសន៍ទាំងឡាយណាដែលកំពុងធ្វើការងារ ឬ ផ្តល់សេវាដែលប្រឆាំងនឹងឆន្ទៈរបស់គេដោយសារថាត្រូវទទួលការបង្ខិតបង្ខំ ឬ គំរាមកំហែងដោយរូបភាពនៃការដាក់ទណ្ឌកម្មណាមួយ ប្រសិនបើគេមិនគោរពតាម ។ និយម័យន័យនៃការងារដោយបង្ខិតបង្ខំត្រូវបានបកស្រាយយ៉ាងទូលំទូលាយដោយជំនាញការគណកម្មាធិការអង្គការការងារអន្តរជាតិ និង បានអនុវត្តចំពោះពលករដែលជាប់បំណុល និង ជនដែលត្រូវបានគេជួញដូរកន្លងមក ។ ជំពូកនានានៅក្នុងអនុសញ្ញានេះដែលមានការពាក់ព័ន្ធជាពិសេសរួមទាំង :

មាត្រា ១: តំរូវអោយរដ្ឋដែលផ្តល់សច្ចាប័នទាំងអស់ " បង្រ្កាបលើការបង្ខំអោយធ្វើការលើគ្រប់រូបភាពនៅក្នុងរយៈពេលដ៏ខ្លីបំផុត" ។

មាត្រា ២: កំណត់និយមន័យលើការងារបង្ខិតបង្ខំថា " រាល់ការងារ ឬ សេវាទាំងអស់ដែលធ្វើដោយជនណាម្នាក់ក្រោយមកការគំរាមកំហែងដាក់ទោសទណ្ឌណាមួយ ហើយដោយសារមូលហេតុនេះធ្វើអោយជននោះមិនបានផ្តល់ការឯកភាពរបស់ខ្លួនដោយស្ម័គ្រចិត្តនោះទេ " ។ ក៏មានការលើកឡើងអំពីករណីលើកលែងផងដែរ ។

មាត្រា ២៥: កត់សំគាល់ថាការប្រើប្រាស់ការធ្វើការងារដោយបង្ខិតបង្ខំត្រូវមានទោសជាបទល្មើសព្រហ្មទណ្ឌហើយរដ្ឋាភិបាលមានកាតព្វកិច្ច "ធានាអោយបានថាកំរិតទោសដែលបានកំណត់ដោយច្បាប់គឺពិតជាសមស្រប និង អនុវត្តបានត្រឹមត្រូវ" ។

**លក្ខខណ្ឌកំរិត:** អនុសញ្ញានេះនឹងមិនក្តោបរាល់ជនអន្តោប្រវេសន៍ទាំងអស់ដែលត្រូវគេគាបសង្កត់កេងប្រវញ្ច័នោះទេដោយសារថាវាអនុវត្តតែចំពោះអ្នកដែលធ្វើការងារផ្ទុយអំពីឆន្ទៈរបស់ និង ក្រោមការគំរាមកំហែងដោយរូបភាពដាក់ទារុណកម្ម ឬ ទោសណាមួយ ។



រូបភាពទាំងនេះ បានមកពី ការប្រត្តិបត្ត ដើម្បីសេរីភាពពលកម្ម ក្នុងខែ ធ្នូ ២០០១ ពីកន្លែងក្នុង អាម៉ាស្សូន ប្រទេសប្រេស៊ីល ។

**ពិធីសារអង្គការសហប្រជាជាតិដើម្បីបង្កា បង្ក្រាប និង ផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារ បន្ថែមលើអនុសញ្ញាស្តីអំពីបទឧក្រិដ្ឋឆ្លងដែន ខែ វិច្ឆិកា ឆ្នាំ ២០០០ (ពិធីសារជួញដូរ) ទទួលសច្ចាប័នចំនួន ៤៤**

ពិធីសារជួញដូរគឺជាបទដ្ឋានអន្តរជាតិសំខាន់មួយសំរាប់ដោះស្រាយអំពើចរាចរជួញដូរមនុស្ស ។ ពិធីសារនេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋចំនួន ៤៤ (ចុះហត្ថលេខាដោយរដ្ឋចំនួន ១៧៧) គិតមកដល់ថ្ងៃទី ១ ខែ វិច្ឆិកា ២០០៣ និង ចូលជាធរមាននៅចុងឆ្នាំ ២០០៣ ។ នៅក្នុងនិយមន័យរួមនៃពិធីសារនេះ

កម្មករអន្តោប្រវេសន៍ជាច្រើននឹងជាអ្នករងគ្រោះដោយអំពើជួញដូរ ហើយអាចទទួលបានផលប្រយោជន៍ពីវិធានការដែលមានចែងនៅក្នុងពិធីសារនេះ ។ មាត្រាដែលគួរអោយកត់សំគាល់មួយចំនួនមាន :

មាត្រា ៣: និយមន័យការជួញដូរ ។ និយមន័យនេះសង្កត់ធ្ងន់ថា មនុស្សម្នាក់នឹងត្រូវចាត់ទុកថាទទួលរងការជួញដូរ នៅពេលមានការបង្ខិតបង្ខំ គំរាមគំហែង ឆបោក ឬ បំពានអំណាចកើតឡើងដោយមិនចាំបាច់គិតថាតើជននោះបានឯកភាព ឬ មិនបានឯកភាពនឹងអំពើកេងប្រវញ្ចនេះ ។ លើសពីនេះទៅទៀត ការជួល ការដឹកជញ្ជូន ការផ្ទេរ ឬ ការលាក់ទុក ឬ ការទទួលក្មេង (ក្រោម ១៨) សំរាប់គោលបំណងកេងប្រវញ្ចនឹងត្រូវចាត់ទុកថាជាការជួញដូរ ។

មាត្រា ៦ និង ៧: គួសបញ្ជាក់អំពីវិធានការជួយ និង ការពារ (រួមទាំងទីជម្រក ជំនួយសង្គម ការថែរទាំសុខភាព ប្រឹក្សាយោបល់ផ្លូវច្បាប់ និង សិទ្ធិអនុញ្ញាតិបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ដើម្បីធ្វើអោយស្ថានភាពអន្តោប្រវេសន៍របស់គេមានលក្ខណៈធម្មតា) ដែលត្រូវធ្វើយ៉ាងណាអោយមានសំរាប់ជនរងគ្រោះដោយអំពើជួញដូរ" ដោយក្នុងករណីសមស្រប និង តាមលទ្ធភាពជាក់ស្តែងនៃច្បាប់របស់ប្រទេស" ។

មាត្រា ៨: ប្រទេសប្រភពនឹងសំរបសំរួលដល់ការវិលត្រឡប់របស់ជននោះប្រកបដោយសុវត្ថិភាពដោយសង្កត់ធ្ងន់លើសុវត្ថិភាពរបស់គេ ។ ប្រទេសគោលដៅនឹងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរអោយបានសមស្របដោយគិតគូសំខាន់លើសុវត្ថិភាពរបស់ជននោះ និង នីតិវិធីច្បាប់ដែលទាក់ទងនឹងការជួញដូរពួកគេ ។ ការបញ្ជូនត្រឡប់មកវិញនេះ"គួធ្វើឡើងក្រោមគោលការណ៍ស្ម័គ្រចិត្ត" ។

មាត្រា ៩: កំណត់តារាងវិធានការដែលត្រូវអនុវត្តដើម្បីបង្កាការជួញដូររួមទាំងការការពារជនរងគ្រោះដោយអំពើជួញដូរ និង វិធានការដើម្បីដោះស្រាយ" ភាពក្រីក្រ ភាពគ្មានការអភិវឌ្ឍ និង ការខ្វះឱកាសស្មើគ្នា" ដែលធ្វើអោយមនុស្សងាយទទួលរងគ្រោះដោយអំពើជួញដូរ ។

មាត្រា ១០: ស្នើសុំអោយមានការផ្លាស់ប្តូរពត៌មានរវាងរដ្ឋ និង ភ្នាក់ងារអនុវត្តច្បាប់ មន្ត្រីអន្តោប្រវេសន៍ និងមន្ត្រីដែលពាក់ពន្ធ័ផ្សេងៗទៀត ។ ការបណ្តុះបណ្តាលត្រូវផ្តោតសំខាន់លើការងារបង្កាអំពើជួញដូរ និង ការការពារជនរងគ្រោះព្រមទាំងសិទ្ធិរបស់ពួកគេ ។ ការបណ្តុះបណ្តាលក៏ត្រូវពិចារណាទៅលើបញ្ហាសិទ្ធិមនុស្ស និង ចាប់អារម្មណ៍លើកុមារ និង ភេទ ព្រមទាំងគួរលើកទឹកចិត្តអោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និង អង្គការដែលពាក់ពន្ធ័ផ្សេងៗទៀត ។

មាត្រា ១៤: សង្កត់ធ្ងន់ថាមិនមានអ្វីនៅក្នុងពិធីសារដែលក៏រិតដល់សិទ្ធិ និង កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិនោះទេ ជាពិសេសទាក់ទងនឹងអនុសញ្ញាឆ្នាំ ១៩៥១ ស្តីអំពីស្ថានភាពរបស់ជនភៀសខ្លួន និង គោលការមិនបញ្ជូនត្រឡប់អោយទទួលរងទោស ។

**លក្ខខណ្ឌកំរិត:** សារធាតុនៃការបង្ការការពារ និង គាំទ្រមិនចាប់បង្ខំដល់រដ្ឋដែលបានផ្តល់សច្ចាប័នរួច ហើយនោះទេ ។ លើសពីនេះទៅទៀតប្រសិទ្ធភាពនៃការការពារដែលបានផ្តល់នឹងអាស្រ័យដោយការធានាបាន ថា រាល់អង្គការ និង មន្ត្រីទាំងអស់ពិតជានឹងបញ្ជូនជនទាំងឡាយណាដែលគេគិតថាទទួលរងអំពើជួញដូរទៅ ភ្នាក់ងារដែលពាក់ពន្ធ័ដើម្បីទទួលការប្រឹក្សាយោបល់ និង ជំនួយផ្សេងៗ ដោយមិនគិតអំពីឆន្ទៈរបស់ពួកគេថា នឹងសហការ ឬ មិនសហការក្នុងដំណើរការក្តី ឬ ស្ថានភាពអន្តោប្រវេសន៍មិនប្រក្រតីរបស់ពួកគេ ។

## អនុសញ្ញាអង្គការសហប្រជាជាតិទាក់ទងនឹងស្ថានភាពជនភៀសខ្លួន ឆ្នាំ ១៩៥១-សច្ចាប័នចំនួន ១៣១ ប្រទេស

អនុសញ្ញានេះ(ដែលតទៅហៅថាអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១)ផ្តល់ការការពារដល់មនុស្សដែល ប្រឈមមុខនឹងការគំរាមសំលាប់ ប្រសិនបើបញ្ជូនទៅប្រទេសដើមកំណើតរបស់ខ្លួន ។ ជំពូកដែលមានការ ពាក់ពន្ធ័នៅក្នុងអនុសញ្ញានេះរួមមាន :

មាត្រា ១: និយមន័យជនភៀសខ្លួនគឺជនណាម្នាក់ " ដែលទទួរងការភ័យខ្លាចការគំរាមសម្លាប់ដោយ សារមូលហេតុ ពូជសាសន៍ សាសនា ជាតិសាសន៍ សមាជិកភាពនៅក្នុងក្រុមសង្គម ឬ មតិនយោបាយ ស្ថិត នៅខាងក្រៅប្រទេសកំណើតរបស់ខ្លួន ហើយដោយសារការភ័យខ្លាចនេះ មិនអាច ឬ មិនមានបំណងដាក់ខ្លួន ក្រោមការការពារដោយប្រទេសនោះ" ។

មាត្រា ៣១: កត់សំគាល់ថារដ្ឋមិនត្រូវដាក់ទោសលើជនភៀសខ្លួនដែលស្ថិតនៅក្នុងប្រទេសរបស់គេ ដោយខុសច្បាប់ ក្នុងករណីដែលពួកគេបានចេញមកពីដែនដីដែលគំរាមកំហែងដល់អាយុជីវិត និង សេរីភាព របស់ពួកគេ និង បានចូលខ្លួនទៅចំពោះមុខសមត្ថកិច្ចដោយមិនបង្អង់ និង មានហេតុផលល្អដើម្បីស្ថិតនៅក្នុង ប្រទេសនោះដោយមិនចាំបាច់មានការអនុញ្ញាតិ ។

មាត្រា ៣៣: ហាមដល់ការបណ្តេញចេញ ឬ ការបញ្ជូនជនភៀសខ្លួនត្រឡប់ទៅកន្លែងដែលអាយុជី វិត និង សេរីភាពរបស់ពួកគេនឹងទទួលការគំរាមកំហែងដោយសារពូជសាសន៍ សាសនា ជនជាតិ សមាជិក ភាពនៃក្រុមសង្គមមួយ ឬ មតិនយោបាយរបស់គេ ។

**លក្ខខណ្ឌកំរិត:** អនុសញ្ញានេះកំរិតលើការផ្តល់ជូននូវស្ថានភាពជាជនភៀសខ្លួនតែចំពោះអ្នកដែលអាច បង្ហាញថារូបគេនឹងប្រឈមមុខនឹងការគំរាមសំលាប់ដែលជាមូលដ្ឋានមួយ ក្នុងចំណោមមូលដ្ឋានផ្សេងៗទៀត កំណត់នៅក្នុងអនុសញ្ញា ។ ដូច្នេះគឺមិនក្តោបលើមនុស្សដែលអាយុជីវិតរបស់ពួកគេអាចប្រឈមមុខនឹងគ្រោះ

ថ្នាក់ដោយសារស្ថានភាពហឹង្សាទូទៅ ឬ អំពើចលាចល ឬ ក៏ពិចារណាលើរដ្ឋាភិបាលនៃប្រទេសនោះអាចផ្តល់នូវការការពារមានប្រសិទ្ធភាពប្រឆាំងនឹងការគំរាមកំហែងសម្លាប់ដែលបុគ្គលនោះមានការភ័យខ្លាច ។ ជនអន្តោប្រវេសន៍ដែលទទួលរងការជួញដូរមួយចំនួនបានទទួលការការពារតាមអនុសញ្ញានេះ ឬ ការធានាអ្វីផ្សេងទៀតក្នុងក្របខណ្ឌជាការការពារ (មើល ៩.១) ។

**៩.១ ការការពារសំរាប់ជនអន្តោប្រវេសន៍ដែលត្រូវគេជួញដូរនៅក្នុងប្រទេសចក្រភពអង់គ្លេសក្រោមអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ និង អនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស (ECHR) ឆ្នាំ ១៩៥០**[៣៩]

ជនអន្តោប្រវេសន៍ដែលបានរត់គេចចេញពីអ្នកជួញដូររបស់គេអាចប្រឈមមុខនឹងការជួញដូរសារជាថ្មីប្រសិនបើពួកគេត្រឡប់ទៅប្រទេសកំណើតវិញ ឬ ទទួលរងនូវទារុណកម្មផ្សេងៗពីអ្នកជួញដូរ ។ សភាពគ្រោះថ្នាក់ដែលពួកគេអាចប្រឈមមុខអាចឈានដល់ការគំរាមសំលាប់ ប្រសិនបើមិនមានការការពារគ្រប់គ្រាន់របស់រដ្ឋ ហើយពួកគេអាចគ្រប់លក្ខណៈសម្បត្តិនឹងទទួលបាននូវស្ថានភាពជាជនភៀសខ្លួន ឬ ការការពារក្រោមរូបភាពណាមួយផ្សេងៗទៀតសំរាប់រយៈពេលយូរអង្វែងនៅក្នុងប្រទេសគោលដៅ ។ ខាងក្រោមនេះគឺជាឧទាហរណ៍សង្ខេបអំពីការប្តេជ្ញាចិត្តរបស់ចក្រភពអង់គ្លេសទាក់ទងនឹងជនរងគ្រោះដោយអំពើជួញដូរ ។

**សេចក្តីសំរេចរបស់តុលាការសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ រដ្ឋលេខាធិការក្រសួងកិច្ចការក្នុងប្រទេស និង Dzhygun (00TH00728) ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០០**

ករណីនេះពាក់ពន្ធ័នឹងស្ត្រីមួយរូបមកពីប្រទេស អ៊ុយគ្រែន ដែលត្រូវបានគេជួញដូរទៅបរទេស និងបង្ខំអោយធ្វើពេស្យាចា ។ តុលាការបានរកឃើញថាស្ត្រីរងគ្រោះនោះមានសិទ្ធិទទួលបាននូវការការពារតាមរយៈអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ ក្នុងនាមជាសមាជិកម្នាក់នៃក្រុមសង្គមមួយដែលមានឈ្មោះថា " ស្ត្រីនៅក្នុងប្រទេស អ៊ុនគ្រែន ដែលត្រូវបានទទួលការបង្ខិតបង្ខំអោយធ្វើជាពេស្យាចាប្រឆាំងនឹងឆន្ទៈរបស់នាង " ។ តុលាការក៏បានសំរេចដែរថាសមត្ថកិច្ចនៅក្នុងប្រទេសអ៊ុយគ្រែនផ្តល់ជូននូវការការពារគ្រប់គ្រាន់ដល់ស្ត្រីម្នាក់នេះបាននោះទេ ។

**សេចក្តីសំរេចរបស់សមត្ថកិច្ចសាលាឧទ្ធរណ៍អន្តោប្រវេសន៍** Josephine Ogbeide **និង រដ្ឋលេខាធិការទទួលបន្ទុកការងារក្នុងប្រទេស** (HX/08391/2002 ) **នៅថ្ងៃទី ១០ ខែ ឧសភា ២០០២**

---

39 The protection offered by the European Convention on Human Rights (ECHR) is extended to all migrants in the UK through the Human Rights Act, 2000 and they should not be removed from the UK if this would lead to a violence of their rights under the ECHR.

ករណីនេះពាក់ពន្ធ័នឹងក្មេងស្រីជនជាតិ នេហ្សេរីយ៉ា ម្នាក់អាយុ ១៦ ឆ្នាំដែលត្រូវបានគេជួញដូរទៅប្រទេសអង់គ្លេសដើម្បីធ្វើជាពេស្យាចា ។ ចៅក្រមកាត់សេចក្តីកំណត់ថានាងស្ថិតនៅក្នុងក្រុមពិសេសមួយរបស់សង្គមនៃក្មេងស្រីមកពីប្រទេស នេហ្សេរីយ៉ា ដែលមានស្ថានភាពសេដ្ឋកិច្ចក្រីក្រ ។ គាត់ក៏បានរកឃើញដែរថាប្រសិនបើបញ្ជូននាងត្រឡប់ទៅវិញ នាងនឹងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរដោយសារថានាងនឹងអាចរងគ្រោះដោយអំពើរជួញដូរម្តងទៀត ឬ ចាប់បង្ខំអោយធ្វើជាពេស្យានៅក្នុងប្រទេស នេហ្សេរីយ៉ា ព្រោះថាអ្នកជួញដូរនឹងចង់រកប្រាក់ដើម្បីសងដើមដែលគេចំណាយលើរូបនាង ។ ដោយមូលដ្ឋាននេះចៅក្រមបានសំរេចអោយនាងទទួលបានការការពារតាមរយៈអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ និង តាមមាត្រា ៣ (សេរីភាពពីការធ្វើទារុណកម្ម) នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស (ECHR) ។

**សេចក្តីសំរេចរបស់សមត្ថកិច្ចសាលាឧទ្ធរណ៍អន្តោប្រវេសន៍ កញ្ញាAB និង រដ្ឋលេខាធិការទទួលបន្ទុកការងារក្នុងប្រទេស** (CC/64057/2002) **នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៣**

ករណីនេះពាក់ពន្ធ័នឹងកុមារីជនជាតិនេហ្សេរីយ៉ាអាយុ ១៦ ឆ្នាំដែលត្រូវបានគេជួញដូរចូលទៅប្រទេសអូស្ត្រាលីដើម្បីធ្វើជាពេស្យាចា ។ ចៅក្រមរកឃើញថាស្ត្រីនេះជាផ្នែកមួយនៃ " ក្រុមកុមារីពិសេសមួយដែលមានឯកសារកត់ត្រាច្បាស់លាស់ហើយត្រូវបានគេជួញដូរអាហ្វ្រិកខាងលិច " និង ថាប្រសិនបើវិលត្រឡប់ទៅនេហ្សេរីយ៉ា វិញមានគ្រោះថ្នាក់មួយថានឹងត្រូវទទួលរងនូវការជួញដូរសារជាថ្មី ។ ដោយសារមូលដ្ឋានទាំងអស់នេះ ចៅក្រមបានសំរេចផ្តល់ការការពារដល់នាងតាមអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ និង តាមមាត្រា ៣, ៤ និង ៨ នៃ ECHR ដែលទាក់សេរីភាពពីការគេចផុតពីការធ្វើទារុណកម្ម អំពើទាសភាព ការងារដោយបង្ខិតបង្ខំ និង សិទ្ធិមិនទទួលការរំខានលើជីវិតផ្ទាល់ខ្លួន និង គ្រួសារ ។

**សេចក្តីសំរេចរបស់សមត្ថកិច្ចសាលាឧទ្ធរណ៍អន្តោប្រវេសន៍ រវាង** A **និង រដ្ឋលេខាធិការទទួលបន្ទុកការងារក្នុងប្រទេស** (CC/63673/2002) **នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៣**

ករណីនេះទាក់ទងនឹងស្ត្រីជនជាតិ អាល់បែនីដែលត្រូវបានគេជួញដូរចូលប្រទេសអង់គ្លេស និង បង្ខំអោយធ្វើពេស្យាចា ។ បើទោះបីថាចៅក្រមបោះចោលភស្តុតាងថាជាស្ត្រីដែលគេជួញដូរ និង ភស្តុតាងភាគច្រើនដែលតតីយភាគីផ្តល់ជូនលើមូលដ្ឋានថា " ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់ទទួលរងនូវអំពើឆបោក " គាត់នៅតែផ្តល់ជូននូវការការពារដោយផ្អែកលើមូលដ្ឋានសិទ្ធិមនុស្ស (មាត្រា ៣ នៃ ECHR)។ គាត់បានរកឃើញថា " នគរបាលមិនអាចការពារដើមបណ្តឹងឧទ្ធរណ៍នៅក្នុងប្រទេស អាល់បែនី ពីក្រុមម៉ាហ្វីបាននោះទេប្រសិនបើនាងរស់នៅជាមួយក្រុមគ្រួសាររបស់នាង " ហើយស្ថានភាពរីកវរខាងក្នុងប្រទេសអាល់បែនីមិនមែនជាជំរើសល្អ

ហើយថាអាចនាំអោយមានអំពើគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះនាងនៅក្នុងប្រទេស អាល់បែនីប្រសិនបើត្រឡប់ទៅវិញ ។

**សេចក្តីសំរេចរបស់សមត្ថកិច្ចសាលាឧទ្ធរណ៍អន្តោប្រវេសន៍ រវាង រដ្ឋលេខាធិការទទួលបន្ទុកការងារក្នុងប្រទេស និង** K (UKIAT00023 K) **នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៣**

ករណីនេះពាក់ពន្ធ័នឹងស្ត្រីជនជាតិអាល់បែនី ដែលត្រូវបានក្រុមគ្រួសាររបស់នាងលក់អោយអោយទៅបុរសម្នាក់ដោយគិតថាគាត់នឹងរៀបការជាមួយនាង តែតាមការពិត គាត់មានចេតនាលក់នាងអោយទៅធ្វើជាពេស្យាចា ។ តុលាការទទួលស្គាល់ថាមិនមានការការពារសំរាប់នាងគ្រប់គ្រាន់នៅក្នុងប្រទេសអាល់បែនីហើយថាប្រទេសនោះ " មិនគោរពអោយបានពេញលេញនូវបទដ្ឋានអប្បបរិមាក្នុងការលុបបំបាត់អំពើជួញដូរ "។ដូច្នេះក៏បានសំរេចថា មានគ្រោះថ្នាក់ជាក់ស្តែងសំរាប់ស្ត្រីនេះដែលអាចនឹងទទួលរងនូវការគំរាមសំលាប់ហើយថានាងអាចទទួលរងនូវការរំលោភលើសិទ្ធិសេរីភាពដូចមានចែងក្នុងមាត្រា ៣ និង ៨ នៃ ECHR។

**សេចក្តីសំរេចរបស់សមត្ថកិច្ចសាលាឧទ្ធរណ៍អន្តោប្រវេសន៍ រវាង** Ms Tam Thi Dao **និងរដ្ឋលេខាធិការទទួលបន្ទុក ការងារក្នុងប្រទេស** (HX/28801/2003) **នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៣**

ករណីនេះទាក់ទងនឹងក្មេងស្រីវៀតណាមម្នាក់ដែលត្រូវគេជួញដូរទៅប្រទេសអង់គ្លេស និង បានរត់គេចចេញពីអ្នកជួញដូរ មុនពេលគេដាក់នាងអោយចូលធ្វើជាពេស្យាចា ។ ចៅក្រមបានរកឃើញថាដោយសារអាយុរបស់នាង និង អវត្តមាននៃក្រុមគ្រួសារនិងមិត្តភក្រ័នៅវៀតណាមនាងនឹងពិតជាប្រឈមមុខយ៉ាងខ្លាំងក្នុងអំពើកេងប្រវញ្ច័ និង ការចរាចរជួញដូរសារជាថ្មីប្រសិនបើបញ្ជូននាងត្រឡប់ទៅប្រទេសវៀតណាមវិញ ។ គាត់បានចាត់ទុកថាប្រសិនបើនាងត្រូវទទួលរងការជួញដូរសារជាថ្មីនោះនឹងមានន័យថានាងអាចទទួលការគំរាមគំហែងសំលាប់ ហើយនាងមានសិទ្ធិទទួលបានការការពារក្រោមអនុសញ្ញាជនភៀសខ្លួនក្នុងនាមជាសមាជិកនៃក្រុមពិសេសមួយដោយផ្អែកលើភេទរបស់នាង ។ គាត់ក៏បានអនុញ្ញាតិអោយនាងធ្វើការតវ៉ាក្រោមមាត្រា ៣, ៤ និង ៨ នៃ ECHR។

**សារៈសំខាន់នៃអនុសញ្ញាអន្តោប្រវេសន៍ឆ្នាំ ១៩៩០ : ឧទាហរណ៍ពីចក្រភពអង់គ្លេស និង ឥណ្ឌូនេស៊ី**

ដូចបានលើកឡើងខាងលើ អនុសញ្ញាអន្តោប្រវេសន៍ឆ្នាំ ១៩៩០ មានបំណងការពារសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់របស់កម្មករអន្តោប្រវេសន៍នៅគ្រប់ដំណាក់កាលនៃដំណើរការធ្វើអន្តោប្រវេសន៍ និងធានា

អោយបាននូវការថែទាំប្រកបដោយសមភាពរវាងកម្មករអន្តោប្រវេសន៍ និង ជនជាតិនៃប្រទេសនោះនៅទូទាំងតំបន់ ។

រហូតមកដល់ពេលនេះមិនមានប្រទេសដែលទទួលជនអន្តោប្រវេសន៍ធំៗណាបានផ្តល់សច្ចាប័នដល់អនុ-សញ្ញាជនអន្តោប្រវេសន៍ឆ្នាំ ១៩៩០ នេះទេ-រួមទាំងអ្នកដែលបានធ្វើអន្តោប្រវេសន៍តាមប្រពន្ធ័ប្រក្រតី-ត្រូវប្រឈមមុខនឹងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនៅក្នុងបណ្តាប្រទេសទាំងនេះ រួមទាំងការបង្ខិតបង្ខំអោយធ្វើការងារ ហើយពួកគេត្រូវប្រឈមមុខនឹងការរើសអើងទាំងលើកម្រៃដែលត្រូវទទួលបាន និង លក្ខខណ្ឌផ្សេងៗទៀត ។ បើតាមអង្គការការងារអន្តរជាតិអ្នកដាក់ពាក្យជាជនអន្តោប្រវេសន៍ដែលមានសមត្ថភាពច្រើនជាងម្នាក់នៅក្នុងចំណោមបីនាក់ត្រូវបានទាត់ចោលពីនីតិវិធីជ្រើសរើសអោយចូលធ្វើការងារដោយអយុត្តិធម៌នៅក្នុងប្រទេសឧស្សាហ៍កម្មរបស់លោកខាងលិច ។[៤០]

ឧទាហរណ៍ខាងក្រោមបង្ហាញអំពីស្ថានភាពជាទូទៅដែលជនអន្តោប្រវេសន៍ធម្មតាមិនទទួលបានការការពារសមស្របប្រឆាំងនឹងការងារដោយបង្ខិតបង្ខំ និង ការកេងប្រវ័ញ្ច ដោយច្បាប់ជាតិ ។

### ការកេងប្រវ័ញ្ច និង ការងារដោយបង្ខិតបង្ខំនៅក្នុងប្រទេសអង់គ្លេស

ថ្មីៗនេះ រដ្ឋាភិបាលអង់គ្លេសបានបោះពុម្ពផ្សព្វផ្សាយដែលបញ្ជាក់អំពីសម្បទានជាវិជ្ជមានដែលកម្មករអន្តោប្រវេសន៍ជួយដល់សេដ្ឋកិច្ច និង បានពង្រីកនូវផែនការដើម្បីអោយកម្មករអន្តោប្រវេសន៍បន្ថែមទៀតចូលទៅក្នុងប្រទេសអង់គ្លេស ។ ការិយាល័យទទួលបន្ទុកកិច្ចការក្នុងប្រទេសបានលើកឡើងថាជនអន្តោប្រវេសន៍បានបង់ពន្ធចំនួន ២.៥ កោដផោនថែមទៀតច្រើនជាងអ្វីដែលគេទទួលបានជាផលប្រយោជន៍នៅក្នុងឆ្នាំ ១៩៩៩-២០០០ ។

ប្រទេសអង់គ្លេសកាន់តែមានតំរូវការកើនឡើងលើការពឹងពាក់លើពលករអន្តោប្រវេសន៍ជាពិសេសនៅលើផ្នែកថែរទាំសុខភាព អប់រំ បោសសំអាត កសិកម្ម សណ្ឋាគារ និង បដិសណ្ឋារកិច្ច បច្ចេកវិទ្យា និង ការងារសាងសង់ ។ មានការប៉ាន់ប្រមាណថាប្រទេសអង់គ្លេសនឹងត្រូវការជនអន្តោប្រវេសន៍រហូតដល់ទៅ ១.២ លាននាក់ ភាគច្រើនមិនមានជំនាញ នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះសំរាប់គ្រាន់តែទៅជំនួសកម្មករដែលនឹងត្រូវចូលនិវត្តន៍ ។[៤១]

---

[40] International Labour Orgnization, *Facts on Migrant Labour, 2003.*

[41] Adapted from Selaisse and Weiss, *The Brain Drain-Africa's Achilles Heel,* World Market in Focus 2002, World Markets Reseach Centre, London, 2002. Quoted in IOM *World Migration 2003, op. cit., p.222.*

ពេលនេះមានផ្លូវខុសៗគ្នាជាច្រើនដើម្បីចូលទីផ្សារការងារប្រទេសអង់គ្លេសដែលរួមមាន: អ្នកកាន់បណ្ណ័នធ្វើការងារ ផែនការសំរាប់អ្នកធ្វើការងារពេលមកសំរាកកំសាន្ត កម្មករកសិកម្មតាមរដូវ ផែនការតាមផ្នែក កម្មករបំរើការងារក្នុងផ្ទះ ទិដ្ឋកាធ្វើការងារដោយខ្លួនឯង កម្មវិធីជនអន្តោប្រវេសន៍ដែលមានជំនាញខ្ពស់ និស្សិត ជនជាតិនៃប្រទេសសហគមន៍អឺរ៉ុប ។ល។ ប្រពន្ធ័នេះមានលក្ខណៈស្មុគស្មាញ និង ប្រចូកប្រចល់ដោយសារថាកម្មវិធីនីមួយៗមានសិទ្ធិ និង ផលប្រយោជន៍ដែលត្រូវទទួលបានផ្សេងៗគ្នា ។ ចំនុចនេះហើយដែលកម្មករអន្តោប្រវេសន៍អាចនឹងមិនយល់អំពីសិទ្ធិរបស់ខ្លួន និង ថាតើត្រូវអនុវត្តសិទ្ធិនោះបែបណា ។

របាយការណ៍របស់ Kalayaan ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយធ្វើការផ្សព្វផ្សាយ និង គាំទ្រដល់កម្មករ ដែលបំរើការក្នុងផ្ទះគូសបញ្ជាក់អំពីវិធីសាស្ត្រនៃការការពារសិទ្ធិរបស់កម្មករអន្តោប្រវេសន៍តាមច្បាប់ដែលមានជាធរមាននៅក្នុងប្រទេសអង់គ្លេស ។ Kalayaan បានរកឃើញថា ជាមធ្យម កម្មករបំរើការងារក្នុងផ្ទះបានចុះបញ្ជីជាមួយនឹងពួកគេត្រូវបានអ្នកជួលរបស់គេដកលិខិតឆ្លងដែនរក្សាទុក (មានកម្មករអន្តោប្រវេសន៍សរុបចំនួន ៥១១ នាក់រវាងខែ មករា ២០០១ និង មិថុនា ២០០៣) ។[៤២] ការដកយកលិខិតឆ្លងដែនទៅរក្សាទុកនេះធ្វើអោយកម្មករអន្តោប្រវេសន៍ងាយទទួលរងគ្រោះដោយការចាប់បញ្ជូន និង បើកឱកាសអោយអ្នកជួលបន្ថែមនូវសំពាធលើកម្មករនោះអោយទទួលយកប្រាក់កម្រៃតិចតួច និង លក្ខខណ្ឌលំបាកៗ ។ ហើយក៏ជារនាំងដល់កម្មករនោះក្នុងការទទួលបាននូវសេវា និង ផលប្រយោជន៍ផ្សេងៗជាច្រើនទៀត ។

ទោះបីជាបែបនេះក៏ដោយ មិនមានច្បាប់នៅក្នុងប្រទេសអង់គ្លេសដែលការពារកម្មករពីការដែលគេដកយកលិខិតឆ្លងដែន ឬ ដាក់ទោសដល់អ្នកជួលសំរាប់ការប្រព្រឹត្តបែបនេះនោះទេ ។ មាត្រា ២១ នៃ អនុសញ្ញាជនអន្តោប្រវេសន៍ឆ្នាំ ១៩៩០ ចែងថាកម្មករអន្តោប្រវេសន៍ទាំងអស់ត្រូវទទួលបានការការពារប្រឆាំងនឹងការដកហូត ឬ ការបំផ្លិចបំផ្លាញឯកសារអត្តសញ្ញាណរបស់ពួកគេ ។

ស្ថិតិរបស់ការិយាល័យទទួលបន្ទុកកិច្ចការក្នុងប្រទេសបង្ហាញថាមានកម្មករបំរើការងារក្នុងផ្ទះប្រមាណ ១៤000 បានទទួលសិទ្ធិធ្វើការងារនៅក្នុងប្រទេសអង់គ្លេសរៀងរាល់ឆ្នាំ ។ ទោះជាយ៉ាងណាក៏ដោយ កម្មករទាំងនេះមិនត្រូវបានទទួលការការពារសមស្របដោយច្បាប់ការងាររបស់អង់គ្លេសទេ ដើម្បីប្រឆាំងនឹងការកេងប្រវញ្ច័ និង ការរើងអើង ។ ឧទាហរណ៍ដូចជា នៅតែស្របច្បាប់នៅឡើយទេចំពោះការរើងអើងដោយផ្អែកលើមូលដ្ឋានជនជាតិ និង ពណ៌សម្បុរនៅពេលជួលអ្នកណាម្នាក់អោយធ្វើការងារនៅក្នុងផ្ទះឯកជន ។ លើសពីនេះទៅទៀត ប្រសិនបើអ្នកជួលអាចបង្ហាញថាពួកគេទទួលបានការថែទាំដូចជា " ផ្នែកមួយនៃក្រុម

[42] Kalayaan, *Migrant Workers' Rights: The Passport Issu,* London, 2003, p.15.

គ្រួសារ " នោះកម្មករបំរើការងារក្នុងផ្ទះត្រូវបានលើកលែងពីច្បាប់ប្រាក់បៀវត្សន៍ សេចក្តីណែនាំការងារមិនអនុវត្តចំពោះកម្មករបំរើការងារនៅក្នុងផ្ទះទេ ។

ប្រភេទនៃថៃទាំបែបនេះមិនកំរិតត្រឹមកម្មករក្នុងផ្ទះជាជនអន្តោប្រវេសន៍ទេ ។ របាយការណ៍សមាជសហជីពជំនួញ *ធ្វើការងារហួសកំលាំង និង មិនទទួលបានកម្រៃ* បានធ្វើការកត់សំគាល់លើការអនុវត្តប្រហាក់ប្រហែលគ្នានេះដែលប៉ះពាល់ដល់ប្រភេទកម្មករផ្សេងៗទៀតរួមទាំងគិលានុបដ្ឋាយិការដ្ឋាន និង កម្មករកសិកម្ម ។ សហជីពសេវាសាធារណ UNISON បានជួយដល់កម្មករអន្តោប្រវេសន៍មកពី ហ្វីលីពីន សាំបាហ្វេ ម៉ាឡាវី អាហ្វ្រិកខាងត្បូង និង ប្រទេសឥណ្ឌាដែលត្រូវបានគេនាំមកប្រទេសអង់គ្លេសដើម្បីធ្វើការជាអ្នកថែរទាំសុខភាពនៅក្នុងផ្ទះផ្តល់សេវាថែទាំ ។ UNISON បានកត់ត្រាឯកសារលើករណីដែលជនអន្តោប្រវេសន៍ត្រូវបានគេយកកម្រៃរហូតដល់ទៅ ២០០០ ផោនដោយភ្នាក់ងារនានានៅក្នុងបណ្តាប្រទេសកំណើតដើម្បីដាក់ចូលធ្វើការងារនៅក្នុងប្រទេសអង់គ្លេស ។ នៅពេលមកដល់ អ្នកផ្សេងត្រូវគេប្រាប់ថាត្រូវធ្វើការងារយ៉ាងហោចណាស់សំរាប់រយៈពេលពីរឆ្នាំ ឬ បង់ "លុយផាក " រហូតដល់ទៅ ៧០០០ ផោន ។ កម្មករទាំងនេះជាញឹកញាប់បានទទួលកម្រៃតិចជាងអ្វីដែលគេសន្យា ធ្វើការងារច្រើនម៉ោង សុំអោយប្រគល់លិខិតឆ្លងដែន និង បណ្ណ័នអនុញ្ញាតិធ្វើការងារ និង ស្ថិតនៅក្នុងស្ថានភាពដែលគួរអោយភ័យខ្លាច ។[៤៣]

ឧទាហរណ៍ទាំងនេះ បង្ហាញថាកម្មករអន្តោប្រវេសន៍នៅក្នុងប្រទេសអង់គ្លេសកំពុងធ្វើការងារនៅក្នុងស្ថានភាពដែលមិនត្រឹមតែទទួលការកេងប្រវ័ញ្ចប៉ុណ្ណោះទេ តែក្នុងករណីខ្លះក៏អាចមានការងារបង្ខិតបង្ខំ (ឧ. ក្នុងករណីដែលគេដកឯកសារចេញដើម្បីបង្ខំអោយជនអន្តោប្រវេសន៍អោយបន្តធ្វើការងារ ឬ ទទួលយកលក្ខខណ្ឌការងារដែលមានការកេងប្រវ័ញ្ច) ។ ទោះបីជាបែបនេះក៏ដោយ ប្រទេសអង់គ្លេសនឹងមិនធានាដល់កម្មករអន្តោរប្រវេសន៍នូវសិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៩០ ដែលបានលើកឡើងថា: " នៅពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលមិនមានផែនការដើម្បីចុះហត្ថលេខា និង ផ្តល់សច្ចាប័នលើអនុសញ្ញា ។ រដ្ឋាភិបាលចាត់ទុកថាបានរក្សាបាននូវតុល្យភាពរវាងសេចក្តីត្រូវការសំរាប់ការគ្រប់គ្រងអន្តោប្រវេសន៍ និង ការការពារផលប្រយោជន៍ និង សិទ្ធិរបស់កម្មករអន្តោប្រវេសន៍ និង ក្រុមគ្រួសាររបស់ពួកគេនៅក្នុងប្រទេសអង់គ្លេស ។"[៤៤]

---

[43] Trades Union Congress, *Overworked, underpaid and over here: Migrant workers in Britain,* London, July 2003, pp.27-27.

[44] Letter from the Home Office, Immigration and Nationality Directorate to the Joint Council for he Welfare of Immigrants, 7 August 2003.

បរាជ័យក្នុងការផ្តល់ការការពារសមស្របចំពោះជនអន្តោប្រវេសន៍មិនក៏រិតត្រឹមតែរដ្ឋនៅអឺរ៉ុប ឬ ប្រទេសទទួលដូចករណីខាងក្រោមនៃកម្មករអន្តោប្រវេសន៍ឥណ្ឌូនេស៊ីបង្ហាញស្រាប់ ។




## ការកេងប្រវ័ញ្ច និង ការងារដោយបង្ខិតបង្ខំលើកម្មករអន្តោប្រវេសន៍ឥណ្ឌូនេស៊ី[៤៥]

ចាប់តាំងពីដើមឆ្នាំ ១៩៨០ មក ភាពក្រីក្រ អត្រាគ្មានការងារខ្ពស់ និង ការខ្វះខាតផ្នែកឱកាសនៃការអប់រំបានធ្វើអោយជនអន្តោប្រវេសន៍ឥណ្ឌូនេស៊ីទៅបរទេសដើម្បីស្វែងរកការងារធ្វើ និង មុនចុងឆ្នាំ ១៩៩០ ពួកគេបានក្លាយទៅជាប្រជាជនអន្តោប្រវេសន៍ដែលមានចំនួនដ៏ធំយ៉ាងលឿនបំផុតនៅអាស៊ី ។ មុនពាក់កណ្តាលឆ្នាំ ២០០១ ជនអន្តោប្រវេសន៍ឥណ្ឌូនេស៊ីជាង ៧០ ភាគរយជាស្ត្រី និង ៤៣ ភាគរយបានធ្វើការងារនៅក្នុងផ្នែកក្រៅផ្លូវការដូចជាអ្នកបំរើនៅក្នុងផ្ទះ កម្មកររោងចក្រ ឬ កម្មករសំណង់ ។[៤៦]

ជនជាតិឥណ្ឌូនេស៊ីភាគច្រើនដែលមានបំណងធ្វើការងារនៅបរទេសដែលគេយល់ថាមាន "តំលៃទាប " ឬ " មិនមានជំនាញ " ត្រូវឆ្លងកាត់ជាផ្លូវការតាមរយៈភ្នាក់ងាររកការងារដែលអនុញ្ញាតិដោយរដ្ឋាភិបាលចំនួន ៤០០ ដែលព្យាយាមស្វែងរកផលប្រយោជន៍ពីពាណិជ្ជកម្មលើជនអន្តោប្រវេសន៍ ។ ភ្នាក់ងារទាំងនេះជាធម្មតាទាញយកកំរៃពីការបណ្តុះបណ្តាល ដំណើរការរៀបចំឯកសារ និង ការដាក់ឈ្មោះដែលធ្វើអោយកម្មករអន្តោប្រវេសន៍ជាប់បំណុលយ៉ាងច្រើនតាំងតែពីមុនពេលដែលពួកគេចាប់ផ្តើមធ្វើការងារនៅបរទេស ។

---

45 Taken for the document Information on Indonesia: Compliance with ILO Convention No. 29 on Forced Labour (ratified in 1950), Asian Migrant Centre, Indonesian Migrant Workers' Union, Migrant Forum in Asia and Anti-Slavery International, August 2003.

46 Indonesia Country Report, *Asian Migrant Yearbook 2000,* The Asian Migrant Centre (AMC), November 2001, Hong Kong SAR.

លក្ខខណ្ឌតំរូវដ៏ចាំបាច់អោយចុះហត្ថលេខាលើកិច្ចសន្យាជាមួយនឹងភ្នាក់ងាររកការងារអោយធ្វើនេះមានន័យថាជនអន្តោប្រវេសន៍មានអំណាចតិចតួច ឬ មិនមានដើម្បីចចារលើកិច្ចសន្យា និង លក្ខខណ្ឌការងាររួមទាំងកំរៃជូនភ្នាក់ងារនោះ ។ ជនអន្តោប្រវេសន៍ជាច្រើនទីបំផុតទទួលយកនូវការងារអ្វីក៏ដោយដែលមានទោះបីជាការងារដែលមិនដូចជាអ្វីដែលត្រូវបានសន្យាក៏ដោយហើយនាំដល់ការកេងប្រវញ្ច័យ៉ាងធ្ងន់ធ្ងរ ។

តំរូវការរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ីអោយជនអន្តោប្រវេសន៍ប្រើប្រាស់ប្រពន្ធ័ភ្នាក់ងារ និង ភាពបរាជ័យរបស់វាក្នុងការផ្តល់សិទ្ធិ និង ការការពារសមស្រប បានធ្វើអោយកម្មករអន្តោប្រវេសន៍ងាយទទួលរងនូវសភាពគ្រោះថ្នាក់នៃអំពើកេងប្រវញ្ច័ និង ការងារបង្ខិតបង្ខំក្នុងអំឡុងពេលនៃដំណើរការធ្វើអន្តោប្រវេសន៍ ។

ភ្នាក់ងារទាំងនេះតំរូវអោយអ្នកដែលអាចជាកម្មករអន្តោប្រវេសន៍រស់នៅក្នុងជំរុំបណ្តុះបណ្តាល នៅប្រទេសឥណ្ឌូនេស៊ីពី ០១ ខែ ទៅ ១៤ ខែ ហើយជាធម្មតាពួកគេត្រូវគេបង្ខំអោយធ្វើការអោយបុគ្គលិកភ្នាក់ងារក៏ដូចជាការងារផ្សេងៗទៀតដូចជាបោសសំអាត ទៅផ្សារ និង ចំអិនម្ហូបអាហារ ។ ទោះបីជាក្រសួងការងាររបស់ឥណ្ឌូនេស៊ីបានកំណត់បទដ្ឋានអប្បបរិមាដើម្បីគ្រប់គ្រងលើការអនុវត្តនានានៅក្នុងជំរុំនេះ កម្រឃើញមានការអនុវត្តណាស់ ។ ការកំរិតនានាត្រូវបានដាក់លើសេរីភាពដើរហើររបស់ជនអន្តោប្រវេសន៍ និង លក្ខ-ខណ្ឌនៅក្នុងជំរុំមានការលំបាក ជាធម្មតានាំដល់បញ្ហាសុខភាពដោយសារមានការថែរទាំសុខភាពតិចតួច ។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងដោយមជ្ឈមណ្ឌលកម្មករអន្តោប្រវេសន៍ឥណ្ឌូនេស៊ី (CIMW) អំពីលក្ខ-ខណ្ឌនៅខាងក្នុងជំរុំបណ្តុះបណ្តាលទាំង ១០០ នេះ ក្មេងស្រី/ស្ត្រី ៦៨ ភាគរយដែលបានសំភាសមិនទទួលបានពូកសំរាប់កេងនោះទេ ៦២ ភាគរយលើកឡើងថាពួកគេទទួលបានម្ហូបមិនគ្រប់គ្រាន់ និង ប្រាំបួនភាគរយមិនទទួលបានម្ហូបអាហារទាល់តែសោះ ។ ទោះបីជាជំរុំបណ្តុះបណ្តាលជាច្រើនបានផ្តល់ជូននូវបង្គន់ ០១ ក្នុងចំណោមស្ត្រីចំនួន ៥០ នាក់ ជំរុំបណ្តុះបណ្តាលមួយមានមនុស្ស ២០០ នាក់ប្រើប្រាស់បង្គន់តែមួយប៉ុណ្ណោះ។ ការបំពានផ្លូវកាយ និង ផ្លូវភេទត្រូវបានគេរាយការណ៍ដោយអ្នកទទួលសំភាសចំនួន ១៧ ភាគរយ ។[៤៧]

ការស្រាវជ្រាវក៏បានរកឃើញថា កម្មករស្ទើរតែទាំងអស់ដែលឆ្លងកាត់ការសំភាសបានចុះហត្ថលេខាលើកិច្ចសន្យាដែលជាភាសាបរទេស (ដោយមិនមានការបកប្រែ) និង មិនបានអានកិច្ចសន្យានោះ ។ សែសិបមួយភាគរយត្រូវបានភ្នាក់ងារបង្ខិតបង្ខំដោយអោយប្រើប្រាស់អាយុ និង អាស័យដ្ឋានក្លែងក្លាយ និង ៧៨ ភាគរយនៃស្ត្រីដែលបានឆ្លងកាត់ការសំភាសបានបង់កំរៃខុសច្បាប់អោយទៅអ្នករត់ការចំនួន ១០០ ០០០ រូពី (១២ ដុល្លារ) ឬ ប្រាំពីរលានរូពី (៨៥៥ ដុល្លារអាមេរិក) ។ ទោះបីជាបានធ្វើបែបនេះក៏ដោយ ក៏មិនមានការធា

---

47 *Training Camps for Potential Indonesian Migrant Women Workers: study on the Conditions Inside Training Camps for Indonesian Migrant Workers in Jakarta,* Centre for Indonesian Migrant Workers, September 1999, Jakarta, Indonesia.

នាណាមួយដែលថាជនអន្តោប្រវេសន៍ទាំងនោះទីបំផុតនឹងមិនធ្លាក់ចូលក្នុងការងារខុសច្បាប់នៅបរទេសនោះទេ ។



និយោជិក ដែលរស់នៅអាគារបង្ហាញនេះ ។ នាងត្រូវបានគេវាយដោយរំពាត់ នៅពេលគេមិនពេញចិត្តការងារនាង ។ នាងកំពុងរងចាំ ទទួលការសងការខូចខាត ពីតុលាការការងារហុងកុង ។

ការកេងប្រវ័ញ្ចលើជនអន្តោប្រវេសន៍នៅបន្តបន្ទាប់ពីចាកចេញប្រទេសទទួល ។ នៅពេលនេះពួកគេស្ថិតនៅក្នុងស្ថានភាពមួយនៃការការជាប់បំណុល និង ការងារដោយការបង្ខិតបង្ខំនៅពេលពួកគេបង់កម្រៃទៅភ្នាក់ងារដែលជាធម្មតាជាការជំរិតយក បើទោះបីជាកម្រៃជាអតិរិមាបែបនេះត្រូវបានគេកំណត់ដោយរដ្ឋាភិបាលឥណ្ឌូនេស៊ីក៏ដោយ ។ ជនអន្តោប្រវេសន៍ដែលតំបន់ឈូងសមុទ្រត្រូវបង់កម្រៃចំនួន ៤០០ ០០០ រូពី (៤៩ ដុល្លារ) ជាមួយនឹងការកាត់ប្រាក់ខែពីរ ឬ បីខែ ។ អ្នកដែលទៅប្រទេសតៃវ៉ាន់ត្រូវបង់ចំនួន ៨២ ៦៥៣ NT (២៤៣០ ដុល្លារ) ជាមួយនឹងការកាត់ប្រាក់ខែចំនួន ២១ ខែបន្ថែមលើកំរៃជើងសារស្មើនឹង ៦០ ០០០ NT (១៧៦០ ដុល្លារ) ។ អ្នកដែលទៅ ហុង កុងត្រូវបង់ចំនួន ១៧ ៨៤៥ ០០០ រូពី (២១៧៩ ដុល្លារ) តែជាង ៥០ ភាគរយនៃជនអន្តោប្រវេសន៍ទៅហុងកុងបង់កំរៃដើម្បីរកការងារធ្វើយ៉ាងច្រើនសន្ធឹកសន្ធាប់រហូតដល់ទៅ ២១ ០០០ ដុល្លារហុងកុង (២៦៩៩ ដុល្លារអាមេរិក) ជាមួយនឹងការកាត់ប្រាក់ខែពីបួនទៅ ប្រាំពីរខែ ។[៤៨] ដូច្នេះទោះបីជាជនអន្តោប្រវេសន៍ឥណ្ឌូនេស៊ីទទួលរងការធ្វើបាប និង បង្ខិតបង្ខំអោយធ្វើការងារច្រើនម៉ោងក្រោមលក្ខខណ្ឌគ្រោធគ្រាធយ៉ាងណាក៏ដោយពួកគេមិនអាចចាកចេញបានទេដោយសារថាកិច្ចសន្យាដែលពួកគេបានចុះហត្ថលេខា និង ប្រាក់ " ដែលជំពាក់ " ដល់ភ្នាក់ងារ ។ ជនអន្តោប្រវេសន៍ទាំងឡាយណាដែលសិទ្ធិរបស់គេទទួលការរំលោភបំពាន ជាពិសេសអ្នកដែលបានចុះហត្ថលេខាលើកិច្ចសន្យាដោយប្រើប្រាស់ឈ្មោះក្លែងក្លាយមានការលំបាកក្នុងការទទួលបានពត៌មាន និង ជំនួយពីអាជ្ញាធរកុងស៊ុលឥណ្ឌូនេស៊ីអំពីការប្រើប្រាស់យន្តការទាវសំណង ។

[48] Indonesia Country Report, *Asia Migrant Yearbook 2001,* The Asian Migrant Centre (AMC), April 2002, Hong Kong SAR.

យោងតាមការស្រាវជ្រាវអំពីស្ថានភាពរួមកន្លងមក ៤៨ ភាគរយនៃកម្មករអន្តោប្រវេសន៍នៅ ហុង កុង បានទទួលកម្រៃពីការងារក្រោមកំរិតអប្បបរិមា ៦១ ភាគរយមិនបានឈប់សំរាកថ្ងៃប្រចាំសប្តាហ៍ និង ២៤ ភាគរយទទួលរងការរំលោភបំពានលើរូបរាងកាយ និង ពាក្យសំដី ។[៤៩]

ជនអន្តោប្រវេសន៍ក៏ត្រូវបង់ប្រាក់កម្រៃយ៉ាងច្រើនលើសលប់ដល់ភ្នាក់ងារ ដើម្បីបន្តកិច្ចសន្យាការងាររបស់ពួកគេ ។ យោងតាមការស្ទង់មតិដែលបានធ្វើឡើងនៅ ហុង កុង ៨៩ ភាគរយនៃអ្នកឆ្លើយតបបានបង់ប្រាក់កម្រៃខ្ពស់ជាងអ្វីដែលបានកម្រិតដោយច្បាប់ ៣៦៧ ដុល្លារហុងកុង (៤៧ ដុល្លារ សហរ)ដែលជាចំនួនកំណត់ដោយរដ្ឋាភិបាលហុងកុង ។ កម្រៃជាមធ្យមដែលអ្នកឆ្លើយក្នុងការស្ទង់មតិបានបង់គឺ ៥ ៦៥៥ ដុល្លារហុងកុង (៧២៧ ដុល្លារ សហរ) និង អ្នកឆ្លើយចំនួន ៥ ភាគរយបានបង់រហូតដល់ទៅ ១០ ០០០ ដុល្លារហុងកុង (១ ២៨៥ ដុល្លារ សហរ) ។[៥០]

មាត្រា ៦៦ នៃ ក្រិត្យក្រសួងរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ីលេខ 104A/2002 រិតតែធ្វើអោយស្ថានភាពកាន់តែយ៉ាប់យ៉ឺនទៅដោយតំរូវអោយកម្មករអន្តោប្រវេសន៍ដែលមានស្ថានភាពទាប ត្រឡប់ចូល ឥណ្ឌូនេ-ស៊ីវិញដើម្បីបន្តកិច្ចសន្យារបស់គេ ។ នេះមានន័យថា ពួកគេត្រូវចាកចេញពីការងារចំនួនពីរសប្តាហ៍ ទិញសំបុត្រយន្តហោះ និង បង់កម្រៃទៅភ្នាក់ងារ ដែលជាធម្មតាពួកគេអាចជៀសវាងបានដោយអោយកុងស៊ុលឥណ្ឌូនេស៊ីនៅក្នុងប្រទេសទទួលនោះបន្តសុពលភាពលើកិច្ចសន្យា ។

ជនអន្តោប្រវេសន៍បន្តទទួលរងការកេងប្រវ័ញ្ច និង ការរើសអើងទោះបីជានៅពេលពួកគេវិលត្រឡប់មកប្រទេសកំណើតវិញក៏ដោយ ។ ជនអន្តោប្រវេសន៍ដែលវិលត្រឡប់មកវិញតាម ច្រកចេញ ៣ ដែលត្រូវបានរៀបចំជាពិសេសនៅព្រលានយន្តហោះ Soekamo Hatta International ដែលជាកន្លែងធ្លាប់មានរបាយការណ៍ថាជនអន្តោប្រវេសន៍ធ្លាប់ទទួលរងការរំលោភ និង ការធ្វើបាបលើរូបរាងកាយ និង ត្រូវបង់សំណូកដើម្បីអាចទទួលបានពត៌មាន និង សេវាជាមូលដ្ឋានផ្សេងៗទៀត ។ ក៏មានការតំរូវអោយសមាជិកក្រុមគ្រួសារនៅពេលពួកគេទៅដល់ ។ ប្រសិនបើពុំនោះទេ ពួកគេត្រូវត្រឡប់មកផ្ទះវិញដោយមធ្យោបាយដឹកជញ្ជូនដែលផ្តល់ជូនដោយភ្នាក់ងារ ដែលតំរូវអោយពួកគេបង់ប្រាក់ ១០ ដងច្រើនជាងអ្វីដែលគេត្រូវបង់ជូនទៅសេវាគមនាគមន៍សាធារណៈ ។

---

49 *Baseline Research on Racial Discrimination Against Foreign Domestic Helpers,* Asian Migrant Centre & Coalition for Migrants Rights, February 2002, Hong Kong SAR.

50 *Campaign for Fair Treatment of Indonesian Domestic Helpers in Hong Kong by Agencies Approved by the Hong Kong Labour Department,* Asian Migrant Centre, Amal Indonesia Direct & Coalition for Indonesian Migrant Workers Association (KOTKIHO), 30 March 2001, Hong Kong SAR.



## ៤.២ សិក្សាលើឧទាហរណ៍-អាជីក

បទពិសោធន៍របស់ អាជីក លើកឡើងអំពីជនអន្តោប្រវេសន៍ដែលបំរើការងារក្នុងផ្ទះជួបប្រទះនៅក្នុងដៃភ្នាក់ងាររកការងាររបស់ឥណ្ឌូនេស៊ី ។ អាជីក បានទំនាក់ទំនងជាមួយនឹងអ្នករត់ការនៅក្នុងភូមិកំណើតរបស់នាងដើម្បីជួយនាងទៅ ហុង កុង ដោយសារនាងបានដឹងពីសាច់ញាតិម្នាក់ថានាងអាចរកការងារបានប្រសើរជាងនៅទីនោះ និងអាចរកប្រាក់បានច្រើនជាងនេះ ។ អ្នករត់ការបាននាំនាងទៅជួបភ្នាក់ងាររកការងារនៅ សារ៉ាប៊ូយ៉ា ចាវ៉ា ខាងកើត ដោយនៅទីនោះនាងត្រូវបង់ប្រាក់ចំនួន ៣៩០ ០០០ រូពី (៤៤ ដុល្លារសហរ) ដើម្បីធ្វើតេស ឯកសណ្ឋាន និង សៀវភៅភាសាចិន និង សៀវភៅចំអិនម្ហូបអាហារ ។

អាជីក ត្រូវគេបញ្ជូនទៅជំរុំបណ្តុះបណ្តាលនៅ សារ៉ាបាយ៉ា ។ មានស្ត្រីនៅក្នុងជំរុំនេះប្រមាណ ១ ០០០ នាក់ ស្ត្រីទាំងនេះភាគច្រើនមានជំងឺដោយសារខ្វះខាតចំណីអាហារ និង ទឹកដែលមានអនាម័យត្រឹមត្រូវ ។ ស្ត្រីម្នាក់បានស្លាប់ដោយសារខ្វះសេវាថែទាំសុខភាព ។ អាជីក និង ស្ត្រីផ្សេងៗទៀតត្រូវបានគេចាប់បង្ខំអោយធ្វើការអោយបុគ្គលិករបស់ភ្នាក់ងារ ការងារអនាម័យ និង រៀនសូត្រភាសារយៈពេលយូរ ។ ក្នុងអំឡុងពេលបួនឆ្នាំនៅក្នុងជំរុំនេះ គេមិនអនុញ្ញាតិអោយ អាជីក ចេញទៅណានោះទេ ហើយក្រុមគ្រួសាររបស់នាងបានទទួលការអនុញ្ញាតិអោយមកជួបនាងតែពីរ ឬ បី ម៉ោងប៉ុណ្ណោះរៀងរាល់ពីរសប្តាហ៍ ។ មិនមានទូរសព្ទ័សំរាប់ អាជីក ទំនាក់ទំនងទៅក្រុមគ្រួសាររបស់នាងនោះទេ ចំណែកលិខិតស្នាមត្រូវគេត្រួតពិនិត្យ និង ដកយកចេញ ។ អាជីក បានចុះហត្ថលេខាលើឯកសារកិច្ចសន្យាដោយមិនមានការណែនាំពន្យល់លើនាងអ្វីទាំងអស់ ។

ក្រោយមកគេយក អាជីក ទៅហុងកុងដោយនៅទីនោះនាងបានធ្វើការងាររស់រយៈពេលប្រាំខែ ដោយមិនបានទទួលកម្រៃព្រោះថាលុយទាំងនោះត្រូវបង់ទៅភ្នាក់ងារដែលនាង " ជំពាក់ " ។ អាជីក ក៏ត្រូវប្រឈមមុខនឹងការបំពារបំពានដោយពាក្យសំដីជាប្រចាំ និង មិនអនុញ្ញាតិអោយចាកចេញពីផ្ទះសម្បែង និង បានសំរាកតែមួយថ្ងៃគត់ក្នុងរយៈពេលធ្វើការងារចំនួនប្រាំបួនខែ ។[៥១]

## ៩. សន្និដ្ឋាន

រដ្ឋត្រូវការអនុម័តច្បាប់ដែលហាមឃាត់ និង ផ្តន្ទាទោសលើអំពើជួញដូរមនុស្សគ្រប់រូបភាពដូចមានចែងក្នុងពិធីសារជួញដូររបស់អង្គការសហប្រជាជាតិ និង ធានាអោយបានថាជនរងគ្រោះដោយអំពើជួញដូរទទួលបាននូវការការពារ និង វិធានការគាំទ្រនានាដូចមានចែងក្នុងមាត្រា ៦ ៧ និង ៨ នៃពិធីសារនោះ ។ ហើយរដ្ឋក៏ត្រូវទទួលស្គាល់ថា គំនិតផ្តួចផ្តើមតែត្រឹមនេះនឹងមិនគ្រប់គ្រាន់សំរាប់ប្រយុទ្ធប្រឆាំងនឹងបញ្ហាជួញដូរមនុស្សនោះទេ ហើយគោលនយោបាយនានាត្រូវតែលើកឡើងអំពីឫសគល់នៃមូលហេតុនៃបញ្ហានេះដែលពាក់ពន្ធ័យ៉ាងជិតស្និទទៅនឹងបញ្ហាអន្តោប្រវេសន៍ ។

ការកើនឡើងនៃវិសមភាពលើទ្រព្យសម្បត្តិរវាង និង នៅក្នុងបណ្តាប្រទេស ព្រមទាំងការកើនឡើង និង ជាធម្មតាមិនមានការទទួលស្គាល់ នូវសេចក្តីត្រូវការលើកម្មករអន្តោប្រវេសន៍ទាំងក្នុងប្រទេសអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍកំពុងតែជំរុញអោយមានការធ្វើអន្តោប្រវេសន៍ ។ រដ្ឋាភិបាលជាច្រើនបានប្រតិកម្មចំពោះបញ្ហានេះ ដោយបង្កើនការផ្សព្វផ្សាយដែលជាទូទៅលើកឡើងអំពីកត្តាភ័យខ្លាចជូនដល់ប្រជាជនដែលអាចធ្វើអន្តោប្រវេសន៍ និង បំបាក់ទឹកចិត្តពួកគេពីការធ្វើដំណើរទៅបរទេសដើម្បីជាមធ្យោបាយកសាងជីវិត និង បានបង្កើននូវផលប្រយោជន៍ជាច្រើនដល់អំពើជួញដូរ និង រត់ពន្ធមនុស្ស ដោយកាត់បន្ថយច្រកផ្លូវធ្វើអន្តោ-ប្រវេសន៍ធម្មតា ។

ការជំរុញអោយធ្វើអន្តោប្រវេសន៍ធម្មតា និង ក្រោមការគ្រប់គ្រងមានសក្តានុពលដើម្បីកាត់បន្ថយអំពើជួញដូរ និង ការរត់ពន្ធដោយការផ្តល់ជូនជនអន្តោប្រវេសន៍នូវយន្តការមួយដែលពួកគេអាចទទួលបានការងារនៅបរទេសដែលមានសុវត្ថិភាព សេវាថោកជាង និង ធានាបាននូវសិទ្ធិមនុស្ស និង សិទ្ធិការងារនៅក្នុងប្រទេសគោលដៅ ។

---

[51] យោងទៅតាមការស្រាវជ្រាវ ដោយមជ្ឈមណ្ឌលអន្តោប្រវេសន៍អាស៊ី និងអង្គការសម្ព័ន្ធសិទ្ធិអន្តោប្រវេសន៍ បានអោយដឹងថា ភាគច្រើននៃ អន្តោប្រវេសន៍ឥណ្ឌូនេស៊ី នៅហុងកុង ទទួលបានការឈប់សំរាក២ថ្ងៃក្នុងមួយខែ ។

ទោះជាយ៉ាងណាក៏ដោយ ត្រូវសង្កត់ធ្ងន់ថាទាំងជនអន្តោប្រវេសន៍ប្រក្រតី និង មិនប្រក្រតីត្រូវទទួលរងនូវអំពើជួញដូរ ការបង្ខិតបង្ខំអោយធ្វើការងារ និង ការកេងប្រវញ្ច័ក្រោមរូបភាពផ្សេងៗទៀត និង ការរើសអើង ។

ដូច្នេះជាការសំខាន់ណាស់ដែលការជំរុញអោយធ្វើអន្តោប្រវេសន៍នៅកើតឡើងក្នុងក្របខណ្ឌ័នៃប្រពន្ធ័អន្តោប្រវេសន៍មួយដែលមានតម្លាភាព ស្តង់ដា ហើយគ្រប់គ្រងដើម្បីផលប្រយោជន៍ជនអន្តោប្រវេសន៍ខ្លួនឯងប្រទេសប្រភព និង ប្រទេសទទួល ។ គន្លឹះក្នុងការបង្កើតឡើងប្រពន្ធ័បែបនេះគឺការធានាបានថារដ្ឋទាំងអស់ចុះហត្ថលេខា និង ផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីការការពារសិទ្ធិកម្មករអន្តោប្រវេសន៍ទាំងអស់ និង ក្រុមគ្រួសាររបស់ពួកគេឆ្នាំ ១៩៩០ ។

**Selected Bibliography**

Anti-Slavery International, *Human Traffic, Human Rights: Redefining Vicitim Protection,* London, 2002.

Anti-Slavery International, ILO Special Action Programme to Combat Forced Labour and Asian Migrant Centre, *Framework for Action to Address Forced Labour and Traifficiking in Domestic Work in Asia,* Hong Kong, 2003.

International Labour Organization, *Trafficking in Human Beings, New Approaches to the Problem,* Geneva, 2003.

International Organization, *World Migration 2003,* Geneva, 2003.

International Organization for Migration, *Elusive Protection, Uncertain Lands: Migrants'Access to Human Right,* Geneva, 2003.

Joint Council for the Welfare of Immigrants and Trades Union Congress, *Migrant Workers: A TUC guide,* London, 2003.

Kalayaan, *Migrant Workers'Rights: The Passport Issue,* London, 2003.

Trades Union Congress, *Overworked, underpaid and over here: Migrant Workers in Britain,* London, 2003.

United Nations Association, *Migrant Workers: Who Benefit?* London, 2003.

United Nations Office of the High Commissioner for Human Rights, *Recommended Guidelines on Human Rights and Human Trafficking,* Geneva, 2002.

**Useful Websites**

Anti-Slavery International: **www.antislavery.org**

December 18 and Migrant Rights International: www.icftu.org

International Labour Organization: www.ilo.org
and www.ilo.org/migrant

International Organization for Migration: www.iom.int

Joint Council for the Welfare of Immigrants: www.jcwi.org.uk

Organization for Security and Co-Operation in Europe: www.osce.org/europe-against-trafficking and www. osce.org.odihr/democratisation/trafficking

Trades Union Congress: www.tuc.org.uk

United Nations Association: www.una-uk.org

United Nations Office of the High Commissioner for Human Rights
www.unhchr.ch/women/focus-trafficking.html

បទដ្ឋានអន្តរជាតិដែលទាក់ទងនឹងសិទ្ធិរបស់ជនអន្តោប្រវេសន៍ ការងារដោយបង្ខិតបង្ខំ និង អំពើជួញដូរនៅថ្ងៃទី ១ ខែ វិច្ឆិកា ២០០៣ ចុះហត្ថលេខាដោយរដ្ឋមួយ ឬ ច្រើន ។

រក្សាសិទ្ធិ © អង្គការប្រឆាំងអំពើទាសភាពអន្តរជាតិ ឆ្នាំ ២០០៣

ISBN: 0 900918 58 6

និពន្ធដោយលោក Mike Kaye

រៀបចំទំរង់អត្ថបទដោយ Becky Smaga ( អត្ថដើមជាភាសា អង់គ្លេស)

រូបភាពដោយ Lorena Ros and Dominic Ridley

បោះពុម្ពដោយ the Printed Word, UK

**Copyright © Anti-Slavery International 2003**
**ISBN: 0 900918 58 6**

**Written by Mike Kaye**
**Design and Layout by Becky Smaga (original English version)**
**Cover photograph by Lorena Ros and Dominic Ridley**
**Printed by the Printed Word, UK**

**November 2003.**

TROCAIRE
Working for a Just World

អង្គការប្រឆាំងអំពើទាសភាពអន្តរជាតិ សុំអរគុណ Trocaireដែលបានផ្តល់ជំនួយហិរញ្ញវត្ថុដល់គំរោងនេះ ។
អត្ថបទនេះ ជាទស្សនៈ របស់ អង្គការប្រឆាំងអំពើទាសភាពអន្តរជាតិ មិនមែនជាទស្សនៈរបស់ម្ចាស់ជំនួយទេ ។

កម្មវិធីអន្តរភ្នាក់ងារអង្គការសហប្រជាជាតិ
ប្រឆាំងអំពើជួញដូរមនុស្សនៅអនុតំបន់មេគង្គ (UNIAP) បានឧបត្ថម្ភ និងរៀបចំការ
បកប្រែអត្ថបទនេះជាភាសាខ្មែរ ។UNIAP សុំថ្លែងអំណរគុណ
អង្គការអន្តរជាតិប្រឆាំងអំពើទាសភាព ដែលបានអនុញ្ញាតិអោយ មានការបកប្រែនេះ ។
អត្ថបទនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ កម្មវិធីអន្តរភ្នាក់ងារអង្គការសហប្រជាជាតិ
ប្រឆាំងអំពើជួញដូរ មនុស្សនៅអនុតំបន់មេគង្គ (UNIAP) ។